អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber

Chambre de Premiere instance

**ឯកសារដើម**

**ORIGINAL/ORIGINAL**

ថ្ងៃ ខែ ឆ្នាំ (Date): 07-Nov-2013, 09:29

CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី លើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០២នាទី**

**សវនាការលើកទី២២១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ដាវ អានសាន

លោក ស៊ីម៉ុន មេសិនប៊ឹជ
*(Mr. Simon MEISENBERG)*

កញ្ញា មីរៀម ម៉ាហ្វេសាន់ទិ
*(Ms. Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក នីកូឡាស គូមជែន *(Mr.Nicolas KoumJian)*

លោក វ៉េង ហ៊ិត់

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក លោក឴ ឃីត រេយ៍ន័រ
*(Mr. Keith RAYNOR)*
លោក ឌេល លីសាក់ *(Mr. Dale Lysak )*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន
*(Mr. Arthur VERCKEN)*
កញ្ញា អង់តា ហ្គីសសេ*(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡៅ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ទី ស្រ៊ីនណា

លោក ហុង គឹមសួន

លោកស្រី ម៉ាទីន ហ្សាកកាំង
*(Ms. Martine JAQUIN)*
លោកស្រី បេនី យេ*(Ms.Beini YE)*

កញ្ញា លីម៉ា ង្វៀន *(Ms.Lyma NGUYEN)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ
*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធារី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
| --- | --- |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក អាកទួរ វែកគែន | បារាំង |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ មុននឹងផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ឡើងធ្វើសេចក្តីថ្លែងនូវសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០១។ សូមលោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តីមានវត្តមាន។ សូមកត់សម្គាល់ថា លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនពីក្រោមសាលសវនាការនេះតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក ផារី។ ជាបន្តទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសឡើងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង ០០២/០១។

**លោក អាកទួរ វែកគែន៖**

បាទ សូបអរគុណលោកប្រធាន។ បាទ ខ្ញុំនឹងចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានចំពោះលោក ខៀវ សំផន។ ជាសេចក្តីផ្តើម -- បាទខ្ញុំសូមពន្យល់ដោយខ្លីអំពីទស្សនៈនៃការអន្តរាគមន៍របស់យើងខ្ញុំ។ យើងព្យាយាមលម្អិតអំណះអំណាងរបស់យើងលើអង្គសេចក្តីនៅក្នុងសារណាសន្និដ្ឋានបញ្ចប់ ដែលយើងបានដាក់ប៉ុន្មានថ្ងៃមុននេះ។ នៅក្នុងចំនួន១២៥ទំព័រ ដែលអស់លោក លោកស្រីចៅក្រមបានកំណត់។

ពីរថ្ងៃចុងក្រោយនេះ សហភាតា វ៉ិចទ័រ កូប៉េ និង សុន អរុណ បានធ្វើការសន្និដ្ឋានដោយជាក់លាក់បំផុតលើចំណុចជាច្រើនដែលក្រុមរបស់ពួកគាត់ ហើយនិងក្រុមរបស់យើងបាននិយាយយ៉ាងលម្អិតនៅក្នុងសារណាសន្និដ្ឋានបញ្ចប់របស់យើង។ យោងទៅលើគុណភាពនៃបទអន្តរាគមន៍ផ្ទាល់មាត់របស់

គាត់ យើងយល់ឃើញថាដូចជាមិនជាការគួរទេក្នុងការត្រឡប់មកនិយាយអំពីចំណុចទាំងអស់នេះដែលពួកគាត់បានលើកអស់ហើយ។

[០៩:០៦:០១]

បាទ ដើម្បីនិយាយឲ្យច្បាស់នោះគឺថាយើងសុំឲ្យតុលាការចាត់ទុកថាអ្វីដែលសហភាតារបស់យើងដែលពោរពេញទៅដោយទេពកោសល្យនិយាយនៅទីនេះ សូមឲ្យទទួលស្គាល់ ហើយយើងគិតថាអ្វីដែលគាត់និយាយដូចជាអ្វីដែលយើងនិយាយដែរ។ បាទ ឥឡូវនេះខ្ញុំសូមបើកបទអន្តរាគមន៍របស់យើងខ្ញុំលើសំណួរមួយដែលជាសេចក្ដីផ្ដើមនៃសារណាសន្និដ្ឋានបញ្ចប់របស់យើងខ្ញុំ ហើយដែលទាក់ទងទៅនឹងវិសាលភាពនៃការជម្រះសេចក្ដីយើងនេះ។ ហើយខ្ញុំនឹងបញ្ចប់ដោយនិយាយអំពីបញ្ហាភស្ដុតាងមុននឹងផ្ដល់វេទិកាសហភាតារបស់ខ្ញុំ គឺលោកស្រី អង់តា ហ្គីសសេ។ ហើយបន្ទាប់មកទៀត លោកមេធាវី គង់ សំអុន នឹងនិយាយបញ្ចប់នៅថ្ងៃទី១នេះ។

នីតិវិធីនៅចំពោះមុខតុលាការយើងនេះ វាមានលក្ខណៈមួយដែលថានៅពេលដែលយើងសរសេរសារណាសន្និដ្ឋានបញ្ចប់យើងមិនដឹងអំពីគោលបំណងនៃសារណាសន្និដ្ឋានបញ្ចប់របស់សហព្រះរាជអាជ្ញាទេ ពីព្រោះថាសារណាទាំងពីរនេះត្រូវបានដាក់នៅថ្ងៃតែមួយនៅម៉ោងតែមួយ ខុសគ្នាតែពីរបីនាទីប៉ុណ្ណោះគឺថ្ងៃទី២៦ កញ្ញា ឆ្នាំ២០១៣។

[០៩:០៧:៤០]

ក៏ប៉ុន្តែបញ្ហាវិសាលភាពនៃការជម្រះសេចក្ដីយើងនេះមានសារៈសំខាន់ទ្វេឡើងៗ នៅពេលដែលយើងឃើញពីរបៀបដែលសហព្រះរាជអាជ្ញាទើបនឹងកែប្រែតាមរយៈសារណាសន្និដ្ឋានបញ្ចប់ ហើយនិងតាមសេចក្ដីសន្និដ្ឋានផ្ទាល់មាត់នៅទីនេះ គឺគាត់បានកែប្រែអំណះអំណាងលើអង្គហេតុ ហើយនិងផ្នែកគតិយុត្តិនៅក្នុងការជម្រះសេចក្ដីយើងនេះ។ បាទ ដើម្បីឲ្យគេយល់ខ្ញុំទាំងអស់គ្នា ខ្ញុំនិយាយនេះគឺសំដៅទៅសាធារណជន។ ដូចអស់លោកដឹងហើយថាខ្ញុំចង់និយាយអំពីអ្វី។ ខ្ញុំសូមរំឭកពីកាលបរិច្ឆេទគន្លឹះមួយចំនួន។ នៅថ្ងៃទី១៥ កញ្ញា ឆ្នាំ២០១០ ចៅក្រមស៊ើបអង្កេតដែលបានស៊ើបអង្កេតទាក់ទងទៅនឹងលោក ខៀវ សំផន។ គាត់បានចេញដីកាដំណោះស្រាយលើអង្គហេតុទាំងអស់តែម្ដងដែលទំនងជាត្រូវបានប្រព្រឹត្តនៅប្រទេសកម្ពុជាចន្លោះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ និងថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩។ ដីកាដំណោះស្រាយនេះ គឺរៀបរាប់អំពីបទឧក្រិដ្ឋយ៉ាងច្រើនដែលត្រូវបានប្រព្រឹត្តអនុលោមទៅតាមគោលនយោបាយទាំងប្រាំនៃកម្ពុជាប្រជាធិបតេយ្យ។ គោលនយោបាទាំងប្រាំនេះ គឺ១) គឺការជម្លៀសទាំងបី

ដំណាក់កាល។ ពីដំបូងគឺពីទីក្រុងទៅជនបទ ហើយបន្ទាប់មកទៀត ពីជនបទទៅជនបទ។ គឺពីខេត្តមួយទៅខេត្តមួយ។ គោលនយោបាយទី២ គឺការបង្កើត និងដាក់ឱ្យដំណើរការសហករណ៍ ហើយនិងការដ្ឋានការងារ។ គោលនយោបាយទី៣ គឺការអប់រំនៃសមាសភាពថ្មី ការកាប់សម្លាប់រង្គាលខ្មាំងនៅក្នុង និងនៅក្រៅ ហើយនិងនៅក្នុងជួរបក្ស។ គោលនយោបាយទី៤ គឺការកំណត់អតីតយោធា និងមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរ ហើយនិងចាម ពុទ្ធសាសនិក វៀតណាម ហើយគោលនយោបាយទី៥ គឺការកំណត់វិធានរៀបអាពាហ៍ពិពាហ៍។ បាទ នេះគឺជាខ្លឹមសារនៃដីកាដំណោះស្រាយទាំងស្រុងតែម្តង ទាំងមូលតែម្តង។

[០៩:១០:៣៨]

នៅថ្ងៃទី២២ កញ្ញា ឆ្នាំ២០១១ នៅពេលដែលការជំនុំជម្រះមិនទាន់បានចាប់ផ្តើមនៅឡើយ អង្គជំនុំជម្រះបានសម្រេចថា ផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យយើងមិនជម្រះសេចក្តីលើអង្គហេតុទាំងអស់នេះក្នុងពេលតែមួយទេ។ ដូច្នេះតាមរយៈដីកាបំបែកដំណើរការនីតិវិធី អស់លោក លោកស្រីចៅក្រមបានជ្រើសរើសយកអង្គហេតុមួយចំនួនដែលអស់លោក លោកស្រីចៅក្រមបានទទួល ហើយលោកបានគិតថា ត្រូវអង្គហេតុទាំងអស់នេះជាកម្មវត្ថុនៃការជម្រះសេចក្តីដំណាក់កាលទី១នេះ ហើយអស់លោក លោកស្រីចៅក្រមបានប្រកាសដោយមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់ទេថា អង្គហេតុផ្សេងៗទៀតនឹងត្រូវយកមកជម្រះនៅពេលក្រោយ បន្ទាប់ពីការជម្រះសេចក្តីលើកទី១នេះ។ កាលពីដើមអង្គជំនុំជម្រះដែលត្រូវបានជ្រើសរើសនៅថ្ងៃទី២២ កញ្ញា ឆ្នាំ២០១១នេះ កម្រិតមកត្រឹមតែការជម្លៀសទាំងពីរដំណាក់កាលនោះទេ។ ហើយលោកបានសម្រេចថា នឹងធ្វើការជម្រះសេចក្តីទៅលើតែការជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយនិងការជម្លៀសប្រជាជនចេញពីខេត្តមួយ ពីតំបន់មួយទៅតំបន់មួយទៀត នៅខែសីហា ឆ្នាំ១៩៧៥។

ហើយបន្ទាប់មកទៀតនៅថ្ងៃទី៨ តុលា ឆ្នាំ២០១២ ដែលមានលេខកូដ E163/5 នៅពេលដែល -- ពេលនោះអង្គ -- យើងបានចាប់ផ្តើមជំនុំជម្រះតាំងពីរយៈពេល១១ខែ ១៣ថ្ងៃមកហើយ ហើយនៅក្នុងសវនាការ តុលាការបានសម្រេច បាទខ្ញុំសូមដកស្រង់៖ “គឺកំណត់តែឱ្យចប់តែម្តង ថាតើប្រភេទអង្គហេតុណាខ្លះ ហើយនិងបញ្ហាណាខ្លះដែលនឹងស្ថិតនៅក្នុង -- ដែលជាកម្មវត្ថុនៃការជម្រះសេចក្តី០០១ យើងនេះ អំ! ០០២/០១។ ហើយនៅថ្ងៃនោះ អង្គជំនុំជម្រះបានសម្រេចចិត្តពង្រីកវិសាលភាពលើ -- វិសាលភាពដែលធ្លាប់បានធ្វើមកហើយថា បន្ថែមលើការជម្លៀសលើកទី១ លើកទី២នេះ បានបន្ថែមអង្គ

ហេតុដែលត្រូវបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃទៀត។ នៅពេលពីរបីថ្ងៃដែលបន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ"។ បាទ ខ្ញុំសូមសង្កត់ធ្ងន់លើការដែលថា នៅទួលពោធិ៍ជ្រៃនេះ យើងនិយាយតែពីរយៈពេលពីរបីថ្ងៃក្រោយខែមេសា ឆ្នាំ៧៥ តែប៉ុណ្ណោះ។

[០៩:១៣:៥១]

នៅក្នុងសេចក្ដីសម្រេចរបស់អស់លោក លោកស្រីចៅក្រមនោះ គឺថាតែរយៈពេលខ្លីទេ។ នេះគឺជារបៀបដែលលោក អស់លោក លោកស្រីចៅក្រមបានផ្សាភ្ជាប់អង្គហេតុទួលពោធិ៍ជ្រៃទៅនឹងវិសាលភាពដែលមានរួចមកហើយ គឺថាការជម្លៀសដំណាក់កាលទី១ ទី២។ បាទ ខ្ញុំសូមសង្កត់ធ្ងន់ផងដែរ ពីព្រោះថា ទួលពោធិ៍ជ្រៃនេះ គឺជាទីកន្លែងសម្លាប់មនុស្ស។ បើសិនជាយើងអានដីកាដំណោះស្រាយវិញ យើងមើលទៅឃើញថា ហាក់ដូចជានៅតែបន្តដំណើរការពេលក្រោយទៀត ក្រោយខែមេសា ហ្នឹងទៅទៀតរហូតដល់ឆ្នាំ៧៦ ឆ្នាំ៧៧។ សេចក្ដីសម្រេចថ្ងៃទី០៨ តុលា ឆ្នាំ២០១២ ច្បាស់ណាស់ គឺថាសេចក្ដីសម្រេចហ្នឹងពេលដែលបញ្ចូលទួលពោធិ៍ជ្រៃនេះ គឺថានិយាយតែរយៈពេលដែលខ្លីទេ បន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយលោក លោកស្រីចៅក្រមបាននិយាយថា ពុំមានការប៉ះពាល់អ្វីធ្ងន់ទេទាក់ទងទៅនឹងការរៀបចំការជម្រះសេចក្ដីយើងនេះ ពីព្រោះថាយើងត្រូវការបន្ថែមតែសាក្សីតែពីរនាក់ទៀតតែប៉ុននុ៎ងទេនៅក្នុងការជម្រះសេចក្ដីនេះ។

តាមរយៈការសម្រេចសេចក្ដីសម្រេចថ្ងៃទី០៨ តុលា ឆ្នាំ២០១២ អស់លោក លោកស្រីចៅក្រមបានផ្ដល់បញ្ជីស្ដាពរមួយនៃកថាខណ្ឌទាំងអស់នៃដីកាដំណោះស្រាយចុះថ្ងៃទី១៥ កញ្ញា ឆ្នាំ២០១០ ដែលជាវិសាលភាពនៃការជម្រះសេចក្ដីយើងឥឡូវនេះ ហើយយើងនិយាយតែក្នុងវិសាលភាពនេះទេ។ ហើយលោក លោកស្រីចៅក្រម ត្រឹមត្រូវហើយក្នុងការនិយាយថាសេចក្ដីសម្រេចនេះគឺជាលិខិតផ្លូវការមួយវាលើសពីហ្នឹងទៀតផង។ គឺជាឯកសារស្ថាបនិកនៃការជម្រះសេចក្ដីយើងសព្វថ្ងៃនេះ។

[០៩:១៦:០៥]

ឯកសារនេះគឺថា អស់លោក លោកស្រីបានទទួលពីអំពីមនុស្ស ហើយនិងអង្គហេតុ គឺថាអស់លោក លោកស្រីចៅក្រមត្រូវបានគេប្ដឹងពីមនុស្ស ហើយនិងអង្គហេតុដែលត្រូវជម្រះសេចក្ដីនៅក្នុងការសេចក្ដីនេះ។ អង្គហេតុដែលមិនមាននៅក្នុងដីកាបំបែកនីតិវិធីដែលពង្រីកដល់ទួលពោធិ៍ជ្រៃនេះ មិនអាចយកមកជម្រះសេចក្ដីបានទេ។ ពីព្រោះវាមិនមែនជាកម្មវត្ថុនៃការជម្រះសេចក្ដីដែលចំណាយអស់រយៈពេលពីរឆ្នាំមកហើយ នេះវាសាមញ្ញបំផុត។ ហើយត្រូវច្បាស់លាស់ត្រង់ចំណុចហ្នឹង ព្រោះថានេះជា

ច្បាប់មូលដ្ឋាន។ ហើយនៅក្នុងរយៈពេលពីរឆ្នាំដែលបានកន្លងផុតមកនេះ ដែលយើងធ្វើសវនាការ រាល់ដងដែលសាក្សីប្រថុយប្រថាននឹងនិយាយអំពីអង្គហេតុដែលនៅក្រៅពីការជម្លៀសទាំងពីរដំណាក់កាលនេះ ហើយនៅចាប់ពីខែតុលា ២០១២ ដែលអស់លោក លោកស្រីចៅក្រម បានបន្ថែមអង្គហេតុទួលពោធិ៍ជ្រៃនេះ អង្គជំនុំជម្រះបានបញ្ឈប់សាក្សី ឬក៏មេធាវីដែលនិយាយ ឬក៏សួរទាក់ទងទៅនឹងប្រធានបទផ្សេងៗមិនពាក់ព័ន្ធ។

បើសិនជាយើងធ្វើការបូកសរុបអ្នកទៅ គឺថាអ្នកដែលគេ -- ដែលអស់លោក លោកស្រីអនុញ្ញាតឲ្យនិយាយនោះគឺមានតែដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលដែលពួកគាត់ត្រូវការនិយាយពីការឈឺចាប់របស់ពួកគាត់។ ហើយខ្ញុំគិតថាប្រហែលជាធម្មតាទេ ពីព្រោះថាប្រហែលជាមិនជាការគួរទេ -- ដែលប្រហែលជាមិនការគួរទេ បើយើងមិនឲ្យគាត់និយាយបែងចែកអំពីការឈឺចាប់របស់គាត់ និងមូលហេតុនៃការឈឺចាប់របស់គាត់ ដែលកើតចេញពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។

[០៩:១៨:២៦]

ហើយអ្នកផ្សេងទៀតអាចនិយាយបានដែរថា និយាយអំពីអង្គហេតុទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយទាំងអស់នុំងគឺជាសាក្សីដែលចាស់ៗ។ ឧទាហរណ៍ ដូចជា សគីម ល្មុត, ឡុង នរិន្ទ អីជាដើម ដែលពួកគាត់នោះមិនអាចមកទីនេះបាន អ៊ីចឹងយើងស្ដាប់គាត់តាមរយៈវីដេអូខនហ្វើរិន ហើយអង្កាល់នោះយើងស្ដាប់ឮគឺថា នៅតាមនោះ មានកន្លែងគាត់នោះមានពិធីការមួយ ពេលដែលគាត់ឆ្លើយមកសំឡេងការហ្នឹងចូល ហើយយើងឮគេចាក់ភ្លេងផងដែរ ពេលដែលគាត់ផ្ដល់សក្ខីកម្មនោះ។

អ៊ីចឹងគិតថា ដោយសារមូលហេតុទាំងអស់នេះហើយ គឺថាដោយសារសាក្សីទាំងអស់នោះចាស់ហើយអ៊ីចឹងគឺយើងឲ្យគាត់ផ្ដល់សក្ខីកម្មក្នុងវិសាលភាពទាំងស្រុងតែម្ដង។ ប្រហែលជាដោយមូលហេតុដូចគ្នានេះហើយ គឺថាដោយឈរលើបញ្ហាសំខាន់ហ្នឹងហើយដែលអ្នកជំនាញពីរនាក់គឺ ដេវីដ ឆេនល័រ ហើយនិង ស្មួត នោះបានអាច គាត់អាចនិយាយពីអង្គហេតុទាំងអស់ដែលហួសពីវិសាលភាពនៃអង្គហេតុជម្លៀសដំណាក់កាលទី១ ដំណាក់កាលទី២ ហើយនិងទួលពោធិ៍ជ្រៃ។

[០៩:១៩:៤១]

យើងអាចភ្ជាក់ផ្អើលអំពីការដែលវិសាលភាពប្រែប្រួលយ៉ាងដូច្នេះ។ កញ្ញា ២០១២ គឺថាយើងចាប់ផ្ដើមសវនាការអស់រយៈពេល១១ខែ ហើយនិង១៣ថ្ងៃហើយ ហើយវិសាលភាពនៅតែប្រែប្រួលទៀត។ ខ្ញុំសូមរំឭកផងដែរថា លោក ខៀវ សំផន មិនបានប្ដឹងឧទ្ធរណ៍អំពីសេចក្ដី -- អំពីដីកាបំបែក

នីតិវិធីទេ ហើយបន្ទាប់មកទៀតអស់លោក លោកស្រីចៅក្រមបញ្ជូលដល់ទូលពោធិ៍ជ្រៃទៀត ក៏មិនបានប្តឹងដែរ។ ហើយយើងគិតថាវិធានទាំងអស់ហ្នឹងវាហួត់ចត់ ហើយត្រូវតែទទួលស្គាល់ ហើយយើងគិតថានឹងមានការដោះលែងកូនក្តីខ្ញុំយ៉ាងឆាប់រហ័ស។

ក្រៅពីសេចក្តីសម្រេចខែកញ្ញា ឆ្នាំ២០១១ ហើយតុលា ២០១២ តុលាការយើងនេះពុំមានសិទ្ធិក្នុងការបន្ថែម ហើយនិងពង្រីកអង្គហេតុទេ ឬក៏ដកអង្គហេតុទេ។ ប៉ុន្តែអស់លោក លោកស្រីចៅក្រមមានសិទ្ធិសេរីភាពក្នុងការកំណត់ប្រភេទបទល្មើសតាមចិត្តចង់ នៅពេលចុងក្រោយក្នុងខណៈដែលអស់លោក លោកស្រីចៅក្រមទុកឲ្យមេធាវី -- ផ្តល់លទ្ធភាពឲ្យមេធាវីនិយាយអំពីការកំណត់ប្រភេទបទចោទ។

ខ្ញុំនិយាយកន្លែងនេះ គឺនិយាយអំពីការកំណត់ប្រភេទបទចោទ។ ការជម្រះសេចក្តីគឺថាអង្គហេតុ អង្គហេតុនេះគឺជាឫសគល់នៃរឿងរ៉ាវទាំងអស់ គឺអំពើគឺព្រឹត្តិការណ៍ស្ថាបនិក។ រីឯការកំណត់ប្រភេទបទល្មើសហ្នឹងអាចប្រែប្រួលបាន រហូតដល់ពេលដែលក្នុងខណៈដែលជនជាប់ចោទមានលទ្ធភាពការពារខ្លួនបាន។ ក៏ប៉ុន្តែអង្គហេតុដែលយើងជម្រះសេចក្តីមិនអាចប្រែប្រួលបានទេ បើមិនដូច្នោះទេយើងនឹងអាចនឹងរំលោភបំពានទៅលើគោលការណ៍កាត់សេចក្តីដោយយុត្តិធម៌។

[០៩:២២:០៨]

ឥឡូវខ្ញុំសូមនិយាយអំពីបញ្ជីចុងក្រោយនេះ ដែលនៅខែតុលា ឆ្នាំ២០១២ ដែលយើងបានទទួលគឺបញ្ជីទាក់ទងនឹងទួលពោធិ៍ជ្រៃ។ បាទខ្ញុំសូមនិយាយដោយសង្ខេបអំពីផ្នែកទាំងប្រាំពីរនៃឯកសារហ្នឹង ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះបួនទំព័រជាភាសាបារាំង លឿនទេ។ ប៉ុន្តែផ្នែកទី១ គឺការរៀបរាប់អង្គហេតុ អ៊ីចឹងគឺថាឯកសារហ្នឹងវាដូចនឹងដីកាដំណោះស្រាយផងដែរ គឺថាបានជ្រើសរើសយកកថាខណ្ឌមួយចំនួន។ យើងមានប្រវត្តិបក្ស -- របបកម្ពុជាប្រជាធិបតេយ្យ រចនាសម្ព័ន្ធរដ្ឋបាលមជ្ឈិម រចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន។ ហើយបន្ទាប់មកទៀតយើងមានប្រព័ន្ធទំនាក់ទំនង ហើយបន្ទាប់មកទៀតយើងមានរចនាសម្ព័ន្ធយោធា។ ហើយដល់ជំពូកទី២ ហ្នឹងផ្នែកហ្នឹងគួរឲ្យចាប់អារម្មណ៍ដែរចំពោះយើងខ្ញុំ គឺអង្គហេតុដែលទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួម។ បន្ទាប់មកទៀត មានសេចក្តីផ្តើម ហើយនៅផ្នែកចុងក្រោយគេ គឺគោលនយោបាយដែលអនុវត្ត ដើម្បីសម្រេចផែនការរួម។ ហើយការជម្លៀសមានសរសេរ ការពិនិត្យពិចារណាចំណុចនេះ គឺថាកម្រិតនៅត្រឹមតែការជម្លៀសដំណាក់កាលទី១, ទី២តែប៉ុណ្ណោះ។ ហើយនិងវិធានការទៅលើក្រុមជាក់លាក់ ហើយការពិចារណាទៅលើការប្រព្រឹត្តទៅលើអតីតយោធារបប លន់ នល់ នៅទួលពោធិ៍ជ្រៃ។ អ៊ីចឹងវាអត់មានចំណុចណាគួរឲ្យមន្ទិលសង្ស័យទេ។

[០៩:២៤:២១]

ផ្នែកទី២ អង្គហេតុនៃបទឧក្រិដ្ឋកម្មដែលចោទប្រកាន់។ គឺថាអង្គហេតុដែលគេអាចនឹងបញ្ចូលទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ បន្ទាប់មកទៀតគឺថាមានការជម្លៀសវគ្គទី១ ជម្លៀសដំណាក់កាលទី២ ទីកន្លែងសម្លាប់មនុស្សដូចជាទួលពោធិ៍ជ្រៃ។

ខ្ញុំចូលទៅទំព័រទី២ ផ្នែកទី៣ តួនាទីរបស់ជនជាប់ចោទ។ ចំណុច(គ) គឺលោក ខៀវ សំផន គេកន្លែងនេះមាននិយាយថា នៅក្នុងការជម្រះសេចក្ដីយើងនេះ យើងនឹងនិយាយអំពីបរិបទសវនាការ ដែលគាត់ជាសមាជិកគណៈមជ្ឈិម ហើយបានចូលក្នុងការងារគណៈអចិន្ត្រៃយ៍ ហើយដែលគាត់ជាប្រធានគណៈប្រធានរដ្ឋ ប្រធាន និងកម្មាភិបាលឈានមុខនៃមន្ទីរ៨៧០ ហើយនិងការទទួលខុសត្រូវខាងពាណិជ្ជកម្មនិងបញ្ជី និងតម្លៃ។ ហើយមានតួនាទីផ្សេងៗទៀត ហើយនិងមានទំនាក់ទំនងជាមួយនឹងអ្នកដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ហើយបន្ទាប់មកទៀតមានសរសេរនៅចំណុចចុងក្រោយហ្នឹងគឺថាការចូលរួមក្នុងផែនការរួម ការផ្លាស់ទីលំនៅប្រជាជន ហើយកម្រិតមកត្រឹមតែការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១, ទី២ ហើយក្រុមមនុស្សជាក់លាក់ផ្សេងៗ ហើយកម្រិតមកត្រឹមតែអតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរតែប៉ុណ្ណោះ។ បាទ នេះគឺច្បាស់ណាស់នៅពេល ដែលយើងនិយាយអំពីការចូលរួមក្នុងផែនការរួម អំពីអង្គហេតុដែលបានគ្រោងទុក អង្គហេតុដែលអស់លោក លោកចៅក្រមបានទទួលដើម្បីឲ្យយើងអាចការពារកូនក្ដីយើងបាន។ អ៊ីចឹងបញ្ជីស្លាពរនេះសំខាន់ណាស់។

[០៩:២៦:២៥]

ខ្ញុំចូលដល់ផ្នែកទី៣ គឺថាសេចក្ដីសន្និដ្ឋានបែបផ្នែកច្បាស់ទាក់ទងទៅនឹងបទឧក្រិដ្ឋដែលចោទប្រកាន់។ បាទត្រង់ចំណុចនេះ ចង់ដឹងថាតើបទឧក្រិដ្ឋជាក់លាក់ដែលត្រូវបាននិយាយក្នុងផ្នែកទី២នេះអាចបញ្ចូលទៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរឬអត់? ហើយរាល់ពេល គេកំណត់ដែនវិសាលភាពដដែល ដែលជាការធ្វើឃាតកម្ម ហើយការសម្លាប់រង្គាលនៅទួលពោធិ៍ជ្រៃ។ ពេលខ្លះមានអង្គហេតុដែលថាលោក ខៀវ សំផន នោះមិនត្រូវបានចោទប្រកាន់ទេ គាត់មិនបានចូលរួមទេព្រឹត្តិការណ៍ទាំងអស់នោះ ក៏ប៉ុន្តែរាល់ដងគឺថាមានការសម្លាប់រង្គាល ការជម្លៀសដំណាក់កាលទី១, ទី២, ការធ្វើទុក្ខបុកម្នេញខាងនយោបាយ កម្រិតមកត្រឹមការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១, ទី២។ អំពើអមនុស្សធម៌ផ្សេងៗក្រោមទម្រង់ការប៉ះពាល់ដល់សេចក្ដីថ្នូររបស់មនុស្ស កម្រិតត្រឹមការផ្លាស់ទីប្រជាជនដំណាក់កាលទី១, ទី២ អំពីមនុស្សធម៌។ ហើយកម្រិតមកត្រឹមការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១, ទី២។

ការបាត់ខ្លួនដោយបង្ខំ កម្រិតត្រឹមការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។ អ៊ីចឹងរឿងទាំងអស់នេះ ច្បាស់ណាស់ មានសរសេរច្បាស់លាស់។

[០៩:២៨:០៦]

ខ្ញុំសូមចូលទៅផ្នែកទី៥។ តម្រង់នៃការទទួលខុសត្រូវ ចំណុច(ក) គឺការទទួលខុសត្រូវចូលក្នុងសហឧក្រិដ្ឋកម្មរួម។

កថាខណ្ឌ១៥២១, ១៥២៥ កន្លែងនេះអង្គជំនុំជម្រះបាននិយាយថា ដកចេញពីចំណុចទី២ និង៣ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចំណុច៤ ចំណុច៥។ ការសម្លាប់ខ្មាំង ការដាក់ចូលសហករណ៍ ការសម្លាប់ខ្មាំងក្នុងនិងក្រៅជួរបក្ស ហើយនិងការបង្ខំឱ្យរៀបការ។ ហើយនិងជំនុំជម្រះតែលើទាហាន និងអតីតមន្ត្រីរដ្ឋការសម័យសាធារណរដ្ឋខ្មែរ ហើយនិងចាម វៀតណាម។ អ៊ីចឹងត្រង់ចំណុចទាំងអស់នេះ ក្នុងផ្នែកនេះដែលរួមបញ្ចូលវិធានការដាក់លាក់ប្រឆាំងនឹងក្រុមជាក់លាក់នេះ។ ត្រង់ចំណុចនេះ បើគិតទៅមានតែ យើងត្រូវតែពិចារណាតែលើអតីតអ្នកមន្ត្រីរដ្ឋការនៃសាធារណរដ្ឋខ្មែរទេ។ អ៊ីចឹងចំណុចនេះក៏ច្បាស់ដែរចំពោះខ្ញុំជាកូនមេធាវីតូចតាចនេះ ពីព្រោះមើលទៅឃើញច្បាស់ហើយ។

ចំណុច(ខ) គឺថាជាសហឧក្រិដ្ឋកម្មរួម ហើយទម្រង់នៃសហឧក្រិដ្ឋកម្មរួម ទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវ ព្រោះថាមិនមានត្រឹមតែសហឧក្រិដ្ឋកម្មរួមទេដែលយើងប្រើជាទម្រង់នៃទំនួលខុសត្រូវនោះ គឺថាមានបន្ថែមទៀតផងថា ការរៀបចំផែនការ ការញុះញង់ ការជួយ និងជំរុញ ហើយការបញ្ជា ហើយរាល់ដងនោះគឺថា ការកម្រិតមកត្រឹមតែបទល្មើសជាក់លាក់នោះទេ។ ដូចដែលអស់លោកលោកស្រីចៅក្រម បានកំណត់នៅក្នុងផ្នែកមុនហ្នឹង គឺថាដូចជាការជម្លៀសដំណាក់កាលទី១ ដំណាក់កាលទី២ ហើយនិងព្រឹត្តិការណ៍ដែលកើតមានឡើងនៅទួលពោធិ៍ជ្រៃក្នុងរយៈប៉ុន្មានថ្ងៃក្រោយការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញតែប៉ុណ្ណឹងទេ។ បាទ ដូច្នេះម្តងទៀត ខ្ញុំលើកឡើងថាវាច្បាស់លាស់ណាស់ទៅហើយវិសាលភាពនេះ។

[០៩:៣១:០៤]

ផ្នែកមួយទៀត គឺផ្នែកបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ នួន ជា, អៀង សារី, ខៀវ សំផន។ អៀង សារី ស្លាប់ហើយ។ ហើយផ្នែកមួយទៀត គឺសេចក្តីសម្រេចបញ្ចប់ យើងនិយាយពីការផ្តន្ទាទោសការចោទប្រកាន់ នៅក្នុងនេះគឺថាមានកថាខណ្ឌ ដូចជាកថាខណ្ឌ១៦១៣ ហើយកំណត់ត្រឹមតែបទល្មើសជាក់លាក់ដែលពាក់ព័ន្ធមួយចំនួននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺបានន័យថា ជាអ្វីដែលអស់លោក

លោកស្រីចៅក្រម បានកំណត់នៅក្នុងផ្នែកទាំងអស់នេះ។ អ៊ីចឹងខ្ញុំអានជូនអម្បាញ់មិញហ្នឹងហើយ។

បាទ ខ្ញុំសូមអភ័យទោសដែលធ្វើបទបង្ហាញនេះ ដែលចំពោះអ្នកខ្លះនោះឃើញថា មើលទៅគួរឲ្យ -- ព្រោះថាមើលទៅនិយាយដូចជាចង់រករឿង អ្នកខ្លះគេស្អប់ខ្ញុំត្រង់ហ្នឹង ប៉ុន្តែមិនបញ្ហាអ្វីទេ។

បើតាមរយៈការអាន ការកំណត់ទាំងអស់នេះ អ៊ីចឹងយើងឃើញវាស្តែងចេញឲ្យឃើញថា មិនអាចប្រកែកបានថា រាល់ពេលដែលនិយាយអំពីអង្គហេតុ ហើយរាល់ពេលនិយាយអំពីទម្រង់ទំនួលខុសត្រូវ អស់លោក លោកស្រីចៅក្រមបានកំណត់យុត្តាធិការមកត្រឹមតែ -- វិសាលភាពមកត្រឹមតែការជម្លៀសលើកទី១ ដំណាក់កាលទី១ ដំណាក់កាលទី២ ហើយនិងទួលពោធិ៍ជ្រៃ ដែលកើតមានឡើងនៅខែមេសា ឆ្នាំ១៩៧៥ តែប៉ុណ្ណោះ។ បាទ ដូច្នេះខ្ញុំសូមនិយាយបន្តិចពីខ្លឹមសារ មុននឹងចូលទៅចំណុចផ្សេងទៀត។ ការជម្លៀសដំណាក់កាលទី១ គឺជាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ បើតាមសហព្រះរាជអាជ្ញាគឺថា ប្រហែលជាការជម្លៀសនេះត្រូវបានសម្រេចនៅខែមិថុនា ឆ្នាំ១៩៧៤ ហើយការជម្លៀសនេះធ្វើទៅលឿនបំផុតតែពីរបីសប្តាហ៍ទាំងអស់។ និយាយឲ្យចំទៅ គឺថាប្រជាជនទាំងអស់ត្រូវបានបញ្ជូនចេញពីទីក្រុងភ្នំពេញ ក៏ប៉ុន្តែកថាខណ្ឌដែលមាននៅក្នុងដីកាដំណោះស្រាយលើកឡើងថា ការជម្លៀសនេះធ្វើទៅអស់រយៈពេលច្រើនសប្តាហ៍។ អ៊ីចឹងបើសិនជាយើងនិយាយឲ្យខ្លីទៅ គឺថាការអនុវត្តនេះបានបញ្ចប់នៅចុងខែកក្កដា ឆ្នាំ១៩៧៥។

[០៩:៣៣:៤៧]

ដើមខែកក្កដា យើងៗមិនដឹងថា មនុស្សទីចុងក្រោយដែលចាកចេញពីទីក្រុងភ្នំពេញហ្នឹងយើងមិនដឹងទេ។ យើងដឹងតែថ្ងៃដែលខ្មែរក្រហមចូលតែប៉ុណ្ណឹងឯង។ ទាក់ទងនឹងចំនួនមនុស្សដែលជនរងគ្រោះយើងមិនច្បាស់ទេ មិន -- យើងទាំងអស់គ្នាមិនបានឃើញរឿងរ៉ាវដូចគ្នាទេ។ យើងមើលក្នុងដីកាដំណោះស្រាយទៅ យើងមិនចាំបាច់និយាយឈ្មោះប្រកែកគ្នាអីទេ។ អ្នកខ្លះឃើញសាកសពយោធាមានឯកសណ្ឋាន ដែលអាចថាកើតចេញពីសង្គ្រាមច្បាំងគ្នារវាងខ្មែរក្រហម អ្នកខ្លះអត់មានបានឃើញអ្វីទេ។ អ្នកខ្លះបានឃើញយោធាខ្មែរក្រហមឲ្យអង្គរ និងលំនៅដ្ឋានដល់ប្រជាជន ដែលកំពុងតែជម្លៀស ហើយអ្នកខ្លះទៀតបានសរសេរពីរឿងរ៉ាវដែលឃោរឃៅជាងហ្នឹង លំបាកជាងហ្នឹង។ ឧទាហរណ៍ មានតែមនុស្សចាស់ កូនក្មេង ហើយនិងមន្ទីរពេទ្យដែលអត់មានអ្នកជំងឺជាដើម។

[០៩:៣៤:៤៩]

តួលេខតែមួយគត់នៃជនរងគ្រោះដែលមាននៅក្នុងកថាខណ្ឌៗមួយនៃដីកាដំណោះស្រាយនោះ

គឺមានចំនួនពី ២.០០០ ទៅ ៣.០០០នាក់ដែលលោក អៀង សារី គាត់ប្រាប់ទេនៅពេលដែលគេសម្ភាសគាត់នោះ។ ការវាយតម្លៃរបស់លោក ប៉ែន យៀរនិន និង ហ្វីលីព ស្បូត ហ្នឹងត្រូវបានរិះគន់កាលពីម្សិលមិញ ហើយរិះគន់ដោយត្រឹមត្រូវដោយសហភាតារបស់ខ្ញុំ–លោក កូប៉េ។ អ៊ីចឹងយើងក៏យល់ឃើញថាការវាយតម្លៃនេះគ្មានតម្លៃភស្តុតាងអីទេ។ ខ្ញុំមិនដឹងថាយើង -- ក៏ប៉ុន្តែទោះយ៉ាងណាក្តីតួលេខគឺថាមាននៅក្នុងដីកាដំណោះស្រាយ។ ការកាប់សម្លាប់ទាហាន លន់ នល់ នៅទួលពោធិ៍ជ្រៃ ដែលអស់លោកលោកស្រីចៅក្រមបានទទួលបណ្តឹង ចំនួននោះមិនច្បាស់លាស់អីទេ ទាក់ទងនឹងកាលបរិច្ឆេទ បើយើងពង្រីកពេលវេលាឲ្យបានវែងបំផុតនោះទៅតាមសក្ខីកម្មដ៏តិចបំផុតនោះ គឺថាប្រហែលជាឧក្រិដ្ឋកម្មនោះកើតមានចន្លោះថ្ងៃទី១៥ មេសា ហើយនិងដល់ ៣០ មេសា។ មានលក្ខណៈមិនច្បាស់លាស់ទេចំនួនជនរងគ្រោះនៅទួលពោធិ៍ជ្រៃប្រហែលពី ២០០ ទៅ២.០០០នាក់ គម្លាតឆ្ងាយណាស់។

[០៩:២៦:២៣]

បាទ ឥឡូវនេះខ្ញុំសូមចូលទៅនិយាយពីការជម្លៀសលើកទី២ ដំណាក់កាលទី២ ដែលមានមនុស្សដែលគេជម្លៀសពី ៤ទៅ៥០០.០០០នាក់ ដែលត្រូវបានធ្វើនៅខែសីហា ឆ្នាំ១៩៧៥ សម្រេចនៅខែសីហាហើយអនុវត្តនៅខែកញ្ញា។ ដូចនៅការជម្លៀសនៅទីក្រុងភ្នំពេញដែរ មិនដឹងថាបញ្ចប់នៅកាលបរិច្ឆេទណាទេ ការជម្លៀសនេះ ពីព្រោះថាបើអ្វីៗទាំងអស់សុទ្ធស្រពិចស្រពិល។

អង្គជំនុំជម្រះ ហើយសហព្រះរាជអាជ្ញាផងដែរនៅក្នុងសារណា សេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្លួនថានៅចប់នៅចុងឆ្នាំ១៩៧៦ ហើយនៅក្នុងសារណារបស់យើងនោះ យើងទទួលយកកាលបរិច្ឆេទនេះព្រោះថាយើងអត់មានតម្រុយអីដើម្បីនិយាយជំទាស់ អ្វីដែលយើងអាចលើកឡើងបាន កត់សម្គាល់បាននោះមានតែមួយគត់គឺថា ខ្មែរក្រហមបានជម្លៀសមនុស្ស២លាននាក់ តែពីរបីសប្តាហ៍ទេ។ ហើយយើងក៏មិនយល់ដែរថា ហេតុអ្វីក៏ពួកគេត្រូវការមួយឆ្នាំកន្លះនោះដើម្បីជម្លៀសមនុស្សដែលតិចជាងហ្នឹងដល់ទៅបួនដង។ អ៊ីចឹងខ្ញុំមើលទៅដូចជាគួរឲ្យភ្ញាក់ផ្អើលដែរ។ អ៊ីចឹងប្រហែលជាការជម្លៀសទាំងអស់នេះ -- ការជម្លៀសដំណាក់ទី២ នោះអាចថាចប់មុនហ្នឹងយូរទៀត ប្រហែលមុនឆ្នាំ១៩៧៥ផង -- មុនចុងឆ្នាំ១៩៧៥។ ដូច្នេះការអនុវត្តការជម្លៀសនេះមិនមានបញ្ហាអ្វីទេ ចំពោះលោក ខៀវ សំផន បើសិនជាព្រះរាជអាជ្ញានោះមិនចេះតែដូរទស្សនៈរបស់ខ្លួនទៅលើអង្គហេតុផ្សេងៗទៀត គាត់ចេះតែនិយាយថាកូនក្តីខ្ញុំមិនអាចមិនដឹងអំពីការផ្លាស់ទីនេះទេ ការអនុវត្តនៃការជម្លៀសនេះទេ។ អ៊ីចឹងគេទៅប្តូររហូតពីការយល់ឃើញរបស់គេ។ បាទ យើងនឹងនិយាយពីចំណុចនេះ។

[០៩:៣៨:៤២]

ទាក់ទងទៅនឹងអ្នក -- ជនរងគ្រោះនៃការជម្លៀសដំណាក់កាលលើកទី២នេះ យើងក៏មិនដឹងដែរ។ យើងដឹងហើយថានៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីនិយាយនោះ គឺថាលក្ខខណ្ឌទំនុងវាល្អជាងមុន ការជម្លៀសហ្នឹង ដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងយ៉ាងដូច្នេះ “យើងមិនបាច់ធ្វើការគណនា មិនគួរគប្បីត្រូវធ្វើទេ។ ឧទាហរណ៍ ដូចជាចែកចំនួនប្រជាជនដែលស្លាប់នៅទីក្រុងភ្នំពេញ គឺថាចែកនឹងបួន ព្រោះថាចំនួនទំនុងវាតិចជាងការជម្លៀសលើកទី១បួនដង ហើយបើថាជម្លៀសទៅល្អជាងហ្នឹងគឺកាត់ចែកតាមហ្នឹងទៅដឹងចំនួនប្រហាក់ប្រហែលហើយ”។ អ៊ីចឹងយើងនៅតែមិនដឹងដដែលចំនួនជនរងគ្រោះ អត់ទាន់មានការបង្ហាញណា ហើយយើងហ្នឹង គឺថាក៏មិនអាចយកតួលេខរបស់លោកសាស្ត្រាចារ្យ យៀរ និន ដែរ ព្រោះថាមិនអាចជឿបានទេ។

បាទ ឥឡូវនេះយើងនិយាយអំពីអ្វីដែលយើងស្ដាប់ឮពីសហព្រះរាជអាជ្ញាប៉ុន្មានថ្ងៃចុងក្រោយនេះម្ដង។ យើងនឹងឃើញថា នៅក្នុងផ្នែកសំខាន់ពីរនៃការជម្រះសេចក្ដីនេះគឺថា សហព្រះរាជអាជ្ញាបានសុំឲ្យអស់លោក លោកស្រីចៅក្រមផ្អែកលើអង្គហេតុដែលក្រៅវិសាលភាពនៃការជម្រះសេចក្ដីយើងនេះ ដើម្បីចេញសេចក្ដីសម្រេចប្រកាសពិរុទ្ធភាព ហើយនិងកាត់ទោសលោក ខៀវ សំផន ឲ្យជាប់គុក មួយជីវិត។ គាត់ក៏បានធ្វើផងដែរ ដើម្បីឲ្យការកំណត់ប្រភេទបទល្មើសសហឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ប្រឆាំងនឹងមនុស្សជាតិ ដើម្បីឲ្យតម្កល់ទុកនៃទម្រង់នៃទំនួលខុសត្រូវនេះ ដើម្បីកាត់ទោសលោក ខៀវ សំផន ឲ្យខានតែបាន។

[០៩:៤០:៤០]

ឥឡូវចំពោះសាធារណជនដែលមិនមែនជាច្បាប់ ដែលកំពុងស្ដាប់យើងនោះ គឺខ្ញុំសូមបញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាឧក្រិដ្ឋកម្មនៃច្បាប់រួម ដែលមានឧក្រិដ្ឋកម្មជាក់លាក់ដែលបង្ហាញ -- ដែលភាពមានលក្ខណៈពិសេស ដែលថាបានប្រព្រឹត្តទៅក្នុងបរិបទជាក់លាក់មួយ។ ហើយនៅចំពោះមុខតុលាការនេះ ដើម្បីយើងអាចកំណត់ថា ឧក្រិដ្ឋកម្មជាក់លាក់នេះស្ថិតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មជាមូលដ្ឋាន ត្រូវតែបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាលក្ខណៈជាប្រព័ន្ធ ហើយជាទូទៅប្រឆាំងនឹងប្រជាជនស៊ីវិលនៅក្នុងបរិបទរើសអើង។ ហើយបញ្ហានេះហើយដែលព្រះរាជអាជ្ញា ចំណុចនេះព្រះរាជអាជ្ញាបានវិភាគនៅកថាខណ្ឌ៦៤៧ និង៥៥២ នៅក្នុងសារណារបស់ខ្លួន។ គេនិយាយអ្វី? ព្រះរាជអជ្ញានិយាយអីខ្លះនៅក្នុងសារណានេះ? គេនិយាយថា “ការវាយប្រហារនេះ គឺថា

ទាក់ទងទៅនឹងការជម្លៀសលើកទី១ លើកទី២ ហើយនៅទួលពោធិ៍ជ្រៃ"។ បាទ សហព្រះរាជអាជ្ញាបាននិយាយថា "ការវាយប្រហារនេះ មានការធ្វើឲ្យក្លាយទៅជាទាសករនូវប្រជាជនទាំងអស់នៅក្នុងការដ្ឋាននៅតាមសហករណ៍ ហើយនិងនៅក្នុងការដ្ឋានធ្វើការ។ ហើយមនុស្សរាប់ម៉ឺននាក់ត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម ហើយសម្លាប់ចោលនៅក្នុងគុកទាំងអស់នេះ និងនៅក្នុងកន្លែងផ្សេងទៀត។ ឧទាហរណ៍ដូចជា ទីតាំងសម្លាប់មនុស្សធំៗ ហើយរហូតទៅដល់មានមនុស្ស៨០០.០០០ ទៅដល់ ១,៣លាននាក់ដែលបានស្លាប់"។ សូមបញ្ចប់ការដកស្រង់។

[០៩:៤២:៥២]

នៅកថាខណ្ឌបន្ទាប់មកទៀត សហព្រះរាជអាជ្ញាសរសេរថា "ការវាយប្រហារនេះដែលពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៃការផ្លាស់ប្តូរឧក្រិដ្ឋកម្មជាក់លាក់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ គឺថាប្រព្រឹត្តទៅរយៈពេល៣ឆ្នាំ និង៨ខែ។ ហើយការវាយប្រហារនោះសំដៅទៅលើប្រជាជន៨លាននាក់"។

នៅកថាខណ្ឌបន្ទាប់មកទៀត សហព្រះរាជអាជ្ញាសរសេរថា ក្នុងចំណោមអំពើហិង្សាដែលបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារនេះ យើងអាចរៀបរាប់បានថា ខ្ញុំសូមដកស្រង់, នេះជាការបកប្រែក្រៅផ្លូវការនៅក្នុងអង្គភាពរបស់យើង, ៖"ការសម្លាប់សត្រូវពិតប្រាកដ ឬស្រមើស្រមៃ ការអនុម័តយកវិធានការជាក់លាក់ធ្វើទុក្ខបុកម្នេញ និងវិធានការរើសអើងចំពោះជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន ការធ្វើឲ្យក្លាយទៅជាទាសករ ការបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ ហើយនិងការបង្ខំឲ្យរួមភេទ" សូមបញ្ចប់ការដកស្រង់។ នេះគឺពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ឥឡូវនេះ ខ្ញុំចូលទៅដល់ផ្នែកសំអាងហេតុរបស់ព្រះរាជអាជ្ញា គឺពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួម។ ចំពោះសាធារណជនដែលមិនមែនជាអ្នកច្បាប់ ដែលកំពុងតែស្តាប់យើងនោះ ខ្ញុំមិនដឹងថាតើយើងមានមេធាវីក្មេងៗអត់នៅទីនេះទេ។ ចំពោះអ្នកមិនមែនអ្នកច្បាប់នោះ គឺថាសហឧក្រិដ្ឋកម្មរួមគឺជាអង្គហេតុមួយ ដែលថាយ៉ាងហោចណាស់ត្រូវមានមនុស្សពីរនាក់ត្រូវរ៉ូវក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយដែលអាចត្រូវបានជំនុំជម្រះដោយតុលាការនេះ។

[០៩:៤៤:៣៥]

ដូច្នេះ សហឧក្រិដ្ឋកម្មរួមមិនមែនជាឧក្រិដ្ឋកម្មទេ គឺជារបៀបនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម។ នេះដែលយើងហៅថាជារបៀបនៃការទទួលខុសត្រូវ។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញា គាត់បានធ្វើអ្វីខ្លះ? នៅក្នុងផ្នែកនៃសារណារបស់គាត់ពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួមនោះ គឺថានៅកថាខណ្ឌ៦៧៧ ដល់៦៩៨នោះ គឺ

ថាគាត់ធ្វើដដែលៗ ធ្វើដូចគ្នា ដូចអ្វីដែលគាត់បានធ្វើ ដូចនៅក្នុងកថាខណ្ឌដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ គឺថាមានន័យថា គាត់ផ្អែកនៃទឡ្ហីករណ៍របស់គាត់ទៅលើការចោទប្រកាន់ដែលថាលោក ខៀវ សំផន ទំនងជាបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដែលមានគោលដៅក្នុងការដាក់ប្រជាជនទាំងអស់ឲ្យក្លាយទៅជាទាសករនៅក្នុងចន្លោះឆ្នាំ៧៥ ដល់ឆ្នាំ៧៩។

នេះមិនមែនជារឿងថៃដន្យទេ គឺសហព្រះរាជអាជ្ញាគាត់ទើបតែនឹងបង្ហាញនូវទឡ្ហីករណ៍ ឬក៏អំណះអំណាងថ្មីពាក់ព័ន្ធទៅនឹងប្រភេទនៃសហឧក្រិដ្ឋកម្មរួមដែលអាចត្រូវបានទទួលយកនៅក្នុងរឿងក្ដីនេះ។ តាំងពីពេលដាក់សារណានៅខែកញ្ញា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាអះអាងថា គឺទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួមដែលត្រូវបានអនុវត្តជាគោលនៅទីនេះ។ រហូតមកដល់ពេលនេះ សហព្រះរាជអាជ្ញាអះអាងថា គឺជាការអនុវត្តសហឧក្រិដ្ឋកម្មរួមក្នុងទម្រង់បឋមដែលត្រូវអនុវត្តនៅទីនេះ។ ដូចអ្នកច្បាប់នៅទីនេះដឹងហើយ នេះគឺជារបៀបមួយនៃការបង្ហាញអំពីយុទ្ធវិធី យុទ្ធសាស្ត្ររបស់សហព្រះរាជអាជ្ញាដើម្បីបង្ហាញឲ្យឃើញអំពីការបន្ធូរលក្ខខណ្ឌនៃការតម្រូវពាក់ព័ន្ធទៅនឹងភស្តុតាង ហើយខ្ញុំនឹងបង្ហាញអំពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនៅក្នុងរឿងក្ដី ឌុច។

[០៩:៤៦:៤២]

ឌុច ដែលជាអ្នកគ្រប់គ្រងជំរំមួយ គឺអ្នកគ្រប់គ្រងមន្ទីរស-២១។ ហើយនៅក្នុងកថាខណ្ឌ៥០៩ នៃសាលក្រម ឌុច ដែលគាត់ត្រូវបានកាត់ទោសតាមរយៈទម្រង់ជាប្រព័ន្ធ។ អង្គជំនុំជម្រះបានសរសេរថាចំពោះទម្រង់បឋម ចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មជាក់លាក់ត្រូវតែធ្វើឡើងដោយសហចារីទាំងអស់។ ចំណែកឯសហឧក្រិដ្ឋកម្មរួមប្រភេទឧក្រិដ្ឋជាប្រព័ន្ធនោះ គឺថាត្រូវបង្ហាញឲ្យឃើញថាជនជាប់ចោទបានដឹងដោយផ្ទាល់អំពីការប្រព្រឹត្ត ការធ្វើបាបនេះ ហើយខ្លួនមានចេតនាក្នុងការចូលរួមនៅក្នុងដំណើរការនៃប្រព័ន្ធនេះ។ ហេតុនេះហើយបានជាអស់រយៈប៉ុន្មានថ្ងៃមកនេះ សហព្រះរាជអាជ្ញាអះអាងថា កម្ពុជាទាំងមូលបានក្លាយទៅជាទម្រង់ប្រមូលផ្ដុំ គឺថាប្រៀបបានទៅនឹងប្រទេសទាសករ។ ហេតុអីបានជាគាត់លើកឡើងបែបនេះ ទោះបីជាគាត់រំលោភទៅនឹងសេចក្ដីសម្រេចនៃការបំបែកនីតិវិធីក៏ដោយ ដែលគាត់និយាយថា គោលនយោបាយទាំងអស់ដែលចែងនៅក្នុងដីកាដំណោះស្រាយឆ្នាំ២០១០នោះ ត្រូវបានអនុវត្ត ហើយត្រូវបានសម្រេចទៀតផង។

លោក លោកស្រីចៅក្រមមិនច្រឡំទេ សហព្រះរាជអាជ្ញាមិនបានលើកឡើងអំពីអត្ថិភាពនៃគោលនយោបាយទាំងអស់នោះទេ។ គាត់លើកឡើងអំពីការអនុវត្តគោលនយោបាយ ប្រសិនបើគោល

នយោបាយទាំងអស់នេះមិនមែនជាកម្មវត្ថុនៃការជំនុំជម្រះក្ដីយើងនេះ មានតែនៅក្នុងឯកសាររបស់ខ្មែរក្រហម។ ហើយវាមិនមែនជារឿងចៃដន្យទេ ប្រសិនបើមិនអនុវត្តនោះ គឺថាវាមិនអាចបង្កើតជាឥទ្ធិពលគតិយុត្តិដែលអាចឲ្យយើងកាត់ក្ដីនៅថ្ងៃនេះបានទេ បើសិនជាមិនមានការអនុវត្ត ហើយមានត្រឹមតែអនុភាពនោះ។ ហើយសហព្រះរាជអាជ្ញាមិនបានបង្ហាញឲ្យឃើញបែបនេះទេ។ គាត់លើកឡើងតែអំពីការអនុវត្ត ដើម្បីឲ្យកម្ពុជាក្លាយទៅជារដ្ឋទាសករនោះ សហព្រះរាជអាជ្ញាត្រូវតែបង្ហាញភស្តុតាងថាវាល់គោលនយោបាយទាំងអស់ដែលមានចែងនៅក្នុងដីកាដំណោះស្រាយ មានគោលដៅមួយគឺថាធ្វើយ៉ាងម៉េចសម្រេចឲ្យបានលទ្ធផល ហើយត្រូវបានអនុវត្តយ៉ាងជាក់លាក់។ ឧទាហរណ៍ដូចជាការជម្លៀសប្រជាជន សហករណ៍ ការដ្ឋានការងារ ការអប់រំ សមាសភាពថ្មី ការសម្លាប់ខ្មាំងទាំងក្នុង និងក្រៅជួរបក្ស។ ការសំដៅទៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ ចាម ពុទ្ធសាសនិកវៀតណាម ហើយនិងគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍ជាដើម។

[០៩:៤៩:៣១]

ដូច្នេះ សំណួរទី១របស់ខ្ញុំ គឺថាអ្វីដែលសហព្រះរាជអាជ្ញានិយាយនៅក្នុងផ្នែកទាំងពីរនៃសារណារបស់ខ្លួនដែលខ្ញុំទើបតែរៀបរាប់នេះ ថាជាអង្គហេតុយោងទៅតាមមាត្រា៩៨(២) នៃវិធានផ្ទៃក្នុងដែលចែងថា៖ “អង្គជំនុំជម្រះអាចជំនុំជម្រះតែទៅលើអង្គហេតុដែលមានចែងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែប៉ុណ្ណោះ” សូមបញ្ចប់ការដកស្រង់។ បាទ ចម្លើយគឺថាពិតណាស់ ពីព្រោះថាការដាក់ឲ្យប្រជាជន ៦ ទៅ៨លាន ហើយទៅទាសករ បញ្ជូនមនុស្សទៅតាមសហករណ៍ឲ្យទៅធ្វើការ ធ្វើទារុណកម្មដាក់មន្ទីរ ដាក់ឃុំឃាំង សម្លាប់ចោលនៅក្នុងគុក នៅក្នុងតាមកន្លែងផ្សេងៗហ្នឹង ទាំងអស់ហ្នឹងសុទ្ធតែជាអង្គហេតុ។ នៅពេលដែលសហព្រះរាជអាជ្ញានិយាយអំពីការវាយប្រហារ ពួកគាត់អះអាងថាការវាយប្រហារទាំងអស់នេះបានប្រព្រឹត្តទៅមែន។ នៅពេលដែលនិយាយអំពីគោលនយោបាយគាត់អះអាងថាគោលនយោបាយទាំងអស់នេះពិតជាបានអនុវត្តមែន។ នេះគឺជាអង្គហេតុវាមិនអាចជៀសវាងបានទេ។

[០៩:៥០:៤៦]

ដូច្នេះ សំណួរទី២របស់ខ្ញុំគឺថា តើអង្គជំនុំជម្រះត្រូវបានប្ដឹងឲ្យកាត់សេចក្ដីអំពីការជម្លៀសប្រជាជនដំណាក់កាលទី៣ អំពីអ្វីដែលបានកើតឡើងនៅក្នុងសហករណ៍ និងអ្វីដែលកើតឡើងនៅក្នុងការដ្ឋានការងារ អ្វីដែលកើតឡើងនៅក្នុងមន្ទីរឃុំឃាំង អ្វីដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃនៅក្រោយខែមេសា ឆ្នាំ១៩៧៥ ពីអ្វីដែលបានកើតឡើងនៅក្នុងកន្លែងសម្លាប់មនុស្សផ្សេងទៀត ហើយតើមានការប្ដឹង

ឲ្យកាត់ក្តីអំពីការ -- អំពីវិធានការរើសអើងប្រឆាំងនឹងជនជាតិចាម ប្រឆាំងនឹងពុទ្ធសាសនិកជន ប្រឆាំងនឹងជនជាតិវៀតណាម ប្រឆាំងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែរឬទេ?

**ប្រធានអង្គជំនុំ៖**

ឲ្យយឺតបន្តិចបកប្រែអត់ទាន់ទេ!

[០៩:៥១:២៧]

**លោក អាកទូរ វែកគែន៖**

សូមអរគុណលោកប្រធានដែលរំឭកឲ្យនិយាយយឺតៗ។ ខ្ញុំនឹងនិយាយយឺតៗតាមការកំណត់របស់អង្គជំនុំជម្រះ។

ដូច្នេះសំណួរទី២របស់ខ្ញុំនោះ ខ្ញុំចង់ដឹងថាតើអង្គជំនុំជម្រះត្រូវបានប្តឹងអំពីអ្វីដែលសហព្រះរាជអាជ្ញាដែលបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួន ហើយនិងក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួនដើម្បីទាមទារឲ្យមានការកាត់ទោសខ្ពស់បំផុតនោះ គឺពាក់ព័ន្ធទៅនឹងអ្វីដែលបានប្រព្រឹត្តឡើងនៅក្នុងសហករណ៍ ប្រព្រឹត្តឡើងនៅជំរំការងារ នៅក្នុងគុក គឺអត់មានទេ។ អង្គជំនុំជម្រះមិនបានទទួលការប្តឹងឲ្យមានការជំនុំជម្រះទាំងអស់នេះទេ ព្រោះថាមានការបែងចែកច្បាស់ណាស់នៅក្នុងដីកាសម្រេចបំបែកនីតិវិធីនោះ។ អង្គជំនុំជម្រះជាអ្នកសម្រេចបំបែកដោយខ្លួនឯងគ្មានអ្នកណាសុំទេ ហើយខ្ញុំខ្លួនឯងផ្ទាល់ហ្នឹងក៏មិនបានដឹងមុនផង។ ដូច្នេះអម្បាញ់មិញនេះ យើងបានមើលឃើញច្បាស់ហើយនៅពេលដែលខ្ញុំអាននោះ វាមានលក្ខណៈចាំបាច់អំពីបញ្ជីស្លាកររបស់អង្គជំនុំជម្រះដែលកំណត់វិសាលភាពនៃការជំនុំជម្រះក្តីនេះ ហើយអង្គហេតុទាំងអស់នេះ ត្រូវបានដកចេញពីការជំនុំជម្រះ។ ហើយអត្ថបទច្បាប់ទាំងអស់ដែលពាក់ព័ន្ធទៅនឹងអង្គហេតុទាំងអស់នេះ ក៏ត្រូវតែច្រានចោលដែរ។

[០៩:៥២:៥៩]

ឧទាហរណ៍ សំណួរទី៣៖ តើអង្គជំនុំជម្រះត្រូវបានប្តឹងឲ្យកាត់ក្តីអំពីការដាក់ឲ្យក្លាយទៅជាទាសករដែរឬទេ? គឺសហព្រះរាជអាជ្ញាបានលើកឡើងថា ប្រទេសទាំងមូលក្លាយទៅជារដ្ឋទាសករ។ គឺអត់មានទេ អត់មានការប្តឹងឲ្យអង្គជំនុំជម្រះកាត់ក្តីពីរឿងហ្នឹងទេ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនេះគឺថាត្រូវបានដកចេញដោយការសម្រេចរបស់អង្គជំនុំជម្រះតាមរយៈការជ្រើសរើសកថាខណ្ឌនៃដីកាដំណោះស្រាយនៅក្នុងកថាខណ្ឌ១៦១៣ ហើយក៏មិនមានការពិភាក្សាគ្នាអំពីបញ្ហានេះដែរ។

សំណួរបន្ទាប់មកទៀត ដូចជាឆោតល្ងង់បន្តិចហើយ ក៏ប៉ុន្តែខ្ញុំត្រូវតែសួរ។ អង្គហេតុដែលប្តឹង

នោះ គឺថានាំឱ្យមានការស្លាប់មនុស្សដល់ ៨០០.០០០ ទៅដល់ ១,៣លាននាក់នោះ? អត់ទេ។ យើងទើបតែមើលឃើញហើយថា តួលេខអតិបរមានៃមនុស្សស្លាប់នោះ គឺថាមានចន្លោះប្រហែលជា២.២០០នាក់ទៅដល់ប្រហែលជា ៥.០០០នាក់តែប៉ុណ្ណោះ។ ដូច្នេះ សហព្រះរាជអាជ្ញាគាត់និយាយអំពីអ្វី? ហេតុអីបានជាគាត់ហ៊ាននិយាយថា មានមនុស្សស្លាប់ ១,៣លាននាក់ នៅក្នុងការជំនុំជម្រះក្ដីយើងនេះ។ ដោយសារយើងមើលឃើញហើយតួលេខដែលមានការចោទប្រកាន់ខ្ពស់បំផុតនោះ គឺមិនលើសពី ៥.០០០នាក់នោះទេ។ តើមានរឿងអ្វីកើតឡើងនៅទីនេះ។ ខាងសហព្រះរាជអាជ្ញានោះ គាត់និយាយ គាត់និយាយអំពីអី? ហើយបន្ទាប់មកទៀតអង្គហេតុដែលត្រូវបានប្ដឹងនោះ តើមានរយៈពេល៣ឆ្នាំ ៨ខែ ដែរឬទេ? អត់ទេ។

[០៩:៥៤:៣៨]

ខ្ញុំបានរៀបរាប់ហើយអម្បាញ់មិញនេះ ពាក់ព័ន្ធទៅនឹងការកំណត់អំពីការជម្លៀសទី១ ទី២ហើយនិងទួលពោធិ៍ជ្រៃនោះ។ យើងប្រសិនបើយើងកំណត់ឱ្យបានច្បាស់នោះ គឺថាយើងមានពីចន្លោះពីខែមេសា ឆ្នាំ៧៥ ទៅដល់ខែធ្នូ ឆ្នាំ១៩៧៦ គឺតែមួយឆ្នាំ ប្រាំបីខែ តែប៉ុណ្ណោះ។ ខាងសហព្រះរាជអាជ្ញាខ្ញុំចង់ឱ្យយើងយល់អំពីវិធាន ដែលពាក់ព័ន្ធទៅនឹងការប្ដឹងតុលាការព្រហ្មទណ្ឌ ហើយដែលបង្ហាញថា ៩០ភាគរយនៃអ្វីដែលអស់លោក លោកស្រីស្ដាប់ឮសហព្រះរាជអាជ្ញាដែលគាត់ស្ដាប់ឮប្រឆាំងនឹងជនជាប់ចោទនោះគឺថាវាចាកប្រធានទាំងស្រុង សាធារណជនស្ដាប់ឮហើយ។ វិធានទាំងអស់នោះគឺ បើយើងមើលទៅគឺកម្មវិធីរៀនច្បាប់ឆ្នាំទី១ហ្នឹង គឺថាជាកម្មវិធីមូលដ្ឋាន អ្នកណាក៏ចេះដែរ។ ហើយបើសិនជាយើងអត់អនុវត្តវិធានបែបហ្នឹងទេ គឺថាអត់មានការជំនុំជម្រះក្ដីដោយយុត្តិធម៌ទេ គឺថាវាមិនអាចទៅរួចទេ ដូច្នេះខ្ញុំចោទសំណួរនេះមកកាន់ខ្លួនឯងហ្នឹង។ តើយើងជ្រើសរើសមនុស្សខុសទេនៅពេលដែលយើងជ្រើសរើសខាងសហព្រះរាជអាជ្ញាឱ្យមកធ្វើការនោះ។ ដូចប្រហែលជាគេអាចច្រឡំជ្រើសរើសអ្នកទេសចរណ៍ដែលគ្រាន់តែមកធ្វើវ៉ាកងនៅនេះ ដែលដើរលេងតាមសង្កាត់នៅមាត់ទន្លេ ហើយដែលសប្បាយចិត្តក្នុងការបន្តការស្នាក់នៅរបស់ខ្លួននៅកម្ពុជា ដោយគ្រាន់តែចំណាយលុយប៉ុន្មានដុល្លារ។

[០៩:៥៦:៣៦]

ហើយខ្ញុំនៅចងចាំថា ខាងសហព្រះរាជអាជ្ញាភាគច្រើននោះមកពីប្រព័ន្ធអង់គ្លូសាក់សុង គឺអស់លោកគឺសុទ្ធតែជាមេធាវីទេ ហើយក្លែងខ្លួនធ្វើជាសហព្រះរាជអាជ្ញា។ ដូច្នេះ ខ្ញុំអាចនិយាយថា អស់លោកអាចរៀបរាប់អីក៏បានដែរ ដើម្បីឱ្យថាឈ្នះក្ដីនោះ។

តាមពិតទៅអ្វីដែលបានកើតឡើងនៅទីនេះគឺថា អស់លោកសហព្រះរាជអាជ្ញា ទោះបីជាមេរបស់លោករត់ចោលៗបាត់ទៅហើយនោះ ក៏លោកកំពុងតែបំពេញបេសកកម្មកុម្ម៉ង់ដូ គឺជាបេសកកម្មដែលធ្វើយ៉ាងណាឲ្យតែមានការកាត់ទោសជនជាប់ចោទឲ្យទាល់តែបាន។ អស់លោកជឿថាពិភពលោកទាំងមូលកំពុងតែមើលអស់លោក ហើយនៅពេលដែលបន្ទប់ គឺថាអត់មានមនុស្សគឺមានន័យថា យើងកំពុងតែធ្វើការនៅមុខកំព្យូទ័រ។ លោកជឿថា ភារកិច្ចរបស់អស់លោកនោះគឺថាធំជាងច្បាប់ធំជាងវិធានទៅទៀត។ អស់លោក លោកស្រីសហព្រះរាជអាជ្ញាយល់ខុសហើយ។

[០៩:៥៧:៥៩]

**ប្រធានអង្គជំនុំ៖**

មេធាវីគប្បីមានការប្រុងប្រយ័ត្នក្នុងការបញ្ចេញនូវសម្ដីនិងអាកប្បកិរិយារបស់ខ្លួន។ អង្គជំនុំជម្រះយល់ថា គប្បីត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ អង្គជំនុំជម្រះសង្ឃឹមថា លោកមេធាវីមិនធ្វើឲ្យប៉ះពាល់ដល់ភាគីដទៃទៀតនៃរឿងក្ដីនេះទេ ពីព្រោះនោះជារឿងបុគ្គលភាពដែលមិនទំនងជាលើកឡើងធ្វើឲ្យប៉ះពាល់ដោយពាក្យសម្ដី ឬដោយអាកប្បកិរិយានោះឡើយ។

*(សម្រាករយៈពេលខ្លី)*

**លោក អាកទូរ វែកគែន៖**

បាទ លោកប្រធាន ខ្ញុំនឹងប្រយ័ត្នប្រយែង។ ដូច្នេះខ្ញុំនិយាយថា ក្រោមឆ័ត្រនៃបេសកកម្មកុម្ម៉ង់ដូនោះ អស់លោកនោះគឺថាអាចនឹងសើចចំអកទៅលើប្រព័ន្ធច្បាប់ លោកប៉ាន់ធ្វើឲ្យបរាជ័យនូវបេសក-កម្មរបស់លោក គឺថាចូលរួមនៅក្នុងបង្កើតប្រព័ន្ធតុលាការរឹងមាំ និងមានយុត្តិធម៌។ លោកប៉ានប្រថុយក្នុងប្រឆាំងទៅនឹងផលប្រយោជន៍ទូទៅរបស់សាធារណៈដែលលោក អស់លោកតំណាង ហើយនិងការពារនោះ។ នៅពេលដែលអស់លោកលើកឡើងអំពីអង្គហេតុដែលមិនពាក់ព័ន្ធទៅនឹងកម្មវត្ថុនៃការជំនុំជម្រះក្ដីយើងនេះ ហើយដែលការកំណត់ប្រភេទបទល្មើស -- ប្រភេទនៃបទល្មើសដែលអាចធ្វើឡើងបាននេះ ពីព្រោះថាអត្ថបទដែលពាក់ព័ន្ធត្រូវបានច្រានចោលអស់រួចទៅហើយ ដែលមិនអាចយកមកដាក់ចូលមកវិញបានទៀតនោះទេ។ គឺអស់លោកប៉ានប្រថុយក្នុងការផ្ដល់ឧទាហរណ៍អាក្រក់ដល់ប្រជាជនកម្ពុជា ដែលបានឆ្លងកាត់នូវការលំបាក ហើយនិងទៅដល់ប្រទេសផ្សេងៗនៅលើពិភពលោក ដែលបានផ្ដល់ភារកិច្ចឲ្យលោកការពារយុត្តិធម៌ ទោះបីជាមានលទ្ធផលយ៉ាងណាក៏ដោយនោះ។

[១០:០០:២៥]

ការកាត់ទោស ឬក៏ការដោះលែងនោះ ប្រសិនបើយើងផ្តោតតែលើការផ្តន្ទាទោសនោះ គឺឈប់បណ្តោយទៅ មិនបាច់កាត់ក្តីកាត់អីទេ គ្មានប្រយោជន៍ទេបើគិតតែពីធ្វើយ៉ាងម៉េចឲ្យបានផ្តន្ទាទោសជនជាប់ចោទនោះ។ គឺថាអស់លោកសហព្រះរាជអាជ្ញាហ្នឹងប្រថុយ ក្នុងការធ្វើម៉េចឲ្យតែបានកាត់ទោសជនជាប់ចោទ។

ដូច្នេះ នៅពេលដែលយើងនិយាយទាំងអស់នេះ គឺថាយើងនិយាយអំពីការប្រថុយប្រថានរបស់សហព្រះរាជអាជ្ញា។ ចំពោះខ្ញុំផ្ទាល់នោះ ខ្ញុំមានការសង្ស័យរយៈពេលខ្លីទេ នៅពេលដែលមើលសំណើរបស់សហព្រះរាជអាជ្ញាដែលបានដាក់នៅខែ -- នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ គឺឯកសារ E284/5 គឺជាសំណើដែលអង្គជំនុំជម្រះមិនបានបញ្ជូនមកឲ្យពួកយើងទេ ប្រហែលជាអង្គជំនុំជម្រះភ្លេចមើលទៅ ហើយសំណើហ្នឹងក៏យើងមិនអាចឆ្លើយតបបានដែរ។ ហើយយើងបានឃើញសំណើនេះ នៅពេលដែលអង្គជំនុំជម្រះខ្លួនឯងទេជាអ្នកឆ្លើយតបនោះ។ នៅក្នុងសំណើនេះ សហព្រះរាជអាជ្ញាបានសុំឲ្យចៅក្រមខ្ញុំសូមដកស្រង់ -- នេះជាការបកប្រែផ្ទាល់ខ្លួនរបស់ខ្ញុំ -- "គឺថាកុំឲ្យអង្គជំនុំជម្រះទាញសេចក្តីសន្និដ្ឋានអង្គហេតុ ឬអង្គច្បាប់នៃអង្គហេតុទាំងអស់ដែលមិនស្ថិតនៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានជ្រើសរើសសម្រាប់ការជំនុំជម្រះក្តីយើងនេះ"។

អស់លោកថែមទាំងសរសេរទៀតផងដែរថា៖ "អង្គហេតុនៅក្រៅវិសាលភាពមិនត្រូវគិតគូរទេ ពីព្រោះថាមេធាវីការពារក្តីមិនមានឱកាសក្នុងការសួរដេញដោលទៅលើសាក្សីពាក់ព័ន្ធទៅនឹងអង្គហេតុទាំងអស់នេះទេ" សូមបញ្ចប់ការដកស្រង់។ សូមអរគុណហើយសហព្រះរាជអាជ្ញាដែលបានលើកឡើងបែបនេះនោះ។

[១០:០២:៣៥]

ពិតណាស់យើងបានលើកឡើងហើយថា អស់លោក លោកស្រីព្យាយាមបញ្ចូលទៅក្នុងវិសាលភាពនូវធាតុផ្សំអង្គហេតុ និងអង្គច្បាប់ ដែលបានបញ្ចប់រួចទៅហើយនោះ។ នេះយោងតាមខ្លឹមសារនៃសារណាចុងក្រោយ ហើយនិងសេចក្តីសន្និដ្ឋានផ្ទាល់មាត់ចុងក្រោយប៉ុន្មានថ្ងៃចុងក្រោយនោះ ខ្ញុំអាចសន្និដ្ឋានបានថា នេះគឺជាការដឹងខ្លួន ការភ្ញាក់រឭករបស់លោក លោកស្រីសហព្រះរាជអាជ្ញា។ ពីព្រោះថាមកដល់ថ្ងៃនេះ គឺថាៗយើងចូលមកដល់រឿងអង្គសេចក្តី យើងដល់ -- បាទខ្ញុំឃើញថារហូតដល់ពេលនេះ ថាវាអាក្រក់បំផុត គឺប្រើវោហាសាស្ត្រ ដែលលោកស្រី ជា លាង បានប្រើនោះ មុនពេលសុំឲ្យកាត់ទោសជាប់គុកមួយជីវិតនោះ។

ខ្ញុំសូមនិយាយអំពីរបៀបនិយាយថា យើងមិនសុំឲ្យតុលាការនេះហែកជើងកូន -- លោក ខៀវ សំផន នៅចំពោះមុខគាត់ទេ យើងមិនសុំឲ្យតុលាការនេះដាក់គាត់ឲ្យក្លាយជាទាសករទេ។ យើងមិនសុំឲ្យតុលាការនេះបោះគាត់នៅលើផ្លូវ ហើយមិនឲ្យផឹកទឹក មិនឲ្យហូបអាហារអីនោះទេ។ ពាក្យសម្ដីទាំងអស់នេះ គឺថាវាជារោគសញ្ញានៃចេតនាមួយ។ ចំពោះព្រះរាជអាជ្ញាមិនមែនចង់បង្ហាញពីថាខ្លួនពូកែខាងអក្សរសាស្ត្រអីទេ ក៏ប៉ុន្តែគឺជាការចង់និយាយថាលោក ខៀវ សំផន គឺជាបិសាច ដែលពុំមានសិទ្ធិការជំនុំជម្រះមួយទេ គឺថាលោក ខៀវ សំផន នោះគួរតែសប្បាយចិត្តទៅ គេមិនហែកដៃហែកជើងរបស់កូនរបស់ខ្លួននោះ គេមិនបង្អត់អាហារខ្លួននោះ។ អ៊ីចឹង នៅក្នុងការនិយាយពីដើមនៅមុខតុលាការយើងនេះ លោក ហ្សាក់ វែកហ្សេស បាននិយាយអំពីភាពអនុគ្រោះ គឺថាអ្វីដែលជ្រុលនោះគ្មានប្រយោជន៍ទេ។ អ៊ីចឹង គឺថាការលើកឡើងរបស់លោកស្រីសហព្រះរាជអាជ្ញានេះជ្រុលណាស់ ក៏ប៉ុន្តែមិនមែនអត់មានប្រយោជន៍ទេ ពីព្រោះថាមានគំនិតក្រោយ នៅក្នុងគំនិតគាត់ គាត់ចង់សុំឲ្យកាត់ទោសប្រហារជីវិត។

[១០:០៥:១៣]

អស់លោក លោកស្រីចៅក្រម ខ្លឹមសារជាក់លាក់ហ្នឹង គឺថាការ-- លោក ខៀវ សំផន ដែលត្រូវតែចាត់ទុកថាគាត់មិនមានពិរុទ្ធភាពនោះ ត្រូវចាត់ទុកថាគាត់ជាបិសាច។ អ៊ីចឹងមិនបាច់គិតពីច្បាប់ ពីអ្វីអីទេ។ ច្បាប់ដែលបង្កើតឲ្យមានចៅក្រមនេះមិនបាច់គិតទេ។ អស់លោក លោកស្រីចៅក្រម ខ្ញុំសូមរំឭកថា នៅពេលដែលសង្គមមនុស្សមួយដែលមានអរិយធម៌ ប្រថុយថាននឹងផ្ដល់ ប្រគល់សិទ្ធិដល់មនុស្សម្នាក់ទៅកាត់សេចក្ដីដល់មនុស្សម្នាក់ទៀតចំពោះអំពើដ៏ធ្ងន់ធ្ងរ សង្គមនោះក៏មានប្រព័ន្ធការពារមួយដែរ។ ទី១ ការប្រុងប្រយ័ត្នដែរ។ ដំបូងគឺថាយើងរើសចៅក្រមទៅតាមចំណេះរបស់ខ្លួន ចំណេះដឹងផ្នែកច្បាប់ ហើយអំពីសីលធម៌របស់គាត់ អំពីវិជ្ជាជីវៈរបស់គាត់។ ហើយដូចដែលសហភាតារបស់ខ្ញុំ លោក កូប៉េ បាននិយាយថាហ្នឹង គឺគេមិនទុកឲ្យចៅក្រមនៅតែឯងទេ។ អស់លោក លោកស្រីចៅក្រមមានប្រាំរូបដែលត្រូវធ្វើការសម្រេចសេចក្ដីនេះ។ ហើយក្រុមទាំងប្រាំនេះ ជាប្រព័ន្ធការពារប្រឆាំងនឹងការប្រើអំណាចហួសហេតុ ហើយក៏មានច្បាប់ដែលអស់លោក លោកស្រីចៅក្រមត្រូវតែគោរពផងដែរ ដែលអស់លោក លោកស្រីចៅក្រមមិនអាចមើលរំលងបានទេ។ អស់លោក លោកស្រីចៅក្រមជាប់កាតព្វកិច្ចដើម្បីធ្វើបំពេញការងារដ៏មហាធំធេងនេះ ដែលលំបាកនេះ ដែលត្រូវកាត់សេចក្ដីលើព្រឹត្តិការណ៍ដែលគេចោទប្រកាន់ព្រឹត្តិការណ៍ដ៏ធ្ងន់ធ្ងរ គឺថាត្រូវជៀសវាងអំពី ជៀងវាងសំណើដែលសហព្រះរាជអាជ្ញាស្នើនេះ។ វិធានទាំងអស់នេះខ្លាំងជាងចៅក្រម ហើយសំខាន់ជាងចៅក្រមទៅទៀត។

[១០:០៧:១៧]

អស់លោក លោកស្រីចៅក្រម មិនមានបេសកម្មក្នុងការកែប្រែវិធានទាំងអស់នេះទេ ព្រោះវាដូចជារដ្ឋាភិបាលមួយគ្របដណ្ដប់លើអស់លោក លោកស្រីចៅក្រមអ៊ីចឹង។ អ្វីដែលព្រះរាជអាជ្ញាបានស្នើសុំនេះគឺថា គឺជាការស្នើសុំឲ្យអស់លោក លោកស្រីចៅក្រមធ្វើរដ្ឋប្រហារអ៊ីចឹង។ ពួកគេសុំឲ្យអស់លោក លោកស្រីចៅក្រមគិតថាវិធានសង្គមមនុស្សនេះ មិនសំខាន់ទេ។ ពួកគេសុំឲ្យលោក លោកស្រីចៅក្រម មិនបាច់គិតពីវិធានទាំងអស់នេះទេ។ គោលបំណងរបស់គេ គឺថាជះឥទ្ធិពលរបស់លោក អស់លោក លោកស្រីចៅក្រម ហើយឲ្យលោក លោកស្រីចៅក្រមយល់ថា មិនខុសអីទេក្នុងការកាត់ទោសគេនេះ ព្រោះជនជាប់ចោទនេះមានទោសទៅហើយ មានពិរុទ្ធភាពទៅហើយ។ អ៊ីចឹងមានអ្នកណាបន្ទោសបង្អាប់ដល់លោក លោកស្រីចៅក្រមទេក្នុងការមិនគោរពច្បាប់ វិធានត្រង់កន្លែងនេះនោះ។ ក៏ប៉ុន្តែទន្ទឹមនឹងនោះនៅពេលដែលច្បាប់ខ្លាំង កាន់តែខ្លាំង ក្មេងជំនាន់ក្រោយនឹងគោរព ហើយយុត្តិធម៌នឹងក្លាយជាគំរូនៅថ្ងៃក្រោយ។ ហើយនៅពេលដែលគេមិនគោរពច្បាប់ ហើយសង្គមនៅថ្ងៃអនាគតនោះហ្នឹង នឹងមិនមានការគោរពយុត្តិធម៌ទេ។

[១០:០៨:៤៩]

ខាងព្រះរាជអាជ្ញានិយាយថាយើងត្រូវផ្សះផ្សាជាតិ ក៏ប៉ុន្តែផ្សះផ្សាជាតិនេះត្រូវចំណាយប៉ុន្មានត្រូវអង្គុយលើច្បាប់ ឬក៏យ៉ាងម៉េច? គេសុំឲ្យអស់លោក លោកស្រីចៅក្រមកាត់ទោសលោក ខៀវ សំផន ដែលបានដាក់ប្រជាជនឲ្យក្លាយជាទាសករ ក៏ប៉ុន្តែឧក្រិដ្ឋកម្មដែលថាដាក់មនុស្សឲ្យក្លាយជាទាសករហ្នឹង មិនត្រូវបានដាក់ជាបណ្ដឹងទេ។ គេសុំឲ្យថានៅ -- ដោយសារគាត់បានបង្កើតជាសហករណ៍ ហើយមន្ទីរឃុំឃាំងពោរពេញទៅដោយឈាម កន្លែងអប់រំដែលមានការប្រព្រឹត្តបទឧក្រិដ្ឋលើចាម លើវៀតណាម លើអ្នកកាន់សាសនាព្រះពុទ្ធ ហើយដែលមនុស្សទាំងអស់នោះត្រូវបង្ខំឲ្យរៀបការ ហើយរួមរ័ក្សគ្នា។ ទាំងប្រធានបទទាំងអស់នេះមិនដែលមានបានលើកមកនិយាយចំពោះមុខតុលាការនេះទេ។ ហេតុអ្វីក៏គេលើកបង្ហាញចំណុចទាំងអស់នេះ។ និយាយទាំងអស់នេះ គឺថាដើម្បីបោកបញ្ឆោតអស់លោកចៅក្រមដែលគេនៅតែនិយាយថា ទោះបីជាលោក ខៀវ សំផន មិនបានមើល ជនរងគ្រោះនៅចំពោះមុខក៏ដោយ ព្រោះថាគាត់អង្គាល់នោះនៅភ្នំពេញ ហើយធ្វើការសេចក្ដីសម្រេចចិត្តឧក្រិដ្ឋ អ្នកហ្នឹងគឺ ខៀវ សំផន ហ្នឹងហើយដែលគាត់កាន់ដំបង ដើម្បីវ៉ៃប្រជាជនខ្មែរ ហើយដែលគាត់ហ្នឹងហើយដែលមិនឲ្យស្រូវអង្ករគេ គាត់ហ្នឹងហើយដែលធ្វើទណ្ឌកម្មគេនៅមន្ទីរស-២១ គាត់ហែកជើងក្មេងៗ ហើយនិងបង្ខំឲ្យគេ

រៀបការ ហើយធ្វើបាបព្រះសង្ឃអីជាដើម ដោយសើចសប្បាយ។ បើតាមការពិតទៅ ខៀវ -- សហព្រះរាជអាជ្ញា -- ពីឡុតអាមេរិកាំង ហើយទាហានលន់ នល់ ដែល ទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជា ហើយនិងទម្លាក់គ្រាប់បែកបរិមាណ្ឌ ហើយតើពួកហ្នឹងកាលដែលទម្លាក់គ្រាប់បែកហ្នឹងមានមើលក្មេងៗនៅស្រុកខ្មែរហ្នឹងទេ?

[១០:១១:០៧]

បាទ តាមការពិតទៅអស់លោក លោកស្រីចៅក្រម! ព្រះរាជអាជ្ញាមិនបាននិយាយទៅកាន់អស់លោក លោកស្រីចៅក្រមទេ គេនិយាយទៅកាន់ ទៅដល់ក្រុមអ្នកកាត់សេចក្ដីដែលមិនមានជំនាញ ហើយដែលគិតថា និយាយអ៊ីចឹងទៅអស់លោក លោកស្រីចៅក្រមស្ដាប់តាម ហើយនិងអំពីអ្វីដែលថា ដោយផ្អែកលើមតិសាធារណជន គួរឱ្យស្អប់ខ្ពើម។ អ៊ីចឹងបានន័យថា គេកំពុងតែយកពិភពលោកធ្វើជាចៅក្រមហើយ ហើយអ៊ីចឹងសហព្រះរាជអាជ្ញានិយាយហ្នឹង និយាយទៅកាន់ពិភពលោកទាំងមូល។ គេនិយាយយ៉ាងដូច្នេះដោយសារគេភ័យ គេដឹងថាៗនៅមាន នៅតែមានសេចក្ដីសង្ឃឹមមួយដែលអស់លោក លោកស្រីចៅក្រម និងធ្វើការកាត់សេចក្ដីក្នុងឋានៈជាចៅក្រម នៅតែមានសេចក្ដីសង្ឃឹមមួយអ៊ីចឹង។ ក៏ប៉ុន្តែមតិអន្តរជាតិវាស្រួលណាស់ ធ្វើឱ្យគេភ្ញាក់ផ្អើលហ្នឹង ហើយ ព្រោះថាគេមិនគោរពនីតិវិធីអីទេ។ ដោយសារសាធារណជនគាត់មិនសូវដឹងប៉ុន្មានទេ អ៊ីចឹងយើងអាចធ្វើប្រជាភិថុតបាន។ ឧទាហរណ៍ ធ្វើឱ្យ -- តើអស់លោក លោកស្រីសាធារណជនឈឺ លោកឈឺក្បាលទេ ដែលគេសុំឱ្យលោក ខៀវ សំផន នេះចូលរួមក្នុងការកាត់សេចក្ដីដែលកាត់ថា បង្ហាញតែឯកសារគន្លឹះទៅសាធារណជន ហើយទៅអ្នកកាសែត ហើយបន្ទាប់មកទៀត ដើម្បីអះអាងថា គឺជាផ្នែកមួយនៃការជំនុំជម្រះ ដែលមានការសួរតទល់គ្នា។ មិនមែនអ៊ីចឹងទេ អស់លោក លោកស្រីប្រហែលជាមិនយល់ថា ខ្ញុំនិយាយអំពីអ្វីទេ ហើយមិនដឹងថាបញ្ហានៅត្រង់ណាទេ? ប្រហែលជា -- តើអស់លោក លោកស្រីគេងមិនលក់ឬក៏យ៉ាងម៉េច ដែលថាវិសាលភាពនៃការកាត់សេចក្ដីលើឃាតករ ពេជ្ឈឃាដនេះ ដែលថាពន្លាតនៅពេលដែលចាប់ផ្ដើមហើយនោះ ហើយបន្ថែមអង្គហេតុអីទៀត? តើធ្វើឱ្យឈឺក្បាល ធ្វើឱ្យអស់លោក លោកស្រីគេមិនលក់ទេ? ធ្វើឱ្យភ្ញាក់ផ្អើលទេ? អស់លោក លោកស្រីសាធារណជន តើបិសាចនៅក្រោយខ្ញុំនោះ ខ្ញុំជាមេធាវីគាត់ផងនោះមិនទាំងអានសារណាសន្និដ្ឋានបញ្ចប់ផង ដោយសារគាត់ -- យើងមិនចេះភាសាអង់គ្លេសច្បាស់លាស់ដើម្បីត្រៀមការមកធ្វើបទបង្ហាញថ្ងៃនេះនោះ ហើយដែលពួកគាត់នោះត្រូវការរង់ចាំដល់នាទីចុងក្រោយនេះ ពេលដែលស្ដាប់គេនិយាយចប់អស់ហើយហ្នឹង ដើម្បីឱ្យយល់អំពីអំណះអំណាង

របស់សហព្រះរាជអាជ្ញា?

[១០:១៤:០៥]

ប្រហែលជាមិនធ្វើឲ្យឈឺក្បាលវិលមុខអីទេ។ មិនធ្វើឲ្យអស់លោក លោកស្រីចៅក្រមគេមិនលក់ទេ។ នៅខែសីហា ឆ្នាំ២០១៣ នៅពេលដែលសវនាការហ្នឹងបានចាប់ផ្ដើមហើយ -- ចប់ហើយនោះហើយអង្គជំនុំជម្រះនោះបានថែមនៅក្នុងសំណុំរឿងនោះ ឯកសារចំនួន១.៣៩៩ ថែមទៀត។ ប្រហែលជាមិនជាឈឺ ប្រហែលជាមិនធ្វើឲ្យភ័យអីទេ។ តើអស់លោក លោកស្រីភ័យទេ ដែលថាឃើញលោកបិសាចនេះ ដែលគេមិនគោរពសិទ្ធិរបស់គាត់នោះ។ សិទ្ធិរបស់គាត់ក្នុងការទទួលដឹងអំពីការចោទប្រកាន់លើគាត់ ហើយនិងត្រូវការផ្ដល់ពេលវេលាឲ្យគាត់គ្រប់គ្រាន់ដើម្បីឲ្យគាត់ការពារខ្លួនបាន។ សិទ្ធិទទួលបានសមភាពនៃភាគី។ តើមេធាវីរបស់ជនផ្ដាច់ការនេះ ដែលថាស្រែកឃ្លានឈាមនេះ មិនទាំងមានពេលវេលានឹងពិភាក្សាអំពីតម្លៃភស្តុតាង ឯកសាររាប់ពាន់នៃសំណុំរឿងនេះ ដែលតុលាការនឹងផ្អែកលើឯកសារភស្តុតាងទាំងអស់ហ្នឹងដើម្បីកាត់ទោសគាត់ហ្នឹង។ តើអស់លោកសាធារណជនគិតយ៉ាងម៉េច? ខាងណោះគេនិយាយថា មិនមានបញ្ហាអ្វីទេ សហព្រះរាជអាជ្ញាអាចទទួលស្គាល់នៅក្នុងសំណើខែសីហាឆ្នាំ២០១៣ របស់ខ្លួនថា អង្គជំនុំជម្រះសាលាដំបូងមិនបានស្ដាប់ភស្តុតាងទាំងអស់ទេ ហើយដោយគេ -- ដោយយោងទៅនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដើម្បីនិយាយអំពីគម្រោងឧក្រិដ្ឋរួមហើយនិងការវាយប្រហារជាប្រព័ន្ធ ហើយនិងទូទៅប្រឆាំងទៅនឹងប្រជាជនខ្មែរទាំងអស់តែម្ដង។ អ៊ីចឹងយើងមើលឃើញទាំងអស់នោះសុទ្ធតែមានការបាញ់សម្លាប់ ហើយពិភពលោកទាំងមូលនឹងចំអកឡកឡឺយដល់នីតិវិធីចំពោះមុខតុលាការយើងនេះ។

[១០:១៦:៣៨]

នៅសវនាការទី១ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញានិយាយអំពីអង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយទាំងអស់តែម្ដង។ ហើយច្រើនណាស់ អ្នកដែលបានចូលរួមក្នុងសវនាការខែវិច្ឆិកា ឆ្នាំ២០១១ ហើយពីរឆ្នាំក្រោយមកនោះ ពីរបីថ្ងៃមុននេះ សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានោះគឺថា គេគិតថាអ្នកដែលកំពុងតែទទួលការកាត់ក្ដីនៅទីនេះ គឺថាគេកាត់ក្ដីលើរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលតែម្ដង ហើយនិងខាងអ្នកកាសែតគេនិយាយថា មានអ្នកមនុស្សស្លាប់រាប់លាននាក់ហើយមានវិសាលភាពពេលវេលាហ្នឹងគឺថា ៣ឆ្នាំ ៨ខែ ជាដើម។ ប៉ុន្តែ នៅថ្ងៃដែលគេកាត់ទោសលោកខៀវ សំផន ផ្ដន្ទាទោសលោក ខៀវ សំផន ហើយគេនឹងលាបពណ៌ លាបថ្នាំអីនៅតុលាការនេះឲ្យឃើញ

ស្អាត ហើយគេនឹងកាត់ស្មៅកាត់អីឲ្យស្អាត ហើយយើងនឹងឃើញនៅក្នុងបន្ទប់នៅហ្នឹងក្រៅនេះ ឃើញឡានពួកឯងអគ្គរាជទូតពីប្រទេសដែលផ្តល់ជំនួយដល់តុលាការយើងនេះ។ អីចឹងយើងនឹងអាចហៅថា ដូចជារោងល្ខោនមួយអីចឹង ព្រោះថាបើអ្នកការទូតទាំងអស់នេះ ហើយនិងអស់លោកស្រីទាំងអស់នេះមិនដែលចាប់អារម្មណ៍នឹងការកាត់សេចក្តីយើងនេះទេ។ ហើយអ្នកកាសែតទាំងអស់នោះដែលយើងបានឃើញតែបន្តិចបន្តួចនោះប៉ុន្មានឆ្នាំនេះនោះ--

[១០:១៨:២៩]

**ប្រធានអង្គជំនុំ៖**

មេធាវី យើងបានរំឭកអំមិញហើយ បញ្ហាគឺធ្វើយ៉ាងម៉េចកុំឲ្យប៉ះពាល់ដល់ភាគីដទៃទៀត ឬក៏មិនពាក់ព័ន្ធទេ សេចក្តីសន្និដ្ឋានរបស់លោកអម្បាញ់មិញនេះ គឺទំនងជាមិនពាក់ព័ន្ធនៅក្នុងរឿងក្តីនេះទេ។ ជាគោលការណ៍នៅក្នុងសេចក្តីសន្និដ្ឋានរបស់ភាគីគឺត្រូវមានអាកប្បកិរិយា ពាក្យសម្តីសមរម្យ គោរពភាគីដទៃទៀត គោរពអង្គជំនុំជម្រះ គោរពសាធារណជន គោរពក្រមសីលធម៌វិជ្ជាជីវៈ។ ហើយសេចក្តីសន្និដ្ឋានគប្បីដាក់ឲ្យចំបញ្ហាទៅលើអង្គហេតុ ភស្តុតាង អង្គច្បាប់ ដែលពាក់ព័ន្ធនឹងវិសាលភាពដែលអង្គជំនុំជម្រះបានធ្វើសវនាការរួចហើយ ដោយសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងឧបសម្ព័ន្ធភ្ជាប់ជាមួយ ដែលលោកបានលើកឡើងអម្បាញ់មិញនេះ គឺជាក់ច្បាស់ហើយនៃមូលដ្ឋាននៅក្នុងការវិសាលភាពនៅក្នុងការធ្វើសេចក្តីសន្និដ្ឋាននេះ។ មិនគប្បីប្រើពេលវេលានេះវាយប្រហារប៉ះពាល់ដល់ភាគីដទៃទៀត ឬដល់កិត្យានុភាពរបស់អង្គជំនុំជម្រះនេះឡើយ។ សង្ឃឹមថាលើកទី២ ហើយលោកមេធាវីនឹងអនុវត្តតាមសេចក្តីណែនាំនេះឲ្យបានសមរម្យ។

[១០:២០:១៧]

**លោក អាកទួរ វែកគែន៖**

បាទយើងប្រហែលជាមានទស្សនៈដូចគ្នាទេអំពីការធ្វើការសន្និដ្ឋានចុងក្រោយ។ ខ្ញុំគិតថាមិនបាននិយាយតែរំលោភបំពានលើអ្នកណាទេក្នុងពេលដែលការពារកូនក្តីខ្ញុំនេះ ហើយខ្ញុំមិនបានជេរអ្នកណាទេ ហើយព្រះរាជអាជ្ញាកាលគេនិយាយនោះ និយាយមួយសេរី ហើយខាងការពារក្តីនោះគួរតែនិយាយដោយសេរីភាពដែរ ដោយមិនត្រូវទទួលការរំលោភបំពាន ដោយថាខ្ញុំបានរំលោភបំពានលើវិធានអីជាដើមនោះ។ ខ្ញុំមិនបានធ្វើអីចឹងទេ។ បើទោះជាយ៉ាងណាក្តី ខ្ញុំ អម្បាញ់មិញខ្ញុំកំពុងតែនិយាយថាអ្នកដែលបានចូលរួមស្តាប់សវនាការកាលពីថ្ងៃដំបូងហ្នឹង ហើយនិងថ្ងៃចុងក្រោយនេះអាចមានអារម្មណ៍ថា

ការកាត់សេចក្តីប្រចាំសតវត្សរ៍នេះកើតឡើងហើយ ក៏ប៉ុន្តែតាមពិតមិនមែនទេ។ ពីរឆ្នាំនេះគឺជាការកាត់ក្តីខុសហើយ។ ដូច្នេះ ការពិតគឺថានៅចុងបញ្ចប់នៃការកាត់សេចក្តីនេះ ខាងមេធាវីលោក ខៀវ សំផន គឺថាចង់និយាយថា បើសិនជាគោរពសិទ្ធិលោក ខៀវ សំផន ត្រូវដោះលែងគាត់។ បើកាត់ទោសគាត់បើតាមយើងវិញ គឺថាជាការរំលោភបំពានលើសិទ្ធិជាមូលដ្ឋាននៃព្រហ្មទណ្ឌអន្តរជាតិ។ ខ្ញុំមិនបានជេរអ្នកណាទេ ហើយយើងមិនអាច យើងមិនអាចសម្របសម្រួលទេ គឺថាមិនអាចថាយុទ្ធសាស្ត្រនេះជាយុទ្ធសាស្ត្ររបស់ខាងការពារក្តីទេ ព្រោះថាចៅក្រមខ្លួនឯងជាអ្នកពង្រីកវិសាលភាពខ្លួនឯង បំបែកដំណើរការនីតិវិធី ហើយយើងមិនមែនប្រើយុទ្ធសាស្ត្រអីទេ។

[១០:២២:១៥]

នៅពេលដែលសហភាតា កូប៉េ របស់ខ្ញុំនោះនិយាយប៉ុន្មានថ្ងៃមុននេះ អស់លោកចៅក្រមមិនបានកាត់ផ្តាច់គាត់ទេ។ គាត់និយាយថា គាត់ទុកចិត្តចៅក្រមអន្តរជាតិដើម្បីបង្កើតជាកំផែងរឹងមាំមួយ។ ខ្ញុំចង់និយាយថា ត្រង់ចំណុចនេះ ខ្ញុំមិនគាំទ្រគាត់ទាំងស្រុងទេ ការលើកឡើងរបស់គាត់។ ខ្ញុំគិតថាចៅក្រមខ្មែរក៏អាចធ្វើដូចចៅក្រមបរទេសបានដែរ។ ខ្ញុំទុកចិត្តអស់លោក លោកស្រីចៅក្រមជាតិ ខ្ញុំទុកចិត្តលើតុលាការយើងនេះតែម្តង ទោះបីជាសមាសភាពយ៉ាងណាក៏ដោយ។ ទាក់ទងនឹងចៅក្រមជាតិ ខ្ញុំសូមជម្រាបជូនថា ជាប្រទេសរបស់លោកចៅក្រម ជាកេរ្តិ៍ឈ្មោះរបស់អស់លោក លោកស្រីចៅក្រម។ នៅថ្ងៃមួយ នៅថ្ងៃអនាគត របបផ្តាច់ការ ពុករលួយដែលមាននៅសព្វថ្ងៃនេះប្រហែលជានឹងបរាជ័យហើយ ហើយនិងសករាជនឹងចាប់ផ្តើម ហើយយើងគួរតែចាប់ផ្តើមត្រៀមលក្ខណៈខ្លួនឯង។ ហើយអ្នកលោកជាចៅក្រមជាតិនោះប្រហែលជាអាចនឹងផ្តល់ អាចធ្វើបដិវត្តន៍ថ្នាក់លើ ហើយអាចនិយាយទៅសហគមន៍អន្តរជាតិថា អស់លោក លោកស្រី--

[១០:២៣:៥៥]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ដូចជាចាកប្រធានហើយ ដូចជាក្រៅអង្គហេតុទេ។ អង្គហេតុហ្នឹងដូចជាមិនមានការចោទប្រកាន់ដេញដោលនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយក្នុងអង្គហេតុដែលអង្គជំនុំជម្រះបានដំណើរការកន្លងមកនេះ គ្មានមិនបានថែង ឬក៏ចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយទេ។

ជម្រាបលោកថា ភាគីពាក់ព័ន្ធដទៃទៀត ការនិយាយស្តីរបស់គេមានកម្រិត ហើយមិនក្រៅអង្គ

ហេតុដែលពាក់ព័ន្ធនឹងការចោទប្រកាន់នេះទេ។ អ៊ីចឹងហើយបានអង្គជំនុំជម្រះមិនកាត់គេ។ មិនមែនប្រៀបធៀបតុលាការនេះទៅជាឆាកល្ខោន ហើយយករឿងដទៃទៀតដែលនៅក្នុងមូលដ្ឋាននៃបញ្ហាក្រៅអង្គហេតុនៅក្នុង អ.វ.ត.ក នេះមកលើកលាតត្រដាងនៅពេលនេះទេ។ វាមិនពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់ ដែលជាមូលដ្ឋានឱ្យអង្គជំនុំជម្រះយកទៅពិចារណាវិនិច្ឆ័យនៅក្នុងរឿងក្ដីនេះ។ យើងបានជម្រាបលោកហើយអំមិញ អង្គជំនុំជម្រះនឹងពិចារណានៅក្នុងរឿងក្ដីនេះទៅលើអង្គហេតុ ទៅលើភស្តុតាងទៅអង្គច្បាប់ ទៅលើស្ថានភាពដែលពាក់ព័ន្ធទៅនឹងកិច្ចដំណើរការសវនាការសំណុំរឿង០០២/០១ ដែលអង្គជំនុំជម្រះបានកំណត់វិសាលភាពក្នុងការធ្វើសវនាការកន្លងមកនេះតែប៉ុណ្ណោះ។

[១០:២៥:៣៧]

**លោក អាកឡូរ វ៉េកគែន៖**

លោកប្រធាន ខ្ញុំដឹងហើយ អ៊ីចឹងហើយបានជាខ្ញុំបានចាប់ផ្ដើមបទអន្តរាគមន៍នេះដោយអានអំពីសេចក្ដីសម្រេចរបស់លោក លោកស្រីនៅឆ្នាំ២០១២ ហើយអ្វីដែលខ្ញុំដឹងដែរនោះ គឺថាសហព្រះរាជអាជ្ញាព្យាយាមតាមរយៈសន្និដ្ឋានផ្ទាល់មាត់ហ្នឹង ថាព្យាយាមធ្វើឱ្យចៅក្រមមិនគោរពសេចក្ដីសម្រេចរបស់ខ្លួនឯងកាលពីខែតុលា ឆ្នាំ២០១២។ អាស្រ័យហេតុដូច្នេះហើយបានជា ការដែលថាការគិតថាការដែលយល់ថាអាចបញ្ចុះបញ្ចូលចៅក្រមបាននេះបាទ។ ដោយសារតែថា -- ដោយសារតែហេតុទាំងអស់នេះ ហើយដែលខ្ញុំនិយាយលើកឡើងពីចំណុចទាំងប៉ុន្មានខាងមុខនេះ។

បើសិនជាលោកចៅក្រមទុកឱ្យព្រះរាជអាជ្ញានិយាយអំពីអារឿងដែលមិនពាក់ព័ន្ធនឹងវិសាលភាពនៃការកាត់ក្ដី ហេតុអ្វីក៏ឥឡូវនេះ ខ្ញុំមិនមានសិទ្ធិឆ្លើយតបទៅនឹងគាត់? តើយុត្តិធម៌នេះវាយ៉ាងម៉េចដែលវាអនុញ្ញាតឱ្យព្រះរាជអាជ្ញានិយាយតែផ្ដេសផ្ដាស ហើយមកហាមខាងការពារក្ដីមិនឱ្យថ្កោលទោសពីការនិយាយមិនដឹងខុសត្រូវនេះ។ នេះហើយជាគោលបំណងនៃបទអន្តរាគមន៍របស់ខ្ញុំ។ ហើយខ្ញុំគិតថាពាក្យពេចន៍ដែលខ្ញុំនិយាយនេះសំខាន់ណាស់ ហើយយើងបាននិយាយនៅក្នុងសារណាជាលាយលក្ខណ៍អក្សរយើងហើយ យើងបាននិយាយលម្អិតនៅក្នុងសំណើមួយដែលយើងបានដាក់ទៅតុលាការកំពូលហើយ ជាសារណាដែលមានចំណងជើងថា៖ “សុំឱ្យបញ្ឈប់ដំណើរការនីតិវិធីចំពោះមុខតុលាការនេះហើយសូមឱ្យដោះលែងលោក ខៀវ សំផន ជាប្រញាប់”។

[១០:២៧:៤៩]

យើងបាន -- យើងយល់ឃើញថា ចំពោះយើងជាអ្នកការពារក្ដីមានហេតុផលក្នុងការព្រួយបារម្ភ

ថាអង្គជំនុំជម្រះនេះនឹងអាចត្រូវពេញចិត្តនឹងអ្វីដែលព្រះរាជអាជ្ញាស្នើ ហើយអង្គជំនុំជម្រះនេះនឹងត្រៀមខ្លួនសម្រេចដោយប្រើអង្គហេតុក្រៅវិសាលភាពនៃការកាត់សេចក្តី ដើម្បីកាត់ទោសកូនក្តីខ្ញុំ។ ខ្ញុំចង់និយាយអំពីការសម្រេចជាច្រើនដែលអស់លោក លោកស្រីចៅក្រម បានចង្អុលបង្ហាញថា បើសិនជាយើងអាចនិយាយអំពីអត្ថិភាពនៃគោលនយោបាយទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ យើងមិនអាចនិយាយអំពីការអនុវត្តវាទេ។ ដោយសារហេតុនេះហើយបានជាខ្ញុំនិយាយរយៈពេលមួយម៉ោងនេះ ដើម្បីពន្យល់អំពីអ្វីដែលព្រះរាជអាជ្ញាចង់និយាយជូនទៅអស់លោក លោកស្រីចៅក្រម។ អ៊ីចឹងហើយបានខ្ញុំចំណាយពេលដល់មួយម៉ោងដើម្បីពន្យល់ហ្នឹង នៅពេលដែលគេយល់ថា ប្រទេសកម្ពុជាត្រូវបានកែប្រែជាតិទាសករមួយ ហើយគឺត្រង់អ៊ីចឹងហើយបាន -- ដោយសារគេនិយាយអំពីខុសពីការជម្លៀសដំណាក់កាលទី១, ទី២ ទួលពោធិ៍ជ្រៃហ្នឹងហើយ បានខ្ញុំនិយាយពីការប្រើប្រាស់អង្គហេតុទាំងឡាយដែលក្រៅពីវិសាលភាពនៅក្នុងសេចក្តីសម្រេចមួយចំនួនរបស់អង្គជំនុំជម្រះ ដែលថា យើងនឹងអាចនិយាយពិភាក្សាអំពីអត្ថិភាពនៃគោលនយោបាយទាំងប្រាំ។

[១០:២៩:៥៧]

កាតព្វកិច្ចរបស់ខ្ញុំជាមេធាវីការពារក្តី គឺរិះគន់សំណើរបស់សហព្រះរាជអាជ្ញាដែលលើកអង្គហេតុខុសវិសាលភាព។ ដែលធ្វើឲ្យយើងអាចគិតដឹងមុនថា សេចក្តីសម្រេច ឬកាត់សេចក្តីនោះយ៉ាងម៉េច បើនិយាយឲ្យចំមួយម៉ាត់ទៅ ខ្ញុំថាកាត់សេចក្តីនេះហាក់ដូចជាការក្តីលើចេតនា។ ខ្ញុំបានដកស្រង់ពីសេចក្តីសម្រេចរបស់តុលាការកំពូលដែលនិយាយថា ដែលបានឆ្លើយបីខែក្រោយមកនោះ ឆ្លើយពីរទំព័រកន្លះថា “អ្វីដែលយើងបានលើកឡើងនេះគួរឲ្យចាប់អារម្មណ៍ណាស់ ក៏ប៉ុន្តែត្រូវចាំសាលក្រមរបស់សាលាដំបូងសិន បើសិនជាយើងខ្ញុំមិនពេញចិត្ត យើងខ្ញុំអាចប្តឹងឧទ្ធរណ៍បាន”។ យើងខ្ញុំដឹងហើយចំណុចនេះ ក៏ប៉ុន្តែការងារខ្ញុំគឺត្រូវតែរិះគន់អំពីអ្វីដែលបានស្នើជូនដល់អស់លោក លោកស្រីចៅក្រមហ្នឹង ដែលគួរឲ្យទុកចិត្តគួរថា -- ហើយមានប្រសិទ្ធភាព នេះគឺជាល្បែងនៃការកាត់សេចក្តីទេ។ បើសិនថាខ្ញុំនិយាយហ្នឹងវាអាចដូចថាគាប់ថា -- មិនមែនជាការមិនគាប់គួរនោះ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់លើកឡើងប៉ុណ្ណឹងទេ។

ខ្ញុំឃើញថាឥឡូវនេះម៉ោងដប់កន្លះហើយៗ ខ្ញុំនឹងសូមបន្តនិយាយអំពីភស្តុតាង អ៊ីចឹងខ្ញុំសូមស្នើថាសម្រាក ឬក៏យ៉ាងម៉េចលោកប្រធាន?

**ប្រធានអង្គជំនុំៈ**

បាទ អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលសមស្របនឹងសម្រាកហើយអង្គជំនុំជម្រះ

ប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥០ នាទី)*

[១០:៥១:០៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន បន្តការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២/០១របស់ខ្លួន អង្គជំនុំជម្រះសូមរំឭកជម្រាបជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ថាពេលវេលាដែលអង្គជំនុំជម្រះបានចែកជូនរួចហើយ គឺពីរថ្ងៃ ដោយសហមេធាវីការពារក្តី រួមទាំងជនជាប់ចោទ ខៀវ សំផន ផង ក្នុងការឡើងធ្វើសេចក្តីថ្លែងសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សារបស់ខ្លួនផ្នែកសំណុំរឿងដែលអង្គជំនុំជម្រះដែលបានធ្វើសវនាការដេញដោលរួចហើយនេះ គឺបិទបញ្ចប់នៅក្នុងសំណុំរឿង០០២/០១។

[១០:៥២:៣៧]

ហើយតើអាចជម្រាបដល់អង្គជំនុំជម្រះបានទេថា ក្នុងពេលពីរថ្ងៃនេះលោក ខៀវ សំផន នឹងប្រើពេលវេលាប្រហែលជាប៉ុន្មាន? ហើយគាត់ប្រើពេលវេលានៅពេលណា ក្នុងការឡើងធ្វើសេចក្តីថ្លែងបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន មុននឹងបន្តកិច្ចការនីតិវិធីទៅមុខទៀត?

**លោក អាកទួរ វែកកែន៖**

លោកប្រធាន ខ្ញុំមិនសូវយល់ច្បាស់អំពីអ្វីដែលលោកប្រធាននិយាយអម្បាញ់មិញនេះ។ គេបានបកប្រែឲ្យខ្ញុំថា សេចក្តីសន្និដ្ឋានរបស់យើងខ្ញុំនោះ គឺថាមានរយៈពេលពីរថ្ងៃ។ ហើយក្នុងរយៈពេលពីរថ្ងៃនេះ គឺគិតទាំងពេលវេលាសម្រាប់លោក ខៀវ សំផន តើអ៊ីចឹងមែនទេ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

បាទ ត្រឹមត្រូវហើយ។ ដោយសារយើង ព្រឹកមិញមិនបានបញ្ជាក់ជូនលោក។ ឥឡូវ យើងជម្រាបជូនឲ្យបានច្បាស់លាស់លើពេលវេលាដែលបានចែកជូន។ តាមពិតគេចែកជូនរួចហើយ នៅក្នុងឯកសារលាយក្ខណ៍អក្សរជូនភាគីនានាតាំងពីដំបូង។ ហើយឥឡូវនេះ យើងបញ្ជាក់បន្ថែម បន្ថែមនេះក្នុងន័យពីរ។ ទី១ គឺរំឭកអំពីពេលវេលា។ ទី២ សូមឲ្យមានការបញ្ជាក់អំពីការប្រើពេលវេលារបស់លោក ខៀវ សំផន ក្នុងការឡើងធ្វើសេចក្ដីផ្ទាល់មាត់ បិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន តើគាត់ប្រើពេលវេលាដែរទេ? ឬប្រើពេលវេលានៅពេលណា?

**លោក អាកឌូរ វែកគែន៖**

អ្វីដែលខ្ញុំមិនយល់នោះ គឺថាតើលោក ខៀវ សំផន គាត់មានពេលវេលាជាក់លាក់ពិសេសអ្វីទេនៅក្នុងសវនាការយើងនេះ? ពីព្រោះថា លោក កូប៉េ ហើយនិងលោក សុន អរុណ នោះ គាត់បានប្រើពេលប្រហែលជាពីរថ្ងៃ គឺខ្វះតែកន្លះម៉ោងទេ។ ហើយដូច្នេះ ខ្ញុំគិតថាលោកប្រធានមិនបានតម្រូវឲ្យ នួន ជា និយាយកន្លះម៉ោងដែលនៅសល់កាលពីម្សិលមិញនោះទេ។ ដូច្នេះ ខ្ញុំគិតថា ប្រហែលជាមានបញ្ហាទំនាក់ទំនងគ្នារវាងយើង ហើយនិងមេធាវីហើយ។

[១០:៥៤:៥៨]

ខ្ញុំសូមបញ្ចប់សិនលោកប្រធាន។ ខ្ញុំយល់ថាមានការគ្រោងទុកថា ភាគីនឹងឆ្លើយតបនៅសប្ដាហ៍ក្រោយ។ តើអ៊ីចឹងមែនទេលោកប្រធាន? ហើយនៅក្នុងពេលដែលសម្រាប់ការឆ្លើយតបនោះ ជនជាប់ចោទមានសិទ្ធិក្នុងការធ្វើសេចក្ដីសន្និដ្ឋានចុងក្រោយ ហើយមិនដែលមានការជម្រាបដល់ភាគី ឬក៏ដល់ក្រុមមេធាវីការពារក្ដីថា ពេលវេលារបស់យើងពីរថ្ងៃដែលចាប់ផ្ដើមពីព្រឹកមិញនេះ នឹងត្រូវកាត់ចេញពីពេលវេលាដែលលោក ខៀវ សំផន នឹងឡើងនិយាយជាលើកចុងក្រោយនោះទេ។

**ប្រធានអង្គជំនុំ៖**

ពេលនេះ គឺនៅការចាប់ផ្ដើមសេចក្ដីសន្និដ្ឋានដំបូងរបស់មេធាវីការពារក្ដី គឺមួយក្រុម រួមទាំងមេធាវីរបស់ខ្លួន និងជនជាប់ចោទពីរថ្ងៃ។ នៅក្នុងពីរថ្ងៃនេះ គឺទាំងមេធាវី ទាំងជនជាប់ចោទសុទ្ធតែមានសិទ្ធិក្នុងការឡើងធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។ នៅថ្ងៃចុងក្រោយបង្អស់អង្គជំនុំជម្រះបានជម្រាបជូនរួចហើយ។ អង្គជំនុំជម្រះបានបែងចែកជូនទៅមេធាវីការពារក្ដី និងជនជាប់ចោទមួយរូបៗមានរយៈពេលពីរម៉ោង ក្នុងការធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់ស្ថាពរចុងក្រោយ។ លោក

មិនបាច់ឆ្លើយក៏បានដែរ ពីព្រោះម្សិលមិញ គឺមិនអាចធៀបជាមួយនឹងលោក នួន ជា បានទេ មេធាវីរបស់គាត់បានបញ្ជាក់ហើយ លោក នួន ជា មិនប្រើសិទ្ធិរបស់គាត់ក្នុងការធ្វើសេចក្ដីថ្លែងបិទបញ្ចប់កិច្ចពិភាក្សាដេញដោលនាពេលនេះទេ។ លោក នួន ជា នឹងប្រើប្រាស់ពេលចុងក្រោយ គឺសេចក្ដីសន្និដ្ឋានបិទបញ្ចប់ស្ថាពររបស់ខ្លួនដែលអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទធ្វើថ្ងៃចុងក្រោយ។

[១០:៥៧:០០]

**លោក អាកទួរ វែកកែន៖**

បាទ ខ្ញុំយល់ហើយលោកប្រធាន។ ដូច្នេះលោក ខៀវ សំផន គាត់នឹងនិយាយនៅថ្ងៃចុងក្រោយនៅពេលដែលគាត់ឆ្លើយតប។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ចង់បានព័ត៌មានប៉ុណ្ណឹងទេ។ សូមអញ្ជើញបន្តការងាររបស់លោកតទៅទៀត។

**លោក អាកទួរ វែកកែន៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះខ្ញុំសូមលើកឡើងអំពីចំណុចមួយចំនួនពាក់ព័ន្ធនឹងភស្តុតាងនៅក្នុងសំណុំរឿង។ ខ្ញុំមិនត្រឡប់មកនិយាយដដែលវិញទេ ខាងមេធាវីការពារក្ដី នួន ជា គាត់បានលើកឡើងថា ប្រសិនបើយើងសង្កេតមើលឯកសារទាំងមូលដែលប្រើប្រាស់ដោយសហព្រះរាជអាជ្ញាដើម្បីបញ្ជាក់អំពីសេចក្ដីសន្និដ្ឋានរបស់ខ្លួននោះ យើងអាចយល់ឃើញថា ការជំនុំជម្រះក្ដីនេះគឺថាមានអស់លុយត្រឹមតែប៉ុន្មានដុល្លារតែប៉ុណ្ណោះ។ នៅក្នុងភស្តុតាងដែលបានបង្ហាញជូនប៉ុន្មានថ្ងៃមកនេះ ដោយសហព្រះរាជអាជ្ញានោះ ក៏មានការដកស្រង់ខ្សែវីដេអូមួយចំនួន។ ខ្សែវីដេអូហ្នឹង គឺអត់មានអស់លុយអីទេ។ វាអត់មានអស់អីប៉ុន្មានទេ ហើយឯកសារទាំងអស់ហ្នឹង សុទ្ធតែជាឯកសារមិនអាចជឿជាក់បាន។

ខ្ញុំសូមបង្ហាញដោយខ្លីដោយស្នើសុំឲ្យផ្នែកបច្ចេកទេសបញ្ចាំងវីដេអូទី១ ហើយនិងទី២។

[១០:៥៨:៣៥]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"ស៖ លោកថាទោះជាយ៉ាងណាក៏ដោយ គឺថាអំណាចលោក នោះមានតាំងពីយ៉ាងយូរនោះលោកត្រៀមខ្លួននឹងបោះបង់ចោល? ឆ៖ ចំពោះខ្លួន ខ្ញុំអាចនឹងចេញបាន ខ្ញុំចុះចេញបាន ប្រសិនជាផលប្រយោជន៍នៃប្រទេសរបស់ខ្ញុំតម្រូវនោះ ខ្ញុំអាចចាកចេញពីតំណែងជាប្រមុខរដ្ឋបាន។ ហើយខ្ញុំមិនចង់ឲ្យគេទាត់ពីក្រោយខ្ញុំ ឲ្យបណ្ដេញខ្ញុំចេញទេ ខ្ញុំមិនបានក្បត់ប្រទេសជាតិខ្ញុំទេ។ ដូច្នេះហើយ បានជាខ្ញុំ*

*តស៊ូប្រឆាំងហើយខ្ញុំបានឈ្នះ។ ខ្ញុំចូលចិត្តការតស៊ូ គឺថាដូចជា កាស៊ុស ស្ពេ ហ្នឹងគាត់ចូលចិត្តការវ៉ៃប្រុក ខ្ញុំៗចូលចិត្តប្រយុទ្ធ។ សៈ លោក លោកមានអំណាចទេពាក់ព័ន្ធទៅនឹងប្រជាជនរបស់លោក? ឆៈ ខ្ញុំ ខ្ញុំមានមោទនភាពក្នុងការធ្វើបដិវត្តន៍ ហើយនិងធ្វើឱ្យរាជានិយមហ្នឹងមានការវិវត្តន៍ជាមួយនឹងបដិវត្តន៍នោះ។ មិនមានរាជានិយមណាដែលអាចធ្វើបានទេ ហើយខ្ញុំមានមោទនភាពណាស់ដែលអំណាចរាជានិយមអាចធ្វើរឿងរ៉ាវបែបនេះបាននោះ។ សៈ តើលោក -- តើសម្ដេចនៅក្នុងព្រះបរមរាជវាំងមែនទេ? ឆៈ បាទ ខ្ញុំនៅក្នុងព្រះបរមរាជវាំង ហើយខ្មែរក្រហមជាអ្នកឱ្យខ្ញុំរស់នៅទីនោះ។ សៈ តើលោក -- តើសម្ដេចជាអ្នកសុំទេ? ឆៈ អត់ទេ មិនមែនខ្ញុំទេ។ នៅវាំង គឺតំណាងឱ្យរដ្ឋកម្ពុជា។ ជាតំណាងឱ្យរដ្ឋ ដូច្នេះប្រមុខរដ្ឋត្រូវតែនៅក្នុងវាំង។ នេះជាអ្វីដែលខ្មែរក្រហមប្រាប់ខ្ញុំ។ សៈ តើទំនាក់ទំនងរបស់សម្ដេចជាមួយនឹងយុទ្ធជនខ្មែរក្រហមយ៉ាងម៉េចដែរ តាំងពីរដ្ឋប្រហាររហូតមកដល់ពេលនេះ? ឆៈ ទំនាក់ទំនងគឺថាល្អណាស់។ គឺថាមានភាពស្និទ្ធស្នាលគ្នា យើងឯកភាពគ្នាទៅលើគ្រប់ចំណុចទាំងអស់ ទាំងផ្ទៃក្នុង ផ្នែកផ្ទៃខាងក្រៅ យើងមានមាគ៌ាដឹកនាំដូចគ្នា យើងឯកភាពគ្នា។ ខ្ញុំឃើញមនុស្សនៅក្នុងតាមផ្លូវ ដែលចេញពីរោងចក្រចូលទៅផ្ទះ ពួកគេមើលទៅដូចជាអត់មានកំសត់អត់មានវេទនាអីទេ។ ខ្ញុំមិនអាចនិយាយបានទេ ពីព្រោះថាខ្ញុំគ្រាន់តែទៅផ្ទះពេទ្យធ្មេញហ្នឹងជាមួយនិងលោក ខៀវ សំផន ហើយខ្ញុំមើលស្រែ មើលសហករណ៍ មើលជំរំការងារ ពួកគាត់ធ្វើការ ហើយយើងមើលទៅដូចថា មិនមានការភ័យខ្លាច អត់មានការហូបចុកខ្វះ មិនគ្រប់គ្រាន់អីទេ គឺមើលទៅដូចជាធម្មតាសុខភាពល្អ”។*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:០១:៥៣]

**លោក អាកទួរ វែកកែន៖**

ការសម្ភាសពីរទើបតែបង្ហាញនៅលើអេក្រង់។ ការសម្ភាសទី១នោះ ត្រូវបានធ្វើឡើងនៅខែតុលា ឆ្នាំ១៩៧៥ នៅទីក្រុងញូវយ៉ក ទៅកាន់អ្នកសារព័ត៌មានបារាំង។ នៅពេលនោះ គឺសម្ដេចសីហនុ នៅញូវយ៉ក គាត់មានសេរីភាព គាត់មិនមានការទទួលការគំរាមកំហែង ការគាបសង្កត់អីទេ។ ហើយការសម្ភាធដែលលើកឡើងដោយ ប៉ុល ពត នៅក្នុងកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦ ជាកំណត់ហេតុដែលត្រូវបានប្រើប្រាស់ដោយសហព្រះរាជអាជ្ញានៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួននៅសប្ដាហ៍នេះ គឺថាមិនមានការអនុវត្តសម្ពាធទាំងអស់នោះទេ។ ពីព្រោះថាយើងមានរយៈពេលប្រាំមួយខែមុនពេលប្រជុំរបស់គណៈអចិន្ត្រៃយ៍នៅខែតុលា ឆ្នាំ១៩៧៥ នៅពេលដែលមានការសម្ភាសនោះ ការ

ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ បានសម្រេចរួចអស់ហើយ ហើយក៏ត្រូវបានអនុវត្តរួចដែរ ហើយក៏បានបញ្ចប់អស់រយៈពេលជាច្រើនខែមកហើយ។

សម្តេច សីហនុ រស់នៅក្នុងទីក្រុងភ្នំពេញដែលគ្មានមនុស្សនៅ ហើយម្យ៉ាងទៀតនៅខែតុលា ឆ្នាំ១៩៧៥ ហេតុការណ៍នៅទួលពោធិ៍ជ្រៃនោះ បានកើតឡើងកន្លងផុតទៅប្រាំមួយខែកន្លងមកហើយ។ ជាចុងក្រោយ គឺនៅខែតុលា ឆ្នាំ១៩៧៥នេះ ការជម្លៀសប្រជាជនដំណាក់កាលទី២ មិនត្រឹមតែបានសម្រេចរួចទៅហើយទេ ក៏ប៉ុន្តែការអនុវត្តនោះក៏បានចាប់ផ្តើមទៅទៀត។ ហើយក៏ដោយសារតែយើងមិនមានភាពច្បាស់លាស់អំពីការបញ្ចប់នោះ យើងអាចគិតថាប្រហែលជាអាចចប់ទៅហើយនៅខែតុលានោះ។ ក៏ប៉ុន្តែនៅក្នុងការសម្ភាសនោះ សម្តេច សីហនុ មានបន្ទូលថា៖ "ខ្ញុំឯកភាពចំពោះអ្វីដែលបានកើតឡើងពាក់ព័ន្ធទៅនឹងគោលនយោបាយផ្ទៃក្នុង និងផ្ទៃក្រៅរបស់កម្ពុជា"។

[១១:០៤:០៣]

កិច្ចសម្ភាសន៍ទី២ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៧៩ គឺមានន័យថា ក្រោយពីការដួលរលំរបស់របបខ្មែរក្រហម។ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ នោះ គឺថាមិនមានការសង្ស័យពាក់ព័ន្ធទៅនឹងការប្រថុយប្រថានដែលសម្តេចសីហនុ គាត់អាចមានក្នុងការនិយាយអំពីអ្វីដែលគាត់បានឃើញនៅតាមសហករណ៍នោះទេ។ គឺថាអត់មានទេ។ មិនមានទេ។ សម្តេចថែមទាំងប៉ានអះអាងថា សហករណ៍ដែលព្រះអង្គបានទស្សនកិច្ចជាមួយនឹងលោក ខៀវ សំផន នៅក្នុងរបបនោះ គឺថាមានមនុស្សសុទ្ធតែជាមនុស្សដែលមានសុខភាពល្អ ហើយមើលទៅដូចជាមិនមានកើតទុក្ខ កំសត់ ឬក៏មិនមានការហូបចុកខ្វះខាតអីទេ។

ដូច្នេះ ខ្ញុំស្តាប់ឮតែអង្គជំនុំជម្រះបញ្ជាក់ថា នេះគឺជាប្រភេទនៃភស្តុតាងមួយដែលសហព្រះរាជអាជ្ញាបានរៀបចំសម្រួលដើម្បីដាក់ប្រឆាំងនឹងកូនក្តីរបស់យើងខ្ញុំ។ ខ្ញុំអាចនិយាយបានថា ប្រសិនបើនរណាម្នាក់ប៉ាននាំសម្តេច សីហនុ មកកាត់ទោសនៅទីនេះនោះ នេះគឺជាប្រភេទនៃភស្តុតាងមួយដែលសហព្រះរាជអាជ្ញាទំនងជាដាក់បង្ហាញនៅលើអេក្រង់ដើម្បីបង្ហាញអំពីពិរុទ្ធភាពរបស់សម្តេចឲ្យហួសពីវិមតិសង្ស័យដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងអ៊ីចឹង។

[១១:០៥:៤៩]

ភស្តុតាងផ្សេងទៀតដែលត្រូវបានប្រើប្រាស់ដោយសហព្រះរាជអាជ្ញា ទោះបីជាថាមានតិចតួចក៏ដោយគឺជាសក្ខីកម្ម ហើយយើងមានអារម្មណ៍ថាសហព្រះរាជអាជ្ញាមិនប្រើសក្ខីកម្មទាំងអស់នោះច្រើននោះទេ ជាពិសេសពីអ្វីដែលបាននិយាយនៅក្នុងនីតិវិធីយើងដែលមានរយៈពេលពីរឆ្នាំមកហើយនេះ។

ហើយពេលខ្លះនោះ សហព្រះរាជអាជ្ញាលើកឡើងនុ៎ងគឺដើម្បីកែ ឬក៏បំភ្លៃសម្តីរបស់សាក្សីទៀតផង។ នៅថ្ងៃដំបូងនៃការសន្និដ្ឋាននោះ សហភាគា កូប៉េ គាត់បានលើកឡើងអំពីសម្ពាធ និងការលំបាកដែលពាក់ព័ន្ធទៅនឹងរបៀបដែលគេប្រមូលសក្ខីកម្មទាំងអស់នោះ ហើយនិងរបៀបដែលសក្ខីកម្មទាំងអស់នេះត្រូវបាននិយាយដដែលៗនៅចំពោះមុខអង្គជំនុំជម្រះ។ ក្រៅពីរឿងទាំងអស់នេះ យើងមិនអាចជៀសវាងក្នុងការគិតនៅពេលដែលអង្គជំនុំជម្រះសម្រេចទៅលើសំណុំរឿងនេះ យើងមិនអាចមិនគិតអំពីភាពយូរយារណាស់មកហើយនៃអង្គហេតុបានទេ។ អស់លោក លោកស្រីចៅក្រមកាត់ក្តីលើរឿងហេតុដែលកើតឡើងតាំងពីយូរយារណាស់មកហើយ គឺថាមានហួស -- គឺជាង៣៨ឆ្នាំមកហើយ។ គឺអាចតាំងពីឆ្នាំ ១៩៧៥ ទៀតនោះ។

ចំពោះខ្ញុំអង្គជំនុំជម្រះអាចនិយាយថា ខ្ញុំមើលរឿងរ៉ាវតាមទស្សនៈរបស់ខ្ញុំផ្ទាល់ ក៏ប៉ុន្តែខ្ញុំឯង ខ្លួនឯងផ្ទាល់នេះនៅថ្ងៃនេះដែលមានអាយុ៤៧ឆ្នាំ ខ្ញុំមិនអាចរៀបរាប់រឿងរ៉ាវឲ្យបានច្បាស់លាស់ពាក់ព័ន្ធទៅនឹងហេតុការណ៍ជាក់លាក់ណាមួយដែលកើតមានចំពោះជីវិតរបស់ខ្ញុំនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ ១៩៧៩បានទេ។ ខ្ញុំមិននិយាយវែងឆ្ងាយអំពីរឿងចំណុចនេះទេ ក៏ប៉ុន្តែរយៈកាលនេះគឺមិនមែនជារឿងលេងសើចទេចំពោះខ្ញុំនោះ។

[១១:០៨:០៤]

ចំពោះខ្ញុំ និងចំពោះក្រុមរបស់យើង គឺយើងមានអារម្មណ៍ថាឯកសារដើមនៃសំណុំរឿងដែលអង្គជំនុំជម្រះកំពុងតែកាត់សេចក្តីនៅថ្ងៃនេះ គឺថាមានតួនាទីសំខាន់ណាស់នៅក្នុងការជំនុំជម្រះក្តីយើងនេះ។ គឺថាមានតួនាទីសំខាន់មែនទែន ក៏ប៉ុន្តែអស់រយៈពេលពីរឆ្នាំនៃការកាត់សេចក្តីនៅក្នុងសវនាការយើងនេះ គឺយើងបានឃើញតែឯកសារដើមតែពីរគត់។ គឺមិនមែនជាកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ផង ដែលជាឯកសារដ៏សំខាន់នៃរឿងក្តីនៃយើងនេះ ហើយយើងមានតែឯកសារហ្វូតូកូពី ឯកសារថតចម្លង ឬក៏ឯកសារស្កេន។ ឯកសារនុ៎ង ឯកសារពីរនុ៎ង គឺជាឯកសារសារព័ត៌មានដែលផ្សព្វផ្សាយឃោសនាអំពីរបបខ្មែរក្រហម។ ហើយអស់រយៈពេលពីរឆ្នាំដែលខ្ញុំអាចជួយលោក ខៀវ សំផន តាមដែលខ្ញុំអាចធ្វើទៅបាននោះ ថាខ្ញុំមិនដែលមើល -- ខ្ញុំមិនដែលឃើញសំណុំរឿងទេ។ ខ្ញុំឃើញតែឯកសារស្កេន ឬក៏ឯកសារថតចម្លងដោយផ្នែកតែប៉ុណ្ណោះ មិនដែលឃើញមានឯកសារដើមនោះទេ។ មាត្រា៨៦ នៃវិធានផ្ទៃក្នុងចែងថា៖ "នៅគ្រប់ពេលវេលាទាំងអស់ ភាគីមានសិទ្ធិពិនិត្យមើលសំណុំរឿង និងថតចម្លងសំណុំរឿង"។ ដូច្នេះមានន័យថា សំណុំរឿងនេះអាចបើកឲ្យពិគ្រោះ ហើយដែលជាឯកសារដែលត្រូវតែមាន

នៅកន្លែងណាមួយ។ ក៏ប៉ុន្តែយើងឃើញថា ឯកសារសំណុំរឿងដើមនោះដូចជាបាត់ទៅហើយ យើងមិនដឹងថា ឯកសារដើមនុ៎ងនៅឯណាទេ។ ហើយយើងមានតែជាឯកសារកុំព្យូទ័រ ដែលធ្វើឡើង ដែលជាការស្កេនយកទៅដាក់នៅក្នុងប្រព័ន្ធកុំព្យូទ័រ ប្រព័ន្ធព័ត៌មានវិទ្យានោះ។

[១១:១០:០៩]

កាលពីព្រឹកមិញនេះ នៅពេលដែលខ្ញុំមកដល់តុលាការយើងតាមផ្លូវមួយដែលខ្ញុំមិនដែលធ្លាប់ដើរនោះ។ ក៏ប៉ុន្តែព្រឹកមិញ ខ្ញុំដើរតាមទ្វារហ្នឹង គឺថាទ្វារហ្នឹង គឺទ្វារខាងមុខទ្វារគោលហ្នឹង ហើយនៅពេលដែលឆ្លងខាងសន្តិសុខហើយ ខ្ញុំឃើញមានពានរង្វាន់មួយដាក់នៅក្នុងកញ្ចក់។ ហើយយើងតាំងពានហ្នឹងគឺថាបង្ហាញអំពីការបានទទួលពានរង្វាន់ ឆ្នាំ២០០៩ នៃបច្ចេកវិទ្យាជាន់ខ្ពស់នៅក្នុងសវនាការយើងនេះ។ នៅពេលដែលខ្ញុំដើរទៅមុខទៀតទៅ ខ្ញុំដឹងថាវាគឺជាពាន១ពានវេទមន្ត ពានរហស្សកម្មអីទេ។ គឺជាពានមួយដែលផ្តល់ឲ្យដល់អ្នកដែលបានធ្វើឲ្យបាត់ឯកសារដើមនៅក្នុងសំណុំរឿងនោះ ហើយដែលមានតែឯកសារកូពីទទួលបានពានដែរនោះ។

យើងត្រូវតែដាក់ឯកសារដើមនៅទីនេះ នៅក្នុងកណ្តាល នៅក្នុងបន្ទប់សវនាការហ្នឹង យើងមើលឃើញទាំងអស់គ្នា ឲ្យឃើញថាមានទាំងឯកសារភស្តុតាង ឯកសារអី យកមកដាក់នៅក្នុងហ្នឹងមកឲ្យភាគីទាំងអស់បានមើលឃើញទាំងអស់គ្នាមក។ ហើយជួនកាលទៅយើងអះអាងថា នេះជាច្បាប់ដើមឯកសារនៅសម័យនោះ ឬក៏ឯកសារកូពី។ យើងចង់ដឹងថាតើឯកសារហ្នឹងទទួលបានមកយ៉ាងម៉េច? នៅពេលដែលយើងយកឯកសារហ្នឹងមកតាំងពីដើមដំបូងនៃការរកឃើញឯកសារហ្នឹង ហើយនិងបញ្ចូលមកក្នុងឯកសារកុំព្យូទ័ររបស់តុលាការនោះ។

[១១:១១:៤០]

នៅទីនេះ គឺថាយើងដូចជាមិនអាចដឹងអ៊ីចឹងបានទេ។ ឯកសារដើមនោះគឺថាបាត់អស់ហើយ។ ហើយខ្ញុំធ្វើការប៉ាន់ស្មានទេនៅពេលដែលគេផ្តល់ឯកសារឲ្យខ្ញុំមួយ ឬក៏ខាងសហព្រះរាជអាជ្ញាបង្ហាញឯកសារអីមួយនោះ ខ្ញុំគិតស្រមៃខ្លួនឯងថា ត្រូវប្រើប្រាស់ឯកសារណា? ខ្ញុំត្រូវស្វែងរកតាមអ៊ិនធើណេតឬតាមកុំព្យូទ័រដើម្បីពិនិត្យមើលថា តើសហចៅក្រមស៊ើបអង្កេតនោះ គាត់បានទទួលឯកសារណាមួយនោះមកតាមរបៀបណា? សូម្បីតែចំនួនឯកសារនៃការស៊ើបអង្កេតនោះ ខ្ញុំមិនដឹងផង នៅតែជាអាថ៌-កំបាំងផង រហូតមកថ្ងៃហ្នឹង ខ្ញុំមិនដឹងថាឯកសារសំណុំរឿងមិនដឹងមានប៉ុន្មានទំព័រផង? មិនដឹងថា ៥០០.០០០ទំព័រ ឬក៏១លានទំព័រ ខ្ញុំអត់ដឹងទាល់តែសោះ។

ចំណុចនេះ ថាយើងមិនអាចពិនិត្យផ្ទៀងផ្ទាត់បានទេ។ ហើយដោយសារតែហេតុអ៊ីចឹងហើយ ប្រហែលជាអ៊ីចឹងហើយបានអង្គជំនុំជម្រះបានផ្តល់ពេលឲ្យយើងតិចតួចក្នុងការពិនិត្យមើលទៅលើឯកសារទាំងអស់នោះ។ ខ្ញុំចង់ចាំនូវសវនាការមួយកាលពីខែធ្នូ ឆ្នាំ២០១១ នៅក្នុងពេលនោះ លោកប្រធានៗប្រកាសថា ការពិភាក្សាទៅលើយថាភាពនៃឯកសារនៅក្នុងសំណុំរឿងនោះ នឹងប្រព្រឹត្តទៅនៅមុនពេលចេញដីកាដំណោះស្រាយ។ ក៏ប៉ុន្តែ ខ្ញុំគិតថាដូចជាមិនអ៊ីចឹងទេ។ ខ្ញុំក៏ចាំច្បាស់អំពីសវនាការនៅពីខែមករា ឆ្នាំ២០១២ ពាក់ព័ន្ធទៅនឹងសេចក្តីជំទាស់មិនទទួលឯកសារ ហើយនៅពេលនោះ គឺលោកប្រធានបានប្រកាសថា អង្គជំនុំជម្រះយល់ឃើញថា នៅពេលដែលជនជាប់ចោទណាមួយ ស្នើសុំឲ្យគេបង្ហាញដើមឲ្យខ្លួននោះ គឺមានន័យថា ជនជាប់ចោទហ្នឹង គឺរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបហើយ។ គឺមិនត្រឹមត្រូវទេ។ នេះគឺជាការលំបាកដែលយើងខ្ញុំបានជួបប្រទះ ពីព្រោះថា នៅពេលដែលជនជាប់ចោទសុំឲ្យគេបង្ហាញឯកសារដើមនោះ ប្រសិនបើមាន។ គឺគាត់ចង់ឲ្យមានការពិភាក្សាគ្នាឲ្យបានស៊ីជម្រៅទៅលើឯកសារនោះទៅវិញទេ។ មិនមែនបានន័យថា គាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបទេ។ ដូច្នេះ ការពិភាក្សានេះគួរតែមានមុនពេលជំនុំជម្រះក្តី។ យើងចង់ឲ្យមានការពិភាក្សាបែបហ្នឹងចំពោះឯកសារនីមួយៗដែលបានដាក់។ ហើយមិនមែនយកមកប្រមូល មកដាក់ឯកសារទាំងដុំៗឲ្យយើងពិនិត្យមើលនោះទេ។ ហើយក៏សវនាការដែលនិយាយអំពីឯកសារគន្លឹះអីទាំងអស់ហ្នឹង គឺថាយើងបានតវ៉ា យើងបានរិះគន់ជាច្រើនដងជាច្រើនសាមកហើយ។ ពីព្រោះតាំងពីដំបូងឡើង អង្គជំនុំជម្រះនិយាយថា សវនាការលើឯកសារគន្លឹះហ្នឹងសម្រាប់តែសាធារណជន។ ហើយមេធាវីការពារក្តីមិនឲ្យនិយាយទេ។ ហើយរហូតដល់ពេលក្រោយមកទៀតនោះ អង្គជំនុំជម្រះប្រកាសថាសវនាការហ្នឹងគឺជាផ្នែកមួយនៃការជំនុំជម្រះរបស់យើងនេះ។

[១១:១៥:៥៥]

ពិតណាស់ វិធាន៨៧(១)នៃវិធានផ្ទៃក្នុង គឺភស្តុតាងទាំងអស់គឺត្រូវតែទទួលយក។ ក៏ប៉ុន្តែនៅក្នុងរឿងក្តីដ៏ធ្ងន់ធ្ងរ និងរសើបនេះ តើចៅក្រមអាចជៀសវាងមិនសួរថាតើឯកសារហ្នឹងមកពីណា? មានប្រភេទយ៉ាងណា? ហើយប្រភពនៃការថែរក្សាឯកសារទាំងអស់ហ្នឹង ដែលសហព្រះរាជអាជ្ញាស្នើសុំមកផ្អែកជាមូលដ្ឋាន ដើម្បីបង្ហាញអំពីជំនឿជឿជាក់របស់គាត់ទៅលើឯកសារនោះ ខ្ញុំមិនជឿថាអ៊ីចឹងទេ ពីព្រោះថាសហព្រះរាជអាជ្ញាមិនមែនជាមិត្តភក្តិរបស់ចៅក្រមទេ។ ពួកគាត់សុំឲ្យអង្គជំនុំជម្រះប្រកាសទោសជាអតិបរិមាដោយផ្អែកតែទៅលើឯកសារខ្សែភាពយន្ត ខ្សែវីដេអូ ទៅលើឯកសារស្កេន ឯកសារ

ថតចម្លងនៃអត្ថបទកាសែត ឬក៏សក្ខីកម្មដែលកើតមានតាំងពី៣៨ឆ្នាំមុន ហើយនិងផ្អែកតែទៅលើឯកសារដើមតែពីរគត់។ យើងគួរកត់សម្គាល់ថា វាអាចមានគ្រោះថ្នាក់ក្នុងការជឿជាក់ទៅលើអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងនោះ។

ខ្ញុំសូមផ្តល់ឧទាហរណ៍មួយនៅថ្ងៃនេះ។ មេធាវីការពារក្តី នួន ជា បានលើកឡើងច្រើនមកហើយ ហើយយើងព្យាយាមផ្តល់នូវឧទាហរណ៍ផ្សេងៗទៀត។ កាលពីថ្ងៃ១៣ ខែមិថុនា ឆ្នាំ២០១២ តាមរយៈសេចក្តីសម្រេចដែលមានលេខ E166/1/4 អង្គជំនុំជម្រះសម្រេចអំពីតម្លៃជាភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយរបស់សាស្ត្រាចារ្យ ឃៀវនិន។ សាស្ត្រាចារ្យនេះបានបដិសេធមិនសហការជាមួយនឹងអង្គជំនុំជម្រះ ហើយនិងមិនព្រមមកទីក្រុងភ្នំពេញទេ។ ហើយនៅក្នុងសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបញ្ជាក់ថា ខ្ញុំសូមដកស្រង់៖ “យោងតាមវិធានដើម្បីធានានូវការជំនុំជម្រះក្តីដោយយុត្តិធម៌ក្នុងកម្រិតអន្តរជាតិនោះ អង្គជំនុំជម្រះពុំអាចកោះហៅសាស្ត្រាចារ្យ ឃៀវនិន បាន”។ ដូច្នេះសក្ខីកម្មរបស់គាត់នោះ គឺមិនមានតម្លៃជាភស្តុតាងនៅក្នុងសំណុំរឿង០០២/០១ នេះ។ ដោយសារតែភាគីមិនអាចលើកការជំទាស់តទល់ណាមួយជាមួយនឹងសាស្ត្រាចារ្យរូបនេះបាន។ ដូច្នេះ តើសហព្រះរាជអាជ្ញាគិតគូរទៅលើសេចក្តីសម្រេចនេះដែរឬទេ?

[១១:១៧:៣៨]

ដើម្បីពិនិត្យផ្ទៀងផ្ទាត់នោះ យើងស្នើសុំឲ្យអង្គជំនុំជម្រះមិនត្រឹមតែស្តាប់ទេ គឺថាឲ្យពិនិត្យមើលទៅលើសារណាសន្និដ្ឋានបញ្ចប់ដែលមាន៥៣៨ទំព័រ។ ហើយដែលមាន៣១១នេះ គឺថាសម្រាប់តែកំណត់សម្គាល់ជើងទំព័រ២៩០០។ សារណានេះខ្ញុំបាននិយាយរួចមកហើយថា អង្គជំនុំជម្រះបានសម្រេចថា ទាំងលោក ខៀវ សំផន ទាំងមេធាវីរបស់គាត់ហ្នឹង គឺថាមិនបាច់ចាំអានក្នុងភាសាដែលខាងយើងខ្ញុំអាចយល់បានទេ។ ហើយសារណាហ្នឹងក៏បានបញ្ជាក់ដែរថា យើងមានពេលតែ១៨ថ្ងៃប៉ុណ្ណោះដើម្បីឲ្យយល់អំពីអ្វីដែលបានសរសេរនៅក្នុងនោះ។ ដូច្នេះ ចំណុចសំខាន់ៗនៃទស្សនៈរបស់សហព្រះរាជអាជ្ញានោះ គឺមានតែគាំទ្រតាមរយៈឯកសារជាលាយលក្ខណ៍អក្សររបស់សាស្ត្រាចារ្យ ឃៀវនិន។ ហើយដែលអង្គជំនុំជម្រះបានប្រកាសរួចមកហើយថា សេចក្តីសន្និដ្ឋានរបស់គាត់ហ្នឹង មិនមានតម្លៃជាភស្តុតាងទេ ពីព្រោះគាត់មិនបានបង្ហាញខ្លួនទេ។ នេះជាឧទាហរណ៍បីក្នុងចំណោមឧទាហរណ៍ផ្សេងទៀត ដែលខ្ញុំអាចរកបានភ្លាមៗ ដែលក្នុងនោះគឺសហព្រះរាជអាជ្ញាបាននិយាយថាសាក្សីទាំងអស់នោះសំខាន់។

[១១:១៨:៥៧]

កថាខណ្ឌ៥២១ ជើងទំព័រ២០១២ លោក ខៀវ សំផន ទំនងជាត្រូវបានកោះហៅឲ្យចូលរួមនៅក្នុងវគ្គរៀនសូត្រមួយដែលមានមនុស្ស៥០០នាក់។

កថាខណ្ឌ៥៥៤ ជើងទំព័រ២២៨២ លោក ខៀវ សំផន ទំនងជាបាននិយាយនៅខែធ្នូ ឆ្នាំ១៩៧៥ ដើម្បីព្យាយាមប៉ុនប៉ងផ្តល់យុត្តកម្មអំពីការជម្លៀស។

កថាខណ្ឌ៦៤៣ កំណត់សម្គាល់ជើងទំព័រ ២៧៩៥ នៅឆ្នាំ១៩៩២ លោក ខៀវ សំផន ទំនងជាបានគំរាមកំហែងហិង្សាទៅលើជនជាតិភាគតិច។

អស់លោក លោកស្រីចៅក្រម ជ្រាបស្រាប់ហើយអំពីចម្លើយរបស់លោក ឆាំង យុ ដែលជាប្រធាននៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការដែលមានប្រភពឯកសារសំខាន់នៃឯកសារ ដែលបង្កើតបានជាសំណុំរឿងរបស់យើងនៅក្នុងកុំព្យូទ័រនោះ។ ហើយនៅក្នុងសវនាការយើងនេះ លោក ឆាំង យុ បានបដិសេធមិនបង្ហើបប្រាប់អង្គជំនុំជម្រះអំពីកន្លែងសម្ងាត់ផ្សេងៗដែលបានរក្សាឯកសាររបស់គាត់ គឺឯកសារដើម គឺបានន័យថា គាត់អង្គាល់នុំង គឺថាគាត់មិនព្រមប្រាប់ទេថា ឯកសារដើមទុកនៅកន្លែងណានោះ។ ដូច្នេះ តុលាការក៏ដូចជាភាគីយើង គឺខ្ញុំទទួលបានតែឯកសារថតចម្លង និងឯកសារស្កេនតែប៉ុណ្ណោះ។

[១១:២០:៥០]

អស់លោក លោកស្រីចៅក្រម ក៏នៅចងចាំផងដែរអំពីចម្លើយរបស់គាត់នៅពេលដែលខ្ញុំសួរថា ហេតុអ្វីក៏យើងត្រូវតែជឿគាត់ នៅពេលដែលគាត់អះអាងថាគាត់មានឯកសារដើម។ ហើយគាត់បានពន្យល់ប្រាប់យើងខ្ញុំប្រកបដោយមោទនភាពបំផុតនោះ ថាដើម្បីសម្រេចថាឯកសារណាមួយមានយថា-ភាព ឬក៏អត់ នៅពេលដែលគាត់ទទួលតាមរយៈប្រៃសណីយ៍ ឬក៏តាមរយៈប្រភពផ្សេងនោះ គឺថាគាត់គ្រាន់តែហិតក្លិន ស្តាប់តែសំឡេងទៅគាត់ដឹងថា ឯកសារហ្នឹងជាឯកសារដើម គឺថាគាត់មើលឯកសារហ្នឹង ដូចជាគាត់ហូបអាហារពេលព្រឹកអ៊ីចឹង។ អភ័យទោសផង ខ្ញុំគិតថា -- យើងនិយាយអំពីយើងមានសិទ្ធិក្នុងការព្រួយបារម្ភថា ព្រួយបារម្ភតម្លៃជាភស្តុតាងនៃឯកសារដែលត្រូវបានពិភាក្សានៅក្នុងសំណុំរឿងកុំព្យូទ័រយើង តាមរយៈការខ្សែសង្វាក់នៃការថែរក្សាឯកសារ ដែលត្រូវបានរក្សាការសម្ងាត់ហើយដែលផ្អែកទៅលើនោះ។ លោកស្រីសហព្រះរាជអាជ្ញា បានស្នើសុំឲ្យអង្គជំនុំជម្រះផ្អែកលើដើម្បីផ្តន្ទាទោសជនជាប់ចោទចាស់ជរាទាំងពីរដែលជាបិសាចនេះ ដែលឲ្យផ្តន្ទាទោសជាអតិបរមានោះ។

[១១:២២:១៧]

ជាសេចក្ដីសន្និដ្ឋាននៃរបស់ខ្ញុំនៅព្រឹកនេះ ខ្ញុំសូមរំឭកអំពីសម្ដីរបស់សហចៅក្រមស៊ើបអង្កេតចាស់គឺ ម៉ាកសែល ឡឺម៉ុងដ៍ ដែលគាត់បានទទួលស្គាល់នៅក្នុងសៀវភៅមួយដែលនិយាយអំពីបទពិសោធន៍របស់គាត់នៅក្នុងតុលាការនេះ។ គាត់បានសរសេរដីកាដំណោះស្រាយនេះ គឺថាសម្រាប់ប្រវត្តិសាស្ត្រគាត់ -- ខ្ញុំប្រើពាក្យថា ទទួលស្គាល់ពីព្រោះថា ដីកាដំណោះស្រាយ -- បើយើងពិនិត្យមើលទាំងស្រុងឬក៏មួយផ្នែកដែលអង្គជំនុំជម្រះបានកាត់យក ដើម្បីមកបំបែកនីតិវិធីនេះ គឺថាសៀវភៅហ្នឹងគ្រាន់តែជាអវតារនៃសៀវភៅរបស់លោក ហ្វីលីព ស្សូត។ ហើយប្រសិនបើយើងពិនិត្យមើលទៅលើភស្តុតាងដែលសហព្រះរាជអាជ្ញាបានបង្ហាញនៅក្នុងសេចក្ដីសន្និដ្ឋានចុងក្រោយរបស់ខ្លួនោះ យើងត្រូវតែសន្និដ្ឋានថារយៈពេលពីរឆ្នាំនៃសវនាការនេះ គឺថាមិនមានអីផ្លាស់ប្ដូរធំដុំទេ។ ក៏ប៉ុន្តែតុលាការយើងនៅទីនេះមិនមែនតុលាការសម្រាប់សរសេរប្រវត្តិសាស្ត្រទេ។ តុលាការមិនមានមុខងារប្រវត្តិសាស្ត្រទេ។ តុលាការនៅទីនេះ គឺដើម្បីផ្សះផ្សាជាតិ -- សូមទោស មិនមែនដើម្បីផ្សះផ្សាជាតិ គឺថាដើម្បីផ្ដល់យុត្តិធម៌ទៅតាមវិធាននៃការជំនុំជម្រះក្ដី ដោយផ្អែកទៅលើភស្តុតាងរឹងមាំ និងមិនអាចប្រកែកបាន។ សូមអរគុណ។

[១១:២៤:២០]

**កញ្ញា អង់តា ហ្គីសសេះ**

កាត់ផ្ដន្ទាទោសពួកគេឲ្យលឿនមុននឹងគេដែលស្លាប់ទៅ។ អស់លោក លោកស្រីចៅក្រម គឺអ៊ីចឹងហើយឬ ដែលមតិអន្តរជាតិគេរំពឹងចាំពីអស់លោក លោកស្រីចៅក្រម ដែលសហភាតារបស់ខ្ញុំបានលើកឡើងហើយ។ ចំពោះខាងការពារក្ដីនោះ ជាការពិតណាស់ យើងលែងឆោតល្ងង់ទៀតហើយ យើងដឹងថានៅពេលអ្នកផ្ដល់ជំនួយមកកន្លែងនេះដែលឃើញតុលាការនេះកំពុងតែឈឺហ្នឹង ហើយឲ្យដំណើរការនីតិវិធីនៅតែបន្តទៀតហ្នឹង។

យើងដឹងថាអ្វីដែលយើងអាចចាំអំពីចៅក្រមគឺថា សាលក្រមផ្ដន្ទាទោសមិនមានអ្នកណាម្នាក់នៅក្នុងសវនាការនេះនៅក្រៅថា នឹងមានការសាលក្រមផ្សេងក្រៅពីសាលក្រមផ្ដន្ទាទោសនេះទេ។ ហើយសាលក្រម -- ការផ្ដន្ទាទោសដោយឧបកិច្ចនេះចាប់តាំងពីបង្កើតតុលាការនេះមកនោះ នឹងផ្ដល់ថា -- ធ្វើឲ្យយើងមានអារម្មណ៍ថាយើងបំពេញការងារចប់ហើយក្នុងការបង្កើតប្រវត្តិសាស្ត្រនេះ។ ពីព្រោះថាវាជាភាពចម្រូងចម្រាស់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិដែលយើងគាំទ្រ លើកស្ទួយសិទ្ធិជន -- សិទ្ធិមនុស្សហើយជាពិសេសសិទ្ធិជនជាប់ចោទ ក៏ប៉ុន្តែជាទីបញ្ចប់ អ្វីដែលយើងកំពុងតែជម្រះសេចក្ដីនេះមិនមែនមនុស្សនៅក្នុងទំនួលខុសត្រូវរបស់ខ្លួន ទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ ក៏ប៉ុន្តែជានិមិត្តរូបទៅវិញ ពេល

ដែលគេត្រូវទទួលខុសត្រូវ។

[១១:២៦:០៦]

ខាងព្រះរាជអាជ្ញាគេនឹងឲ្យយើងនិយាយអំពីបរិបទប្រវត្តិសាស្ត្រ មើលទៅហាក់ដូចជាថាបរិបទប្រវត្តិសាស្ត្រហ្នឹងគ្រាន់តែនិយាយឲ្យតែគេចាប់អារម្មណ៍នោះ ហាក់ដូចជាថា បរិបទនេះមិនសំខាន់នោះ ព្រោះថាជាការ គឺថាត្រូវការធ្វើការជម្រះក្ដីលើប្រវត្តិសាស្ត្រតែម្ដង ពីព្រោះថាបរិបទប្រវត្តិសាស្ត្រនេះសំខាន់ អ៊ីចឹងយើងនឹងនិយាយអំពីបរិបទនេះ។ ប្រហែលជាមានរឿងមួយចំនួនដែលគេមិនចង់ស្ដាប់ ប្រហែលជាមានរឿងមួយចំនួនដែលរំខាន ប្រហែលជាមានរឿងមួយចំនួនដែលធ្វើឲ្យយើងមិនស្រួលចិត្ត ព្រោះពេលដែលយើងនិយាយអ៊ីចឹងហ្នឹងគឺថា ពេលយើងលើកចំណុចហ្នឹងគឺថាត្រូវតែថាកុំឲ្យដាច់ខាតពេក យើងមិនអាចគិតថា រឿងថាល្អដាច់អាក្រក់ដាច់ទេ ត្រូវតែនិយាយឲ្យចំចំណុចតែម្ដង។ ខាងការពារក្ដីគេដូចគេប្រាប់ថា មិនត្រូវនិយាយអ្វីរឿងដែលគេមិនសប្បាយចិត្ត ធ្វើរឿងដែលរំខានគេ ត្រូវនិយាយអំពីអ្វីដែលគេទាំងអស់គ្នាដឹង ហើយគេមិនហ៊ាននិយាយ។ ហើយអ៊ីចឹងបើនៅខាងការពារក្ដីនោះបានយ៉ាងម៉េច? ខាងការពារក្ដីគិតខុសពីហ្នឹងទាំងអស់ ក៏ប៉ុន្តែមិនមែននិយាយនេះតែខាងការពារក្ដីទេ អស់លោកលោកស្រីចៅក្រម គឺនិយាយសម្រាប់ចៅក្រមដែរ ក្នុងឋានៈជាចៅក្រមត្រូវគិតឲ្យខុសពីនេះ មិនមែនថាល្អដាច់អាក្រក់ដាច់ទេ។ ខ្ញុំដឹងថាគិតខុសពីនេះមិនជាការងាយស្រួលទេក្នុងសំណុំរឿងយើងនេះ ព្រោះថាមានការឈឺចាប់សម្បើមណាស់។

[១១:២៨:០៣]

ការឈឺចាប់របស់ប្រជាជនកម្ពុជាដែលយើងបានឃើញនៅទីនេះ នៅក្នុងសាលសវនាការនេះពិតណាស់មតិដូចជាលោកទាំងអស់នោះ អស់លោកចៅក្រម។ ខ្ញុំក៏ដោយដូចត្រូវតែមានអ្នកទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងអស់នេះ តើអ្នកណាត្រូវទទួល ហើយធ្វើរបៈទទួលយ៉ាងម៉េច? ដូច្នេះយើងត្រូវតែគេចឲ្យផុតពីបុរេវិនិច្ឆ័យ យើងអាចគិតទៅបានដូចយើងទាំងអស់គ្នា ហើយក៏ប៉ុន្តែយ៉ាងណាមុននឹងមកដល់ទីនេះយើងសុទ្ធតែមានបុរេវិនិច្ឆ័យ ក៏ប៉ុន្តែខាងការពារក្ដីលោក ខៀវ សំផន សុំឲ្យអស់លោកទាំងអស់គ្នាបំបាត់បុរេវិច្ឆ័យនេះចោលទាំងអស់ទៅ ហើយគ្រាន់តែពិចារណាសំណុំរឿងឲ្យសមរម្យនៅក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០២/០១នេះ។ ហើយយើងនឹងឃើញ -- យើងនឹងមើលឃើញរឿងរ៉ាវច្បាស់ពីព្រោះថាយើងមិនអាចមើលឃើញតែថា ចំណុចកំពូលមួយទេ ពីព្រោះថាកាលណាកាត់ការជំនុំជម្រះមួយ ឬក៏ការពារក្ដីនៅក្នុងក្ដីយ៉ាងដូច្នេះ ឬក៏ថាចូលរួមក្នុងរឿងក្ដីរបៀបនេះតម្រូវឲ្យយើងបោះបង់បុរេ

វិនិច្ឆ័យចោល។

ការកាត់ទោសឲ្យលឿននេះ ព្រោះឲ្យមុនពេលពួកគាត់ស្លាប់នោះ តើមានមូលដ្ឋានអ្វីទៅក្នុងការធ្វើយ៉ាងដូច្នេះ? តើត្រូវ -- ដូចដែលការណែនាំនោះ គឺត្រូវតែថារកយ៉ាងម៉េចឲ្យឃើញដូចគំនិតបុរេវិនិច្ឆ័យរបស់យើង ឬក៏យ៉ាងម៉េច? ឬក៏ថារយៈពេលសវនាការជិតពីរឆ្នាំហើយនេះ ត្រូវតែបំភ្លេចចោល ហើយត្រូវតែពិនិត្យតែច្បោលៗតែប៉ុណ្ណោះ ឬក៏យ៉ាងម៉េច?

[១១:៣០:០៥]

ជាការពិតណាស់ យើងខ្ញុំសូមនិយាយយ៉ាងដូច្នេះ ជូនដល់តុលាការថា រយៈពេល២០ខែមក ហើយមានចម្លើយជាច្រើន មានការជំទាស់ជាច្រើន នៅពេលចុងក្រោយនៃដំណើរការនីតិវិធីនេះ យើងចង់សួរថាតើនៅទីនេះ គេចង់ស្តាប់គំនិតផ្សេងពីបុរេវិនិច្ឆ័យនេះដែរឬទេ? ហើយនៅក្នុងពេលនេះតែម្តង អស់លោក លោកស្រីចៅក្រម! ខ្ញុំនឹកទៅដល់ ហ្សាក់ វែកហ្សេស ដែលជាសហភាតារបស់ខ្ញុំ គាត់ជានិមិត្តរូបនៃការការពារក្តី ក្រឡុករឿងក្តី ដែលគាត់ -- ហើយខ្ញុំគិតថាយុត្តិសាស្ត្រនេះ នៅក្នុងរឿងក្តីយើងនេះ គឺការពារក្តីរបៀបនេះមានខ្លឹមសារ ព្រោះថាយើងត្រូវតែកាត់ផ្តាច់ខ្លួនឲ្យផុតពីបុរេវិនិច្ឆ័យ។ នៅពេលដែលយើងដឹងថា យើងនោះ នឹងត្រូវបានគេកាត់ទោសមុននឹងការជំនុំជម្រះសេចក្តីទៀតផង។ អ៊ីចឹងហើយ គឺថាមាគ៌ារបស់ វែកហ្សេស នេះមានន័យ។ មិនមែនត្រឹមតែថា គាត់មានទេពកោសល្យជាមេធាវីក្នុងការការពារក្តីនោះទេ ក៏ប៉ុន្តែតាមរយៈប្រវត្តិដែលគាត់ឆ្លងកាត់ទាំងឡាយនោះ ជាច្រើនឆ្នាំមកហើយនោះ គឺថាធ្វើឲ្យយើងមានការព្រួយបារម្ភខ្លាំង ដោយសារនៅទីនេះ និយាយតែអំពីបរិបទប្រវត្តិ-សាស្ត្រ ហើយមិនគិតពីអង្គហេតុដែលជារឿងរ៉ាវរបស់យើងទេ។

ខ្ញុំមិនជំទាស់អីទេ ដែលព្រះរាជអាជ្ញាគេលើកឆ្កាដៃឆ្កាជើង ដើម្បីឲ្យគេចាប់អារម្មណ៍នោះ។ ខ្ញុំចង់ឲ្យគេពន្យល់ថាពីមូលហេតុថាហេតុអីបានជាប្រជាជនអត់បាយ ដោយសារកូនក្តីខ្ញុំនេះ? សូមពន្យល់កន្លែងនេះ។ យើងត្រូវតែចាំថា មានជនជាប់ចោទផ្សេងទៀតមិននៅក្នុងបន្ទប់ជំនុំជម្រះក្តីទេ ពីព្រោះថាខ្វះជនជាប់ចោទ ខ្ញុំនិយាយពី អៀង ធីរិទ្ធ ពី អៀង សារី នោះទេ ដែលយើងទាំងអស់គ្នាដឹងហើយថាគាត់មានជោគវាសនាយ៉ាងម៉េចនោះ។ ក៏ប៉ុន្តែ ខ្ញុំនិយាយអំពីអ្នកទទួលខុសត្រូវនៅពេលដែលមានការជម្លោះនៅតាមព្រំប្រទល់ ហើយនិងនៅក្នុងប្រទេសកម្ពុជា។

[១១:៣២:៣៨]

ខ្ញុំនិយាយអំពីអ្នកទទួលខុសត្រូវនៅក្នុងប្រទេសកម្ពុជា។ ខ្ញុំនិយាយអំពីការបង្ក្រាបទៅលើអ្នក

បះបោរកសិករ។ ខ្ញុំនិយាយអំពីសេចក្ដីសម្រេចសង្គ្រាមត្រជាក់ រវាងមនោគមន៍វិជ្ជាទាំងពីរហ្នឹង។ សង្គ្រាមត្រជាក់នេះ ជាដើមហេតុនៃសោឌនាកម្មនៃប្រទេសកម្ពុជា។ យើងត្រូវតែបញ្ចូលប្រធានាធិបតីអាមេរិកាំងផងដែរនៅក្នុងការជំនុំជម្រះនេះ ព្រោះថាបង្កើតឲ្យមានសង្គ្រាម មានទម្លាក់គ្រាប់បែក ហើយយើងនិយាយអំពីការទម្លាក់គ្រាប់បែកទាំងអស់នេះ ហាក់ដូចជានិយាយទៅឃើញថា មើលទៅដូចមិនថាមិនសំខាន់អ៊ីចឹង។ ហើយបើយើងនិយាយអំពីឆ្នាំ៧០គត់ -- អ៊ំ! ៧៥, ៧៩នេះ មិននិយាយពីទម្លាក់គ្រាប់បែបនេះ និយាយយ៉ាងម៉េចហ្នឹងកើត វាមាននិមិត្តរូបខ្មែរក្រហម។ អ៊ីចឹងត្រូវតែមានអ្នកណាម្នាក់មកពន្យល់ពីមូលហេតុ ហើយនិងទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងអស់។ ក៏ប៉ុន្តែមានទិដ្ឋភាពនៅក្នុងសំណុំរឿងយើងនេះ សង្គ្រាមមនោគមន៍វិជ្ជា វាកន្លងផុងទៅឆ្ងាយហើយ ប៉ុន្តែសង្គ្រាមត្រជាក់នេះស្ថានភាពភូមិសាស្ត្រនយោបាយនេះស្ថិតនៅក្នុងចំណុចជាចំណុចសំខាន់នៃការជម្រះសេចក្ដីនេះផង។ តែខាងព្រះរាជអាជ្ញាគេចំអក និយាយថាចេះតែភ័យទៅ មេដឹកនាំខ្មែរក្រហមចេះតែភ័យទៅ ខៀវ សំផន ចេះតែភ័យទៅខ្លួនឯង។ អ៊ីចឹង យើងនឹងត្រឡប់មកនិយាយពីចំណុចនេះនៅពេលក្រោយ។

[១១:៣៤:១១]

យើងអាចនិយាយពីចំណុចនេះបាន និយាយថាអ៊ីចឹងបានដោយសារតឡូវយើងឆ្នាំ២០១៣ហើយ ក៏ប៉ុន្តែបើនៅឆ្នាំ១៩៥០, ៦០, ៧០ នេះ យើងដឹងហើយថា ការតស៊ូដើម្បីឯករាជ្យហ្នឹងវាយ៉ាងម៉េច។ នៅអាហ្វ្រិកក៏ដោយ នៅអាស៊ី យើងហ្នឹងក៏ដោយ យើងត្រូវរំឭកពីចំណុចហ្នឹង។ អ៊ីចឹងទិដ្ឋភាពពិតនៃសង្គមនៅសម័យនោះ អ៊ីចឹងឯងមានការភ័យខ្លាចខ្លាំង។ ការសើចចំអកលើប្រវត្តិសាស្ត្រនេះ អស់លោក លោកស្រីចៅក្រមជាទីគោរព! គឺថា ខៀវ សំផន កាលណោះ ដែលគាត់ជានិមិត្តរូប ជាអ្នកតំណាងឲ្យរដ្ឋកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយនិមិត្តរូបដោយគ្មានអំណាចនេះ អ៊ីចឹងការសើចចំអកនៃព្រហ្មលិខិតនេះ នៃប្រវត្តិហ្នឹង គឺថាធ្វើឲ្យគាត់ស្ថិតនៅក្នុងសាលជំនុំជម្រះនេះឯង។ មានតែគាត់មួយទេ ដែលមកឲ្យគេកាត់ទោសនៅទីនេះ។

ប៉ុន្តែលោកប្រធាន អស់លោក លោកស្រីចៅក្រម កុំឲ្យច្រឡំលើងអការៈក្រៅ។ ការមានវត្តមានតែម្នាក់ឯងរបស់គាត់នេះ ក៏សូមលោកស្រីចៅក្រមកុំច្រឡំ លោក ខៀវ សំផន បាននិយាយហើយថា គាត់មិនមែនជាខ្មែរក្រហមតែម្នាក់ឯងនោះទេ។ គាត់មានការសន្យា ហើយមានខ្សែជីវិត ហើយនិងតួនាទីដែលមិនដូចនឹងសហព្រះរាជអាជ្ញាបានពិពណ៌នោះទេ។ ហើយដើម្បីឲ្យយល់ចំណុចទាំងអស់នេះ ឬខ្សែជីវិតគាត់នេះ ហើយបរិបទប្រវត្តិសាស្ត្រដែលចំពោះយើងមិនមែនថាវា -- មិនមែនអត់សំខាន់ទេ

ក៏ប៉ុន្តែវាថែមទាំងជាប្រភពនៃរឿងសោងនាកម្មផង។ ពីព្រោះថាបើយើងចង់យល់ពីអ្វីដែលកើតឡើងចន្លោះ៧៥-៧៩ នោះ។ យើងត្រូវតែនិយាយអំពីតថភាពដែលកើតឡើងនៅ៤០ឆ្នាំមុននេះ។ ហើយយើងក៏ត្រូវចងចាំផងដែរថា ចំណោទបញ្ហាគឺយ៉ាងដូច្នេះ។ តើយើងចង់កាត់ទោសមនុស្សម្នាក់ ឬក៏ចង់កាត់ទោសប្រវត្តិសាស្ត្រ។

[១១:៣៦:២៤]

យើងចង់កាត់សេចក្ដីលើមនុស្សម្នាក់ ឬក៏កាត់សេចក្ដីលើប្រព័ន្ធនយោបាយមួយ។ តើយើងចង់បានភស្តុតាងច្បាស់លាស់ ឬក៏ចង់បានអ្វីដែលនិយាយជាមិនច្បាស់លាស់ទេ ឬក៏គ្រាន់តែចង់និយាយថាគោលបំណងគេ គឺថាគេចង់បំផ្លិចបំផ្លាញប្រជាជនកម្ពុជា ពីព្រោះថាកន្លែង ឬក៏មជ្ឈិមដែលថាមិនច្បាស់លាស់នោះ មានចេតនាប្រព្រឹត្តបទឧក្រិដ្ឋ។ តើយើងត្រូវវិភាគភស្តុតាង ហើយនិងសក្ខីកម្មឲ្យបានពេញលេញដោយបោះបង់ចោលនូវបុរេវិនិច្ឆ័យ ឬក៏ធ្វើដូចសហព្រះរាជអាជ្ញាដែលថាដកស្រង់មកដើម្បីឲ្យតែថាឈ្នះតែប៉ុណ្ណឹងឯង។ ខាងការពារក្ដីយើងហ្នឹងជាការច្បាស់ណាស់ថា យើងត្រូវតែពិនិត្យទាំងអស់។ រយៈពេល២០ខែកន្លងមកនេះត្រូវពិនិត្យទាំងអស់។ មានឯកសាររាប់ពាន់ទៀត ដែលត្រូវយកមកពិនិត្យពិចារណា ហើយមានចំណុចមួយចំនួន ហើយមានឯកសារច្រើនណាស់ដែលព្រះរាជអាជ្ញាអត់បានលើកឡើង ក៏ប៉ុន្តែឯកសារទាំងអស់នេះបង្ហាញពីការពិត។

ខែមេសា ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញ ហើយជិតរលំហើយ។ ហើយយើងនិយាយពីការជម្លៀសប្រជាជនចេញ។ ហេតុអ្វីក៏និយាយអំពីការជម្លៀសប្រជាជនចេញ? អ៊ីចឹងយើងត្រូវច្បាស់ទាំងអស់គ្នា។

[១១:៣៧:៥៦]

លោក ខៀវ សំផន តែងតែងបាននិយាយថា ហើយបញ្ជាក់ថែមទៀតថាគាត់មិនបានចូលរួមក្នុងការសម្រេចចិត្តជម្លៀសប្រជាជនចេញនៅឆ្នាំ៧៥នេះទេ។ ពីព្រោះថាយើងនៅក្នុងការកាត់សេចក្ដីយើងមានភស្តុតាងត្រូវពិនិត្យ យើងបានស្ដាប់សក្ខីកម្មច្រើនហើយ អ៊ីចឹងត្រូវតែពិនិត្យថាតើមានហេតុផលរបស់ខ្មែរក្រហមក្នុងការជម្លៀសនោះវាយ៉ាងម៉េចដែរ? តើយើងអាចទទួលយកបាន ឬក៏អត់? តើមានភស្តុតាងមួយចំនួនដែលថាគាំទ្រគំនិតរបស់គាត់ទាំងអស់? តែការសង្កេតនោះធ្វើឲ្យហេតុផលរបស់អ្នកដឹកនាំខ្មែរក្រហមនោះរលាយបាត់អស់ទៅហើយ។

យើងត្រូវច្បាស់ទាំងអស់គ្នានៅពេលដែលខ្ញុំលើកពីហេតុផលទាំងអស់នេះ មិនមែនជាការពារក្ដី

យឺតយ៉ាវទេ ដែលដូចដែលខាងព្រះរាជអាជ្ញាបានលើកឡើងទេ។ ក៏ប៉ុន្តែជាការវិភាគអ្វីដែលអស់លោក លោកស្រីចៅក្រមបានស្ដាប់នៅទីនេះ អ្វីដែលលោក លោកស្រីចៅក្រម បានអាននៅក្នុងឯកសារនៅចំពោះមុខរបស់អស់លោក លោកស្រីចៅក្រម។ អំណះអំណាងទាំងអស់នេះបានលើកឡើងតាមរយៈសាក្សីដែលបានមកផ្ដល់សក្ខីកម្មនៅទីនេះ។ មានហេតុផលដែលលើកឡើងដោយប៉ុល ពត និង នួន ជា។ នួន ជា នៅទីនេះ ប៉ុល ពត នៅក្នុងកិច្ចសម្ភាសន៍មួយ គាត់បានពន្យល់ថាការជម្លៀសហ្នឹងធ្វើឡើងដោយសារមិនដឹងច្បាស់ថាអាមេរិកាំងមានប្រតិកម្មមកវិញដែរឬអត់។ អ៊ីចឹងត្រូវតែបង្កើនស្បៀងអាហារដើម្បីប្រជាជន។ អ៊ីចឹងត្រង់ចំណុចនេះត្រូវតែចោទសួរខ្លួនឯងហើយថាតើស្ថានការណ៍នៅថ្ងៃទី១៧ មេសា ៧៥ហ្នឹងវាយ៉ាងម៉េច?

[១១:៣៩:៥៤]

មូលហេតុយោធា។ បាទមានមូលហេតុយោធាដែរ។ ខ្ញុំបានស្ដាប់ឮរឿងរ៉ាវច្រើនណាស់សហព្រះរាជអាជ្ញាបានរៀបរាប់ ហើយដើមបណ្ដឹងរដ្ឋប្បវេណីក៏បាននិយាយដែរ។ គេនិយាយថាការភ័យខ្លាចការទម្លាក់គ្រាប់បែកនេះគ្រាន់តែជាលេសទេ។ ហើយគេនិយាយថា ពុំមានថាភស្តុតាងដែលថាមិនមានការទម្លាក់គ្រាប់បែកដោយសារអត់មានទម្លាក់គ្រាប់បែកមែន។ ឥឡូវនេះ ខ្ញុំសូមបញ្ចប់សំណួរសួរថាតើៗតាំងពីណាពីណឹមកថា មានហានិភ័យអីបើទាល់តែវាមិនអាចកើតមានឡើងទេ? ទាល់តែវាកើតមានហើយបានយើងដឹងថា ពិតជាមានមែន។

លន់ នល់ គាំទ្រពីអាមេរិកាំង តើក្នុងបរិបទនេះ តើហេតុអីបាន ថាតើយើងអាចភ័យបានទេ បើលន់ នល់ មានការគាំពារពីអាមេរិកាំង ខ្លាចគេសងសឹកនេះ? យើងដាក់ខ្លួនក្នុងបរិបទហ្នឹង បានយើងអាចយល់បាន។ នេះជាអង្គហេតុដែលបានដាក់ជូនអង្គជំនុំជម្រះ។ នៅថ្ងៃទី០១ មេសា ៧៥ សម្ដេចសីហនុ បានឆ្លើយ -- ឯកសារ E3/1287, គាត់បានថ្កោលទោសល្បិចការ -- ទង្វើរបស់អាមេរិកាំងហើយនិងបរិវាររបស់អាមេរិកាំងនៅភ្នំពេញ។ ខ្ញុំសូមដកស្រង់៖ “អាមេរិកាំងបានបញ្ជូនយន្តហោះមកបាងកក ហើយបញ្ជូននាវាយោធាសង្គ្រាមមកដែរ មកសមុទ្រយើង ហើយពួកគេមក គេត្រៀមខ្លួននឹងមកជួយយោធា លន់ នល់”។ ខ្ញុំបញ្ចប់ការដកស្រង់។

[១១:៤១:៥២]

ថ្ងៃទី០១ មេសា ឆ្នាំ១៩៧៥ អង្កាល់នុំងយើងគិតថាមានមែន ព្រោះថាឃើញមានការបញ្ជូនកងទ័ពមកជួយអ៊ីចឹងមែន។ អង្គជំនុំជម្រះក៏ត្រូវតែចងចាំផងដែរថា ការទម្លាក់គ្រាប់បែកលើប្រទេស

កម្ពុជា នៅក្នុងរបបសាធារណរដ្ឋខ្មែរ មិនអាចធៀបៗ -- បរិមាណមិនអាចស្មើនឹងការទម្លាក់គ្រាប់បែកអាមេរិកាំងទេ ក៏ប៉ុន្តែក៏ច្រើនដែរ។ ស្ទីវ ហេដឌ័រ បានមកផ្ដល់សក្ខីកម្មនៅទីនេះ នៅឆ្នាំ២០១៣ យើងនេះខ្ញុំសូមដកស្រង់៖ "ការទម្លាក់គ្រាប់បែកអាមេរិកាំងបានឈប់នៅពេលនោះ ក៏ប៉ុន្តែកម្លាំងជើងអាកាសនៃកងទ័ពរបស់សាធារណរដ្ឋខ្មែរនៅតែបន្ត ហើយនិងផ្ដោងផងដែរទម្លាក់ទៅលើខាងខ្មែរក្រហម"។ ពិតណាស់ ដល់ថ្ងៃទី១៧ មេសា ៧៥ នោះវានៅតែជាសង្គ្រាមនៅឡើយទេ។ ក្រោយមកក៏នៅតែមានសង្គ្រាមដែរ ហើយត្រង់ចំណុចនេះ ខ្ញុំត្រូវតែកែប្រែ កែតម្រូវថា ពិតជាសង្គ្រាមមិនមែនគ្រាន់តែជាការបាញ់ផ្ដោងនោះទេ។

[១១:៤៣:០៣]

សង្គ្រាមអាវុធ -- សង្គ្រាម គឺបានន័យថា ការប្រឈមមុខគ្នាស្លាប់រស់រវាងសត្រូវ។ អ៊ីចឹងអត់មានអ្វីគួរឲ្យសរសើរទេ វាជាសង្គ្រាម។ អ៊ីចឹងយើងត្រូវចាំត្រង់ចំណុចនេះ។ យើងត្រូវចាំចម្លើយរបស់ស៊ីដនី ស្កេនប៊ឺក *(Sydney Schanberg)* ផងដែរ គាត់នៅទីនេះមុនថ្ងៃទី១៧ មេសា ៧៥ ហ្នឹងគាត់លើកឡើងដូចតទៅនេះ៖ ទាក់ទងទៅនឹងសង្គ្រាមដែលគ្មានអ្វីគួរឲ្យចាត់ថា គោរពសរសើរទេ គាត់និយាយពីថ្ងៃ១១ មករា ឆ្នាំ១៩៧៥ គាត់ឮសំឡេងមួយ-- ខ្ញុំសូមដកស្រង់៖ "សំឡេងផ្គរធ្វើឲ្យខ្ញុំភ្ញាក់ មានផ្លេកបន្ទោរ ហើយឃើញមានទម្លាក់គ្រាប់បែកជាចង្កោមៗ គឺជាគ្រាប់បែកប្រឆាំងនឹងមនុស្ស ព្រោះថាគ្រាប់មួយៗនោះមានគ្រាប់បែកតូចៗនៅក្នុងហ្នឹងទៀត ហើយដែលបំបែក ដែលផ្ទុះសម្លាប់មនុស្សលើផ្ទៃក្រឡាដ៏ធំ ហើយគ្រាប់បែកធម្មតានោះ គេទម្លាក់សម្រាប់តែលើគោលដៅមួយច្បាស់លាស់ទេ។ លើកទី១នេះហើយដែលកងទ័ពអាកាសខ្មែរសាធារណរដ្ឋបានប្រើគ្រាប់បែកប្រភេទនេះ ហើយមុននឹងទៀតហ្នឹងមានការទម្លាក់គ្រាប់បែកជាតិគីមីផងដែរ"។ ហ្នឹងហើយសង្គ្រាមៗ ព្រោះថាមិនមែនខ្មែរក្រហមទេដែលទម្លាក់គ្រាប់បែកទាំងអស់ហ្នឹងនោះ។ តើការភ័យខ្លាចថា ការទម្លាក់គ្រាប់បែកហ្នឹងអាចកើតមានទេ យើងត្រូវ -- យើងទាំងអស់គ្នាត្រូវចាំដែរ ភី ភួន បាននិយាយនៅទីនេះហើយ នៅថ្ងៃទី៣១ កក្កដា ឆ្នាំ២០១២ គេសួរគាត់ថាតើនៅពេល ក្នុងកិច្ចប្រជុំហ្នឹង ឬក៏កិច្ចប្រជុំផ្សេងទៀតហ្នឹងមាននិយាយអំពីហានិភ័យនៃការទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញដែរឬទេ? ចម្លើយរបស់គាត់៖ "បាទ គឺជាប្រធានបទដែលគេបានពិភាក្សានៅពេលនោះ ហើយនៅកន្លែងខ្លះហ្នឹងមានការទម្លាក់គ្រាប់បែក។ មានការប្រើប្រាស់យន្តហោះនៅសៀមរាប នៅកំពង់សោមជាដើម។ "ស៖ តើមានកម្លាំងតស៊ូរបស់ទាហានខ្មែរក្រហមទេ? ឆ៖ បាទ ពិតជាមាន។ ស៖ តើយើងអាចច្បាស់លាស់អំពីប្រតិកម្មរបស់ពួកគេទេរបស់

អាមេរិកាំងទេ? ឆ៖ យើងមិនដឹងទេ”។

[១១:៤៥:៤៥]

ឥឡូវមានសាក្សីមួយទៀតឈ្មោះ សោម សែ ដែលគាត់មកផ្ដល់សក្ខីកម្មនៅខែមករា ឆ្នាំ២០១៣ គាត់និយាយថាមានការភ័យខ្លាចអំពីការវាយលុករបស់ទាហានលន់ នល់។ ខ្ញុំសូមដកស្រង់៖ “អង្កាល់ អង្កាល់ណោះយើងដើររហូត ផ្លាស់ទីរហូតដោយសារយើងខ្លាចទាហានលន់ នល់ ខ្លាចពួកគេសងសឹក។ ពួកទាហានដែលនៅសល់ទាំងប៉ុន្មានសងសឹក”។ អ៊ីចឹងវាពិតជាមានការភ័យខ្លាចមែន។ លោកឪពុក ប៉ុងសួង៍ បានរៀបរាប់ផងដែរថា “នៅថ្ងៃទី១៨ មេសា ឆ្នាំ១៩៧៥ គាត់បានជូនដំណើរខ្មែរក្រហមទៅជិត វាំង ហើយក៏ឃើញទាហានលន់ នល់ ហើយបានបាញ់ជាមួយទាហានខ្មែរក្រហម បាញ់ទាហានខ្មែរ ក្រហម។ ហើយទាហានខ្មែរក្រហមពេលនោះគេគិតថា គេនឹងជួបទាហានអាមេរិកាំង”។ អាល់ រ៉ុក្កូហ្វ នោះក៏គាត់បានលើកឡើងយ៉ាងដូច្នេះដែរ គាត់និយាយនៅសវនាការនេះថា “បន្ទាប់ពីបានឃើញការច្បាំង គ្នាគ្រប់ទិសទី ក្រោយពី -- ចាប់ពីដប់ -- ខែមេសាទៅ គាត់ឃើញមានអ៊ីចឹងហើយ”។ ហើយ ហេដឌ័រ ក៏បាននិយាយដែរថាមានការប្រឆាំងពីទាហានលន់ នល់ នៅក្នុងទីក្រុងភ្នំពេញផងដែរ ពេលដែលដណ្ដើម បានហើយនោះ។ ខ្ញុំសូមដកស្រង់៖ “កម្លាំងសល់ទាំងប៉ុន្មាននៃកងទ័ពជើងអាកាសនៅតែបន្តប្រឆាំងនឹង ទាហានខ្មែរក្រហម អ៊ីចឹងហើយបានជាពួកគេភ័យខ្លាច កាលដែលនៅបាត់ដំបងនោះមានអ្នកខ្លះៗ គេថា ត្រូវតែជម្លៀសប្រជាជនបណ្ដោះអាសន្នហ្នឹងហើយ ព្រោះថាមានកម្លាំងតស៊ូបន្តទៀត ប្រឆាំងទៀត”។ ហ្នឹងហើយ អ៊ីចឹងមានការជម្លៀសមុនទីក្រុងភ្នំពេញពិតជាត្រូវហើយ ក៏ប៉ុន្តែជាការជម្លៀសក្នុងយុទ្ធវិធី យោធាទេ។ នៅពេលដែលយើងនិយាយពីទំនួលខុសត្រូវរបស់លោក ខៀវ សំផន ក្នុងការអនុវត្តការ ជម្លៀសនេះ ដែលលោកនិយាយជាច្រើន ដែលសហព្រះរាជអាជ្ញានិយាយជាច្រើននោះ តែងតែត្រូវបាន សម្រេចដោយផ្នែកយោធាខ្មែរក្រហមទេ។ ហើយមានសាក្សីមកផ្ដល់សក្ខីកម្មនៅទីនេះហើយតើ ហេតុ អីបានគេជម្លៀស ហើយជម្លៀសរបៀបណានោះ? លោក នី កន ក៏បានរៀបរាប់ដែរ “គឺថាគឺជាការ ជម្លៀសប្រជាជនចេញពីកន្លែងមានសង្គ្រាម ហើយជួនកាលនោះគ្រាន់តែបណ្ដោះអាសន្នទេ។ នៅពេល ដែលជនស៊ីវិលខ្លួនឯងនោះមិនចេញពីកន្លែងហ្នឹងដោយខ្លួនឯង”។ ឈូក រិន ក៏បានលើកឡើងដែរ ខ្ញុំសូម ដកស្រង់៖ “យើងនៅក្នុងពេលសង្គ្រាម យើងមិនដែលគិតថា ជនស៊ីវិលជាខ្មាំងទេ ហើយខ្ញុំមិនដែល ទទួលបញ្ជាថា ឲ្យចាត់ទុកគេជាខ្មាំងទេ តែបើសិនជាខ្មាំងវាយប្រហារដល់យើង ហើយប្រជាជនមិនត្រូវ បានជម្លៀសនោះ អ៊ីចឹងគឺយើងអាចមានគ្រោះថ្នាក់”។ ហើយចម្លើយទាំងអស់នេះគឺថាមានការគាំទ្រ

ដោយសក្ខីកម្មមួយចំនួនដូចឧទាហរណ៍ដូចជា៖ ឌុច, ភី ភួន។

[១១:៤៩:០៩]

នេះគឺជា គ្រាន់តែជាយុទ្ធវិធីសង្គ្រាមឈ្លបទេ។ លោក ឆេនល័រ ក៏បានពន្យល់ដែរ អំពីប្រវត្តិនៃសង្គ្រាមនេះ ដែលនិយាយអំពីភាពសមហេតុផលនៃសង្គ្រាមក្នុងការដំណើរការដណ្ដើមអំណាច។ ហើយមានការបញ្ជាក់គាំទ្រដែរដោយលោក ស្ទីវ ហេដឌ័រ នៅក្នុងសវនាការយើងនេះ។ មិនមែនជាវិធានការដាក់ទណ្ឌកម្មទៅលើអ្នកទីក្រុងដោយចាត់ទុកថា គាត់ជាខ្មាំងនោះទេ អ៊ីចឹងត្រូវយល់ពីបរិបទនេះផងដែរ។ យើងក៏បានលើកឡើងផងដែរអំពីមូលហេតុសុខភាពនៃការជម្លៀសនោះ -- សុខាភិបាល។ ហើយខាងសហព្រះរាជអាជ្ញា គេបាននិយាយរឿងរ៉ាវច្រើនណាស់ ហួសពីការដែលថាខ្មែរក្រហមនៅក្នុងសង្គ្រាមទេ។ គេនិយាយថា ព្រោះថាខ្មែរក្រហមហ្នឹងបានព័ទ្ធទីក្រុងដើម្បីវាយលុកផ្ដាច់ព្រ័ត្រ ហើយអ៊ីចឹងហើយបានស្ថានភាពហ្នឹងវាធ្ងន់ធ្ងរ ដោយសារពួកខ្មែរក្រហមព័ទ្ធក្រុងហ្នឹង។ អានេះមិនត្រូវទេនិយាយយ៉ាងដូច្នេះ ព្រោះថាយើងមានធាតុផ្សំភស្ដុតាងនៅក្នុងសំណុំរឿងយើងហើយ។ សាក្សីមកផ្ដល់សក្ខីកម្មនៅនេះ និយាយថាគេគេចពីការទម្លាក់គ្រាប់បែកអាមេរិកាំង។ នៅថ្ងៃទី២៣ កក្កដា ឆ្នាំ២០១២ ឆេនដ៍ល័របាននិយាយថា “នៅភ្នំពេញនោះមានតែ២លាននាក់ ហើយពីមុនមានតែ ៥០០.០០០នាក់ទេ”។ អ៊ីចឹងក៏គេនាំគ្នាមកភ្នំពេញយ៉ាងច្រើនបំផុតដើម្បីគេចគ្រាប់បែកខ្មែរក្រហម ហើយមុនពេលការវាយលុកផ្ដាច់ព្រ័ត្ររបស់ខ្មែរក្រហម -- ទម្លាប់បែករបស់អាមេរិកាំង (សូមទោស)។

[១១:៥១:១១]

ឯកសារ E3/1757 គេបានលើកឡើងថា ខ្ញុំសូមដកស្រង់៖ “ដើម្បីយល់ប្រវត្តិសាស្ត្រ យើងត្រូវយល់ថាការជម្លៀសមកទីក្រុងភ្នំពេញនេះ មិនមែនជាលើកទី១ទេ នៅថ្ងៃទី១៧ មេសា នោះ ក៏ប៉ុន្តែជាការជម្លៀសការចេញទីក្រុងភ្នំពេញនេះវាជាការជម្លៀសដែលប៉ះពាល់ទៅប្រជាជនទៅដល់ប្រជាជននៅទីក្រុងភ្នំពេញ។ ហើយរយៈកាលណោះ ប្រជាជនឡើងទៅដល់២លានជាង ហើយកើនទៅដល់ពីរបីដងហើយដែលនៅទីក្រុងភ្នំពេញកាលណោះ ភាគច្រើនដែលប្រជាជនរត់មកពីស្រុកស្រែ គេចការទម្លាក់គ្រាប់បែក”។ សូមរំឭកផងដែរ ពាក្យពេចន៍របស់ លោក ប៉ុងសូដ៍ គាត់និយាយនៅទីនេះ គាត់និយាយថា “ជនភៀសសឹកដែលគេចពីការវាយប្រហារនោះមិនមែនមកពួកខ្មែរក្រហមទេ ដូចគេនិយាយថា ដូចភាសាខ្មែរគេនិយាយអ៊ីចឹង ថាពេលដំរីឈ្លោះគ្នាស្រមោចងាប់។ គេក៏មិនកាន់ជើងខ្មែរក្រហម ហើយក៏មិនកាន់ជើងរដ្ឋាភិបាលដែរ ប្រជាជនកាលណោះនោះ។ នៅឆ្នាំ១៩៧៣នោះ គេនាំគ្នាគេចពីការទម្លាក់

គ្រាប់បែកអាមេរិកាំង”។ ខ្ញុំសូមបញ្ចប់ការដកស្រង់។

[១១:៥២:៤៣]

ហើយស្ថានភាពនៅភ្នំពេញនៅពេលនោះ ខែមេសា ឆ្នាំ១៩៧៥នោះ គឺថាអ្នកនៅភ្នំពេញនោះ បានពិពណ៌នាស្ថានភាពនេះហើយ នៅក្នុងតុលាការយើងនេះ។ ហើយដូចជា ឡាយ បូនី, ពេជ ស្រីផល, មាស សារ៉ាន់, អាល់ រ៉ុក្កូហ្វ, ទៀង សុខា ដែលបាននិយាយអំពីកង្វះខាតលំនៅដ្ឋាន ហើយនិងបញ្ហាសុខាភិបាល ហើយនិងស្បៀងអាហារជាដើម ហើយនិងបញ្ហាដែលកើតចេញពីបញ្ហាទាំងអស់នេះ។ ហើយបន្ថែមលើសក្ខីកម្មទាំងអស់នេះហ្នឹង យើងក៏មានឯកសារគាំទ្រផងដែរ។ ឯកសារ E3/4188 កាលណោះ យើងនៅឆ្នាំ១៩៧១ គឺថាមុនវាយផ្ដាច់ព្រ័ត្រចូលទីក្រុងភ្នំពេញរបស់ខ្មែរក្រហម។ លោកវេជ្ជបណ្ឌិតដែលធ្វើការនៅ *វើលវីសិន* មួយ គាត់បានលើកឡើងថា ខ្ញុំសូមដកស្រង់៖ “នៅក្នុងសង្គ្រាមចុងក្រោយដ៏តានតឹងនេះ ប្រជាជននៅទីក្រុងភ្នំពេញកើនទ្វេឡើងមួយជាពីរ។ ទីក្រុងនេះ ពីមុននោះមានតែ៧៥០០០០នាក់ទេ តែឥឡូវឡើងដល់១លានកន្លះ ហើយប្រជាជនទាំងអស់រត់ចេញពីស្រុកស្រែមកទីក្រុងភ្នំពេញ ដើម្បីរកលំនៅដ្ឋាន ស្បៀងអាហារ ការងារ សាលា ហើយនិងការព្យាបាល”។

[១១:៥៤:១២]

ខាងក្រោមបន្តិចចុះទៀត “គឺថាប្រជាជនច្រើនពេក កង្វះម្ហូបអាហារអីសព្វបែបយ៉ាងនោះ ខ្វះអនាម័យ ធ្វើឱ្យមនុស្សស្លាប់ជាច្រើននាក់ ក្នុងមួយសប្ដាហ៍ៗ”។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងបញ្ហាសុខាភិបាលនេះបានលើកឡើងដោយអ្នកផ្សេងទៀតផងដែរ។ ដូចជា ម៉ាហ្គារ៉េត ស្លូកូម *(Margaret Slocomb)* ឯកសារ E3/4535។ វីល្លៀម សក្រូស *(William Shawcross)* ក៏បានលើកឡើងដែរ គឺឯកសារ E3/88 នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា *“សាយស្ទូ: និចសុន, ឃីស៊ីងហ្គ័រ អេ ដេសសេកសិន អូហ្វ ខាំបូឌា” (តាមសូរស័ព្ទ)*។ យើងមានការខ្វះថ្នាំ ស្បៀងអាហារជាដើម។ យើងត្រូវការនាំចូលថ្នាំទាំងអស់ហ្នឹង។ នេះជាបញ្ហាដែលខ្មែរក្រហមត្រូវប្រឈមមុខ។ ហេតុអីបានជាខ្ញុំរំឭកពីបរិបទប្រវត្តិសាស្ត្រនេះ ពីព្រោះថាបើយើងគិតថាឆ្នាំ១៩៧៥ហ្នឹង វាគ្មានអ្វីទាំងអស់។ អ៊ីចឹងយើងត្រូវពីបរិបទដែលពេលដែលខ្មែរក្រហមដណ្ដើមបានអំណាចហ្នឹង។ អ៊ីចឹងយើងត្រូវគិតពីរឿងទាំងអស់ហ្នឹង យើងមិនត្រូវនិយាយតែពីឆ្នាំ៧៥ ហើយមិនមែននិយាយពីឆ្នាំមុនៗនោះទេ។ នៅក្នុងជំរំជនភៀសខ្លួន ឯកសារ E3/4187, ដូណាល់ខូន័រ *(តាមសូរស័ព្ទ)* គាត់សរសេរអត្ថបទមួយនិយាយថា “កម្ពុជា ប្រជាជនដែលរស់នៅស្ងប់ស្ងាត់ ប៉ុន្តែឥឡូវធ្លាក់ចូលក្នុងសង្គ្រាមហើយ”។ ជនភៀសខ្លួននៅក្នុងមណ្ឌលទទួល

រស់ទាំងត្រដរក្នុងលក្ខខណ្ឌអមនុស្សធម៌ ហើយនិងគួរឲ្យអស់សង្ឃឹម ជាពិសេសនៅកាំបូឌីយ៉ាណា នៅក្នុងកន្លែងមួយដែលជាកាស៊ីណូ ហើយដែលមិនអាចរកអ្វីបានលើសពីហ្នឹង។ ជនភៀសខ្លួនទាំងអស់នេះក៏នៅនឹងជាន់ទី២នៃអគារហ្នឹង ហើយភាពកខ្វក់ ហើយប្រជាជនច្រើនពេក លក្ខខណ្ឌគ្មានអនាម័យហ្នឹងគឺមានជ្រូកដើរចុះឡើងក្នុងកន្លែងមនុស្សនៅផង។ បង្កើតឲ្យមានក្លិនដូចជាកន្លែងគេចញ្ចឹមសត្វអីចឹង។

[១១:៥៦:២៤]

អាល់ រ៉ុកូហ្វ ក៏បាននិយាយដែរអំពីជំរំកាំបូឌីយ៉ាណានេះ គាត់និយាយថា មានមនុស្ស២៣ពាន់នាក់ដែលមកជ្រកកោននៅទីហ្នឹងក្នុងលក្ខខណ្ឌមួយវេទនាមែនទែន។ រ៉ុកូហ្វ បានលើកឡើងផងដែរថា ដោយសារមិនមានកន្លែងគ្រប់គ្រាន់នៅតាមជំរំទាំងអស់នោះ គេនាំគ្នា អ្នកខ្លះទៅនៅតាមផ្លូវ ចញ្ចើមផ្លូវ ហើយអ្នកភាគច្រើនហ្នឹងគេសង្ឃឹមថា សង្គ្រាមនឹងចប់ឆាប់ៗ ហើយនឹងគេត្រឡប់ទៅស្រុកទេសគេវិញ។ ការពិតណាស់ ដែលមានជំនួយអាមេរិកដែលជួលដល់របបលន់នល់។ ក៏ប៉ុន្តែយើងកុំឆោតពេក ដូចដែលខ្ញុំបានលើកឡើងអម្បាញ់មិញអីចឹង គឺថាយើងកំពុងតែធ្វើសង្គ្រាមត្រជាក់។ អីចឹងជំនួយហ្នឹងមិនមែនជំនួយអត់ចំណងទេ។ ជំនួយរបស់របបលន់នល់នេះ សង្គ្រាម ធ្វើសង្គ្រាមប្រឆាំងនឹងវៀតណាម។ មិនមែនថាជួយហ្នឹងដោយសារស្រលាញ់ទេ។ យើងកុំឲ្យវាត្រូវឆោតពេក យើងត្រូវតែចាំថា ស៊ីដនី ស្កេនប៊ឺក មកផ្តល់សក្ខីកម្មនៅទីនេះ គាត់និយាយថាជំនួយអាមេរិកាំងគឺជាជំនួយយោធាជាដំបូង មុនគេបង្អស់គឺជំនួនយោធា។ គាត់បានប្រាប់ផងដែរថា "បញ្ជាក់ផងដែរថា ការផ្តល់ជំនួយពីវ៉ាស៊ីនតោនសម្រាប់សង្គ្រាមប្រាំឆ្នាំហ្នឹង គឺថា២០០០លាននាក់*(ស៊ីក)* ជួយជំនួយមកប្រទេសកម្ពុជា ជាពិសេសគឺដើម្បីជំនួយខាងយោធា ហើយជួយតិចបំផុតខាងគម្រោងមនុស្សធម៌"។ សូមបញ្ចប់ការដកស្រង់។ ហើយ មានការទម្លាក់គ្រាប់បែកច្រើនហ្នឹងបង្កឲ្យមានមនុស្សពិការជាច្រើន។ អីចឹងយើងត្រូវនិយាយពីចំណុចទាំងអស់នេះផងដែរ។ អីចឹងការពិតទៅ វាមើលឃើញក្រោមទ្រង់ទ្រាយខុសៗគ្នាច្រើនណាស់។ ស៊ីដនី ស្កេនប៊ឺក ក៏បានពន្យល់ដែលថាគ្រាន់តែចាប់ពីខែកុម្ភៈ ឆ្នាំ១៩៧៥ ហ្នឹងចាប់ពីពេលហ្នឹងទេដែលអាមេរិកាំងផ្តល់ជំនួយឲ្យ ហើយឈប់ផ្តល់អាវុធយុទ្ធភណ្ឌឲ្យទាហានលន់នល់។ អីចឹងយើងកុំឲ្យឆោតពេកត្រូវយល់ពីបរិបទទាំងអស់នេះផងដែរ។

[១១:៥៨:៤៤]

ខ្មែរក្រហមនោះក៏មិនឆោតប៉ុន្មានដែរ គេដឹងថាក្រោយពេលដែលខ្លួនទទួលបានទទួលជោគជ័យជ័យជម្នះលើរបបលន់នល់ហើយ គឺថាប្រហែលជាគេខ្មែរអាមេរិកាំងនៅតែបន្តជួយទាហានលន់នល់

ទៀត។ អ៊ីចឹងយើងត្រូវដឹងថាកាលណោះ យើងកំពុងតែធ្វើសង្គ្រាមត្រជាក់។ ហើយមូលហេតុពិតប្រាកដនៃការជម្លៀសនោះ តើជម្លៀសឲ្យតែជម្លៀសប្រាវតែម្តងទៅ ឬក៏ -- ហើយដូចសហព្រះរាជអាជ្ញាបាននិយាយហ្នឹង ថាជម្លៀសហើយក្រោយមកដាក់ឲ្យក្លាយជាទាសករឬយ៉ាងម៉េច? មិនមែនអ៊ីចឹងទេ ហើយភស្តុតាងហ្នឹងមានតើនៅក្នុងសំណុំរឿងយើងហ្នឹង គឺថាស្ថានភាពសេដ្ឋកិច្ចនៅអង្គាល់នោះនោះវាគ្រោះមហន្តរាយណាស់នៅថ្ងៃទី១២ មេសា ឆ្នាំ៧៥នោះ។

លោកប្រធាន ឥឡូវនេះខ្ញុំចង់ចូលទៅនិយាយលម្អិតអំពីស្ថានភាពសេដ្ឋកិច្ច។ ប៉ុន្តែប្រហែលជាដល់ពេលសម្រាក ឬក៏យ៉ាងម៉េចលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយ និងសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣១:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ នៅពេលឈប់សម្រាកអម្បាញ់មិញនេះ ខ្ញុំបាននិយាយអំពីមូល-ហេតុសេដ្ឋកិច្ចនៃការជម្លៀសប្រជាជននៅឆ្នាំ១៩៧៥ ហើយការទម្លាក់គ្រាប់បែកដែលខ្ញុំបានលើកឡើង

អម្បាញ់មិញនេះ គឺជាប្រភពចម្បងនៃបញ្ហាសេដ្ឋកិច្ចដែលកើតមាននៅសម័យនោះ។

យើងមានសង្គ្រាមអស់រយៈពេលប្រាំឆ្នាំនៅក្នុងប្រទេសកម្ពុជាដែលជាប្រទេសកសិកម្មនោះបានបង្កនូវការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ ហើយការទម្លាក់គ្រាប់បែកអាមេរិកាំងនេះ ខាងសហព្រះរាជអាជ្ញាគាត់មិនចាប់អារម្មណ៍ទេ។ ក៏ប៉ុន្តែតាមពិតទៅវាគឺជាមូលហេតុនៃបំផ្លាញស្រែ ហើយនិងធ្វើឲ្យបាត់បង់នូវការប្រមូលផល។ យើងបាននិយាយអំពីការទម្លាក់គ្រាប់បែកបេ៥២ ប៉ុន្តែមានការទម្លាក់គ្រាប់បែកផ្សេងទៀត អង្គជំនុំជម្រះមានភស្តុតាងនៅក្នុងសំណុំរឿង។ នៅក្នុងសំណុំរឿង ខ្ញុំសូមលើកឡើងនៅសៀវភៅរបស់ អានវុន ហ្គីយូ *(Anne-Yvonne Guillou)* គឺ E3/1797 ដែលបានលើកឡើងអំពីការទម្លាក់គ្រាប់បែកដំបូងៗនៅព្រំដែនខាងជើង គឺនៅលើ -- ខាងកើត (សូមទោស) គឺនៅលើផ្លូវលំហូជីមិញគឺដើម្បីកម្ទេចទីបញ្ជាការរបស់ពួកវៀតកុង។ ការទម្លាក់គ្រាប់បែកនេះ ក៏បាននិយាយដោយលោក ស៊ីដនីស្តេនប៊ឺក ផងដែរនៅក្នុងសវនាការយើង។ ហើយគេបានពន្យល់ថា ហេតុអ្វីបានជាអាមេរិកគាំទ្ររដ្ឋប្រហារ លន់ នល់ នៅក្នុងក្របខ័ណ្ឌនៃការតស៊ូរបស់វៀតកុង។ លោក សុន អរុណ បានលើកឡើងអំពីតួលេខរួចមកហើយកាលពីម្សិលមិញ ឬក៏ម្សិលម្ង៉ៃ ខ្ញុំភ្លេចទៅហើយ។ ហើយយើងក៏ទើបតែបានរំឭកឡើងវិញ ក៏ប៉ុន្តែប្រហែលជាវាមិនច្បាស់ ក៏ប៉ុន្តែខ្ញុំគិតថា វាស្ថានភាពពិតប្រាកដដែលបានកើតឡើងពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចនៅកម្ពុជាក្នុងសម័យ ៧៥ ដល់៧៩។

[១៣:៣៤:២៩]

គឺខ្ញុំសូមរំឭកថា ទំហំគ្រាប់បែកនេះ គឺថាបីដងធំជាងការទម្លាក់គ្រាប់បែកនៅជប៉ុនទៅទៀត។ គឺថាធំជាងបីដង បើរួមទាំងគ្រាប់បែកអាតូមិកផងដែរ។ ហើយលោកឪពុក ប៉ុងសូដ៍ ដែលគាត់បានធ្វើការអស់ច្រើនឆ្នាំជាមួយកសិករកម្ពុជា គាត់និយាយអំពីការទម្លាក់គ្រាប់បែកដំបូងៗ គឺទម្លាក់ មានទាំងថ្នាំគីមីដើម្បីបំផ្លាញដំណាំទៀតផង។ នេះគឺជាឥទ្ធិពលទៅលើស្ថានភាពសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ ខ្ញុំសូមដកស្រង់៖ “គ្រាប់បែក១លានតោនត្រូវបានទម្លាក់នៅផ្នែកខាងកើតនៃកម្ពុជា ហើយដំណាំត្រូវបានបំផ្លាញដោយថ្នាំគីមី។ ថ្នាំគីមីនេះមានបន្សល់ស្នាមរហូតដល់សព្វថ្ងៃនេះ ដោយគ្រាប់របស់អាមេរិកាំង។ ឧទាហរណ៍ដូចជានៅតំបន់របស់ខ្ញុំមានទារកជាច្រើនកើតមកអត់មានដៃអត់មានជើង នេះហើយជាផលវិបាកផ្ទាល់នៃថ្នាំគីមីដែលបានទម្លាក់ពីលើអាកាសទៅលើដំណាំផ្សេងៗ”។ សូមបញ្ចប់ការដកស្រង់។ បន្ទាប់មកទៀត គាត់បន្ថែមទៀតថា៖ “នេះគឺជាផ្នែកដំបូងនៃការទម្លាក់គ្រាប់បែកអាមេរិកាំង ដែលបង្កគ្រោះមហន្តរាយទៅក្នុងតំបន់ទាំងមូល ហើយនិងបំផ្លាញសេដ្ឋកិច្ចកម្ពុជាទាំងមូល” សូមបញ្ចប់ការដក

ស្រង់។ គឺថាបំផ្លាញទៅលើសេដ្ឋកិច្ចកម្ពុជាទាំងមូលតែម្តង នេះហើយជាផលប៉ះពាល់នៃគ្រាប់បែកនោះ។ គាត់ក៏បានបញ្ជាក់ផងដែរថា៖ "គឺថានៅឆ្នាំ១៩៧៣ គឺការទម្លាក់គ្រាប់បែកនោះគឺបំផ្លាញសេដ្ឋកិច្ចកម្ពុជាខ្ទេចខ្ទីអស់ គឺនៅមានតែសេដ្ឋកិច្ចគ្រដរស់តែប៉ុណ្ណោះនៅពេលនោះ"។ គាត់នេះហើយគឺជាសាក្សីផ្ទាល់ភ្នែកដែលបានឃើញអង្គហេតុ។

[១៣:៣៦:២៧]

ហើយការរៀបរាប់នេះក៏បានបញ្ជាក់ដោយមនុស្សផ្សេងទៀតដែលចង់ការពារខ្មែរក្រហម ដូចជាលោក វីល្លៀម សក្រូស –នៅក្នុងឯកសារលេខ E3/88– គាត់បានលើកឡើងនូវការកត់សម្គាល់ពាក់ព័ន្ធទៅនឹងជំនួយអាមេរិកាំងដែលបានផ្តល់នៅពីសម័យនោះ។ គាត់បាននិយាយថា ខ្ញុំសូមដកស្រង់៖ "នៅខែមេសា ១៩៧៥ រដ្ឋាភិបាលណាក៏ប្រឈមមុខនឹងវិបត្តិស្បៀងអាហារកសិកម្មដែលមិនអាចជម្នះបាន" សូមបញ្ចប់ការដកស្រង់។ របាយការណ៍ដដែលដែលនិយាយអំពីជំនួយរបទេសអាមេរិកនោះ ខ្ញុំសូមដកស្រង់៖ "ប្រសិនបើប្រទេសណាមួយ -- គ្មានប្រទេសណាមួយដែលលក់ដាវដោយយកនង្គ័លមកធ្វើទេ គឺមានតែកម្ពុជាមួយទេ"។ ហើយបន្ទាប់មកទៀតរបាយការណ៍ហ្នឹងដែលលើកឡើងដោយ វីល្លៀម សក្រូស ដដែលនោះ គឺគាត់បានសរសេរថា ខ្ញុំសូមដកស្រង់៖ "ការងារទាសករ ហើយនិងរបបអាហារដែលធ្វើឲ្យប្រជាជនអត់ឃ្លាននោះ គឺថាកើតមាននៅឆ្នាំទុំង ហើយវាមានការលំបាកដល់ប្រជាជន"។ នេះគឺរបាយការណ៍របស់អាមេរិក។

[១៣:៣៧:៤៥]

ឥឡូវនេះយើងនិយាយអំពីតួលេខម្តង។ តើរបាយការណ៍នេះយើងនិយាយអ្វីពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចនៅកម្ពុជា គឺនិយាយអំពីតួលេខដែលពាក់ព័ន្ធទៅនឹងស្ថានភាពសេដ្ឋកិច្ច។ សត្វ៧៥ភាគរយត្រូវបានបំផ្លាញដោយសង្គ្រាម ហើយដំណាំក៏ត្រូវតែធ្វើឡើងដោយប្រជាជនដែលមានការអត់ឃ្លាន។ នេះជាអ្វីដែលបានកើតឡើងនៅខែមេសា ឆ្នាំ១៩៧៥។ គឺមិនមែនបង្កើតឡើងដោយខ្មែរក្រហមទេ គឺវាកើតឡើងនៅពេលនោះ។ គឺនៅពេលដែលខ្លួនចូលកាន់អំណាចនោះ គឺថាមានបញ្ហារួចទៅហើយ។

សក្រូស នោះក៏គាត់នៅតែរំឭកអំពីតួលេខមួយផ្សេងៗទៀត គឺដីកសិកម្ម ៨០ភាគរយសម្រាប់ដាំស្រូវនោះត្រូវបានបោះបង់ចោល។ តួលេខមួយទៀត គឺនៅឆ្នាំ១៩៧៤ ការបង្កបង្កើនផលស្រូវគឺមានទៅដល់៦៥៥.០០០តោន ឯឆ្នាំមុនសង្គ្រាមនោះគឺមានដល់ ៣,៦លានតោនឯណោះ អ៊ីចឹងមានន័យថា ថយចុះពី៣.៦០០.០០០ មកនៅត្រឹមតែ ៦៥៥.០០០តោន។ សក្រូស ក៏បានរំឭកផងដែរថា ជំនួយអាមេរិកាំង

នោះគឺមិនមែនជាជំនួយឥតសំណងនោះទេ។

[១៣:៣៩:២៦]

ពាក់ព័ន្ធទៅនឹងតួលេខទាំងអស់នេះ ខ្ញុំសូមបញ្ជាក់ផងដែរថា ខ្ញុំមានការភ្ញាក់ផ្អើលណាស់នៅពេលដែលនៅក្នុងដីកាដំណោះស្រាយគឺកថាខណ្ឌ១៤៥៨ បានបញ្ជាក់ថាមានស្ថានភាព វិបត្តិស្បៀងនោះគឺដោយសារតែមានបញ្ហា -- ដូច្នេះនៅក្នុងបរិបទនេះខ្មែរក្រហមគាត់បានចាត់វិធានការ ប្រហែលជាមិនមែនជាវិធានការទាំងស្រុងទេ ក៏ប៉ុន្តែជាវិធានការមួយចំនួនដែលមានភាពសមហេតុផលប្រឈមមុខនឹងបញ្ហាទាំងអស់នេះ។ ដើម្បីធ្វើម៉េចដោះស្រាយបញ្ហាផ្គត់ផ្គង់ស្បៀងដល់ប្រជាជន ដូច្នេះហើយត្រូវតែផ្ដោតទៅលើការធ្វើកសិកម្ម ផ្ដោតទៅលើការបង្កបង្កើនផល។ គឺថាយើងផ្ដោតទៅលើដី៨០ភាគរយដែលត្រូវបានបោះបង់ចោលមិនដាំដុះនោះ។ នេះជាបរិបទសេដ្ឋកិច្ច ដែលយើងខ្ញុំត្រូវតែលើកឡើង ដើម្បីបង្ហាញឲ្យឃើញអំពីបញ្ហានានា។

ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីអ្នកដែលទទួលបន្ទុកក្នុងការអនុវត្តការជម្លៀស។ ខាងមេធាវី នួន ជា បានលើកឡើងរួចមកហើយ ពិតណាស់សក្ខីកម្មដែលមាននៅចំពោះមុខអង្គជំនុំជម្រះនេះបញ្ជាក់ថាមានទាហានភូមិភាគ ហើយការជម្លៀសនេះគឺថាក្រោមការទទួលខុសត្រូវរបស់ភូមិភាគ។ ចំណុចមួយផ្សេងទៀតដែលលើកឡើងដោយមេធាវី នួន ជា ដែលនោះ ដែលខ្ញុំចង់បញ្ជាក់នៅពេលនេះ គឺថាទាហានភូមិភាគនេះហើយមិនដែលមានឯកភាពគ្នានោះទេ។ មិនមែនខ្ញុំជាអ្នកនិយាយនោះទេ គឺលោក ហ្វីលីព ស្បូត ដែលជាអ្នកជំនាញនៅក្នុងសវនាការយើងនេះបាននិយាយបែបនេះឯង។ “បក្សកុម្មុយនីស្តកម្ពុជាយើងមើលពីក្រៅទៅហាក់ដូចជាមានឯកភាពគ្នាអ៊ីចឹង។ ក៏ប៉ុន្តែយោធាដែលកាន់អំណាចនោះ គឺថាមិនមានឯកភាពគ្នាទេ”។ នេះគឺជាសម្ដីរបស់លោក ហ្វីលីព ស្បូត។

[១៣:៤១:៥៤]

ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជននៅទីក្រុងភ្នំពេញនោះ គាត់បានលើកឡើងថា “នៅទីក្រុងភ្នំពេញ តំបន់ផ្សេងៗត្រូវបានកាន់កាប់ដោយទាហានផ្សេងៗគ្នាដែលស្ថិតនៅក្រោមការគ្រប់គ្រងមួយរួមហើយដែលមានភូមិភាគផ្សេងៗបានចូលរួម”។ គាត់បាននិយាយក្នុងសៀវភៅរបស់គាត់ ហើយក៏គាត់បាននិយាយឡើងវិញនៅក្នុងសវនាការនេះផងដែរ។ ខ្ញុំសូមដកស្រង់នូវសម្ដីរបស់គាត់៖ “ការរៀបរាប់អំពីការជម្លៀសប្រជាជនទីក្រុងភ្នំពេញ ហើយនិងប្រភពផ្សេងទៀត ហាក់ដូចជាស៊ីសង្វាក់គ្នាក្នុងការនិយាយថាតំបន់ភូមិភាគផ្សេងៗនោះមានរបៀបអនុវត្តផ្សេងៗគ្នាក្នុងការជម្លៀសប្រជាជន។ ទាហាន

ខាងភូមិភាគបូព៌ា ឧទាហរណ៍ ហាក់ដូចជាមិនសូវតឹងតែងដូចពួកនិរតី ដែលកាន់កាប់ដោយ តាម៉ុក នោះទេ។ នេះគឺជាគំនូសបំព្រួញមួយដែលយើងអាចសង្ខេបបានអំពីអ្វីដែលបានកើតឡើងនៅក្នុងរបប នោះ អាស្រ័យទៅតាមភូមិភាគ អាស្រ័យទៅតាមគោលនយោបាយ និងអាស្រ័យទៅតាមកម្មាភិបាល ជាន់ទាប។ ហើយដូចគ្នាផងដែរចំពោះមេភូមិ មេសហករណ៍គឺថាមានភាពខុសគ្នាទាំងស្រុងនៅក្នុងការ អនុវត្តសេចក្ដីណែនាំនោះ”។ សូមបញ្ចប់ការដកស្រង់។

យើងនឹងពិនិត្យមើលនៅពេលក្រោយ ថាតើភាពខុសគ្នារវាងតំបន់មួយទៅតំបន់មួយនេះ វាមាន លក្ខណៈយ៉ាងម៉េចពាក់ព័ន្ធទៅនឹងសហឧក្រិដ្ឋកម្មរួមនោះ។

[១៣:៤៣:២៣]

យើងចាំបាច់ត្រូវតែរំឭកអំពីលក្ខខណ្ឌដែលកើតមាននៅក្នុងប្រទេសកម្ពុជា នៅក្នុងថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ហើយនិងថាតើខ្មែរក្រហមបានចាត់វិធានការជម្លៀសនេះក្នុងលក្ខខណ្ឌបែបណាខ្លះ។ ពាក់ព័ន្ធ ទៅនឹងការជម្លៀសប្រជាជនដំណាក់កាលទី២ គឺយើងមានធាតុផ្សំតិចតួចណាស់។ លោកមេធាវី សុន អរុណ បានពន្យល់ច្បាស់លាស់ហើយកាលពីម្សិលមិញ លោក អាកទួរ វែកគែន ក៏បានពន្យល់ផងដែរ កាលពីព្រឹកមិញនេះ ថាយើងអត់មានកាលបរិច្ឆេទច្បាស់លាស់ទេ ហើយចំនួនជនរងគ្រោះក៏យើងមិន មានភាពច្បាស់លាស់ដែរ។ ក៏ប៉ុន្តែមានឯកសារពីរសំខាន់ដែលសហព្រះរាជអាជ្ញាផ្អែកលើនោះ សម្រាប់ និយាយអំពីការជម្លៀសដោយបង្ខំដំណាក់កាលទី២នេះ គឺកំណត់ហេតុនៃទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ នៅក្នុងតំបន់ព្លៃសាន នៅក្នុងភូមិភាគព្លៃសាន នៅថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥។ ហើយកំណត់ មួយទៀត គឺមានចំណងជើងថា “ការពិនិត្យមើល ការក្ដាប់ និងការអនុវត្តគោលនយោបាយនៃការកសាង សេដ្ឋកិច្ច និងកសាងប្រទេសក្នុងគ្រប់វិស័យ”។ ឯកសារទាំងអស់នោះគួរឲ្យចាប់អារម្មណ៍ណាស់ យើងអាចកត់សម្គាល់ឃើញថានៅក្នុងឯកសារទាំងពីរនេះ គឺមិនមាននិយាយថាលោក ខៀវ សំផន បាន ធ្វើបទអន្តរាគមន៍នោះទេ។ ហើយនៅពេលដែលយើងពិនិត្យមើលលើតួនាទីរបស់លោក ខៀវ សំផន នោះ យើងរឹតតែដឹងច្បាស់ថា នៅពេលដែលសរសេរកំណត់ហេតុទី១នោះ គឺថាលោក ខៀវ សំផន គាត់ នៅបរទេសឯណោះទេ។

[១៣:៤៥:១០]

ហើយឯកសារទី៣ ដែលមាននៅក្នុងដីកាដំណោះស្រាយ និងជាមូលដ្ឋានសម្រាប់សហព្រះរាជ អាជ្ញា គឺទូរលេខដែលនិយាយអំពីការជម្លៀសប្រជាជន។ ហើយទូរលេខនោះ គឺផ្ញើទៅតែ ប៉ុល ពត ទេ

អត់មានចម្លងជូនលោក ខៀវ សំផន នោះទេ។ ចំណុចទី៤ ដែលសហព្រះរាជអាជ្ញាផ្អែកលើដើម្បីនិយាយអំពីដែលភ្ជាប់លោក ខៀវ សំផន ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនដំណាក់កាលទី២នោះ គឺនិយាយអំពីអ្វីដែលលោក អៀង សារី បានលើកឡើង។ ទស្សនៈរបស់សហព្រះរាជអាជ្ញា គឺមានលក្ខណៈចម្លែកណាស់។ គាត់និយាយអំពីថាកិច្ចសម្ភាសន៍របស់ អៀង សារី បញ្ជាក់ថា មានការចូលរួមរបស់លោក ខៀវ សំផន នៅក្នុងការជម្លៀសប្រជាជនដំណាក់កាលទី២។ ពិតណាស់ គឺលោក អៀង សារី គាត់កុហក។ គាត់បាននិយាយថា លោក ខៀវ សំផន គាត់ចូលរួមពាក់ព័ន្ធ។ ដូច្នេះ យើងមិនអាចផ្អែកទៅលើកិច្ចសម្ភាសន៍របស់លោក អៀង សារី ដើម្បីយកមកធ្វើជាអះអាងនោះទេ។ ក៏ប៉ុន្តែទោះជាយ៉ាងក៏ដោយ យើងអាចពិនិត្យលើភស្តុតាងទាំងអស់នេះបាន។ ខ្ញុំដូចជាពិបាកយល់ហើយនូវទស្សនៈរបស់សហព្រះរាជអាជ្ញានៅពេលដែលគាត់លើកឡើងបែបនេះនោះ។

[១៣:៤៦:៥៦]

ពាក់ព័ន្ធទៅនឹងមូលហេតុនៃការជម្លៀសប្រជាជនដំណាក់កាលទី២ យើងត្រូវតែគិតទៅដល់បរិបទដែលលើកឡើងសម្រាប់ការជម្លៀសដោយដំណាក់កាលទី១។ គឺថាការជម្លៀសទី២នេះ គឺត្រូវបានសម្រេចបួនខែ មុនថ្ងៃទី១៧ មេសា ហើយអម្បាញ់មិញនេះ ខ្ញុំបាននិយាយអំពីស្ថានភាពសេដ្ឋកិច្ច ស្ថានភាពប្រទេសជាតិ។ ប្រសិនបើយើងកត់សម្គាល់ឃើញថា ទស្សនកិច្ចនៅខែសីហា ឆ្នាំ១៩៧៥ របស់គណៈអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ដែលជាមូលហេតុនាំឲ្យមានការសម្រេចអំពីការជម្លៀសថ្មីនោះ។ គឺពិតណាស់ ស្ថានភាពនៃការខ្វះខាតស្បៀងនោះហើយ ដែលតម្រូវឲ្យមានការធ្វើបែបនេះនោះ។

បើតាមសហព្រះរាជអាជ្ញាមូលហេតុនៃការជម្លៀសនោះ គឺថាជាមានលក្ខណៈជាបទឧក្រិដ្ឋ។ ក៏ប៉ុន្តែនៅពេលដែលយើងព្យាយាមពិនិត្យមើលឯកសារមួយចំនួន មូលហេតុច្បាស់លាស់នោះ គឺថាមូលហេតុសេដ្ឋកិច្ច បានជាបណ្ដាឲ្យមានការជម្លៀសលើកទី២។ តើឯកសារទាំងអស់នោះ បាននិយាយអ្វីខ្លះ? ខ្ញុំសូមលើកឧទាហរណ៍ គឺឯកសារ E3/781 គេបានបញ្ជាក់ថា ស្ថានភាពនៅព្រះវិហារ គឺប្រជាជនមានការកើនឡើង។ ខ្ញុំសូមដកស្រង់៖ "គឺថានៅទីនោះយើងមានលទ្ធភាពក្នុងការដោះស្រាយបញ្ហាស្បៀង"។

ចំណុចមួយផ្សេងទៀត ដែលយើងឃើញនៅក្នុងឯកសារនេះដែរ គឺគេនិយាយអំពីផ្ទះត្រៀមទុកសម្រាប់អ្នកជម្លៀសថ្មី។ ខ្ញុំសូមដកស្រង់ -- ឯកសារនោះបាននិយាយថា៖ "ការគ្រោងរៀបចំផ្ទះបន្តិចៗម្ដង ធ្វើពីថ្ម និងស៊ីម៉ង់ត៍"។ ហើយក៏មានការគ្រោងទុកផងដែរ គឺសូមដកស្រង់ "ដូច្នេះ យើងត្រូវយកឥដ្ឋ និងយកគ្រឿងមកធ្វើផ្ទះ ធ្វើឃ្លាំង និងធ្វើរោងចក្រ"។

[១៣:៤៩:២៧]

ឯកសារ E3/216 គ្រោងទុកផងដែរ អំពីសញ្ញាណនៃការដោះស្រាយជីវភាពប្រជាជន។ គោលដៅនោះគឺថាដើម្បីបង្កើនការបង្កបង្កើនផល។ ហេតុអ្វីបានជាមានការបង្កបង្កើនផល? ពីព្រោះថាមានស្ថានភាពដូចដែលខ្ញុំបានរៀបរាប់ពីមុនមកអ៊ីចឹង។ ក្នុងឯកសារដដែលនេះគឺមានការពន្យល់ថាការជម្លៀសប្រជាជននៅកាន់ភូមិភាគឧត្តរ និងភូមិភាគពាយ័ព្យ គឺថាដើម្បីព្យាយាមដោះស្រាយបញ្ហាស្បៀងជូនប្រជាជន ហើយនៅទីនោះដីមានជីជាតិល្អ។ ហើយយើងមានដីស្រែសម្រាប់ផ្គត់ផ្គង់ជីវភាពប្រជាជន ហើយក៏មានសម្ភារៈច្រើនសម្រាប់ឲ្យប្រជាជនធ្វើស្រែផងដែរ។

ពិតណាស់នេះគឺជាការពិត។ តំបន់នោះគឺថាមានភាពសំបូរបែបជាងតំបន់ផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះយើងឃើញហើយថានៅក្នុងសក្ខីកម្មរបស់លោក ហេងឌ័រ នោះគាត់បាននិយាយថាតំបន់ភូមិភាគឦសាននោះ គឺជាជម្រុកស្រូវ -- សូមទោស ភូមិភាគពាយ័ព្យ។ ហើយមេដឹកនាំខ្មែរក្រហមក៏គាត់យល់បែបនេះដែរ។ ពួកគាត់ប្រហែលជាគិតត្រូវចំពោះបញ្ហានេះ។ អង្គជំនុំជម្រះប្រហែលជានឹកឃើញហើយអំពីចម្លើយរបស់លោក ប៉ុងសូដ៍ ដែលបានពន្យល់អំពីតំបន់នោះគឺថាតំបន់បាត់ដំបងជាដើម។ ឧទាហរណ៍មានការរំរ៉ែគ្នាតិចតួច ហើយមានការទម្លាក់គ្រាប់បែកតិចតួចនៅទីនោះ។ ដូច្នេះស្ថានភាពកសិកម្មនៅទីនោះ គឺមានភាពប្រសើរជាង។ ខ្ញុំមិននិយាយថាល្អអស្ចារ្យអីទេ ក៏ប៉ុន្តែវាប្រសើរជាង បើវាធៀបទៅនឹងតំបន់ផ្សេងទៀតដែលកំពុងតែប្រឈមមុខនឹងបញ្ហាគ្រោះមហន្តរាយនោះ។

[១៣:៥១:២៥]

ដូច្នេះប្រសិនប្រសិនបើយើងជឿទៅលើឯកសារទាំងអស់នេះ គឺយើងឃើញថាមានការព្យាយាមក្នុងការដោះស្រាយបញ្ហាស្បៀងជូនប្រជាជន។ ហើយនេះគឺជាការពិត សម័យនោះពិតជាមានការខ្វះខាតស្បៀងមែន។ យើងមិនអាចប្រកែកបានទេ។ ឯកសារ E3/781 នោះគឺបានបញ្ជាក់ថាត្រូវតែធ្វើកសិកម្ម ហើយយកកសិកម្មនោះមកធ្វើជាមូលដ្ឋាន។ នៅពេលដែលយើងគិតទៅដល់ចេតនាឧក្រិដ្ឋ នៅពេលដែលយើងគិតទៅដល់មូលហេតុនៃការធ្វើសេចក្ដីសម្រេចចិត្ត យើងត្រូវតែគិតទៅលើធាតុផ្សំអត្តនោម័តិ ដែលអាចឲ្យយើងគិតអំពីឧក្រិដ្ឋកម្ម។ ដូច្នេះ គោលបំណងនោះ គឺមិនមែនដាក់ទណ្ឌកម្មប្រជាជនថ្មីក្នុងការដាក់ទណ្ឌកម្មទៅលើអ្នកទីក្រុងនោះទេ។ ដូច្នេះ គោលបំណងនោះគឺថាព្យាយាមក្នុងការស្វែងរកដំណោះស្រាយសមស្របដើម្បីចៀសវាងនូវមហន្តរាយផ្សេងៗ គឺដើម្បីចៀសវាងនូវស្ថានភាពអាក្រក់ដែលបានកើតឡើងនៅក្នុងប្រទេស។

[១៣:៥៣:០០]

ចំពោះអ្នកដែលទទួលបន្ទុកក្នុងការជម្លៀសដំណាក់កាលទី២នេះ ទាំងដីកាដំណោះស្រាយ ទាំងភស្តុតាងដែលយើងបានស្តាប់ឮនៅក្នុងក្របខ័ណ្ឌនៃសវនាការយើងនេះ គឺមិនមានភាពច្បាស់លាស់នោះទេ។ យើងនិយាយអំពីកម្មាភិបាលមូលដ្ឋាន និយាយពីថ្នាក់លើ អំពីអង្គការ និយាយអំពីកងទ័ព និយាយអំពីឈ្លប។ ខ្ញុំសូមបញ្ជាក់បន្តិចត្រង់ចំណុចនេះ។ យើងបាននិយាយច្រើនមកហើយអំពីសញ្ញាណការសម្ងាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ វាអាចនិយាយច្រើនពាក់ព័ន្ធទៅនឹងចំណុចនេះ ដោយថាយើងមិនដឹងថាយើងនិយាយអំពីអ្វី។ សញ្ញាណនៃពាក្យអង្គការនេះ ក៏មានភាពស្រពិចស្រពិលមិនច្បាស់លាស់ដែរ។ សាក្សីដែលបានមកផ្តល់សក្ខីកម្មនេះបានបញ្ជាក់ជាច្រើនដងហើយថា ឧទាហរណ៍ដូចជា នង សុផង់, គឺនៅថ្ងៃទី២៩ សីហា ២០១២, គាត់ថាគាត់មិនដឹងថាអង្គការនោះជាអ្នកណាទេ។ លោក នឹម សែម, ថ្ងៃទី២៥ កញ្ញា ២០១២, គាត់បានបញ្ជាក់ថាពាក្យអង្គការសំដៅទៅដល់ថ្នាក់ដឹកនាំ។ ហើយយើងមិនដឹងទេថ្នាក់ដឹកនាំនោះថាជាអ្នកណានោះ។ លោក ហ៊ុន ឈុនលី, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១២, នៅពេលដែលគេសួរគាត់ថា តើអង្គការជាអ្វី? គាត់ថាគាត់អត់ដឹងទេ គាត់មិនអាចឆ្លើយបានទេ។ គាត់មិនដឹងថាអង្គការហ្នឹងមានន័យថាយ៉ាងម៉េចទេ។ លោក ពេជ ជឹម, សវនាការថ្ងៃទី១ កក្កដា ឆ្នាំ២០១៣, គាត់ថាអង្គការគឺជាស្ថាប័នមួយ ជាអង្គភាពមួយ ជាបណ្តុំមនុស្សមួយ ហើយអ្វីច្បាស់លាស់នោះ គឺគាត់មិនដឹងទេ។ លោក សួង ស៊ីគឿន ផ្ទាល់ដែលបានធ្វើការនៅទីក្រុងភ្នំពេញ ក៏បាននិយាយផងដែរថា៖ “ខ្ញុំមិនដឹងថាអង្គការហ្នឹងជាអ្វីទេ។ អ្នកណាជាអង្គការ? ខ្ញុំមិនដឹងទេ”។

[១៣:៥៥:១១]

លោក ស្ទីវ ហេដឌ័រ ក៏បាននិយាយនៅក្នុងសវនាការនេះ គាត់បញ្ជាក់ថា អង្គការបើតាមគេពន្យល់ខ្ញុំ “គឺមានន័យថាអ្វីៗនៅថ្នាក់លើ ហើយថ្នាក់លើដល់កម្រិតណានោះក៏មិនមានការបញ្ជាក់ឲ្យបានច្បាស់ដែរ។ មិនដឹងថាតើថ្នាក់លើនោះ លើដល់ណាទេ”។ បន្ទាប់មកទៀត គាត់បានពន្យល់បញ្ជាក់ឲ្យបានច្បាស់ ខ្ញុំសូមដកស្រង់នូវសម្តីរបស់គាត់ “ដូចដែលគេបានពន្យល់មកឲ្យខ្ញុំអ៊ីចឹង គឺថាអ្វីៗអាស្រ័យទៅលើលេខាភូមិភាគ ឬក៏លេខាស្រុក។ តើពួកគេដំណើរការជាលក្ខណៈរួម ហើយមានស្តេចត្រាញ់មួយដែលអាចប្រើអំណាចជិះជាន់គេ”។ នេះជាងបញ្ហាដែលអាចកើតឡើង។ ចំពោះការជម្លៀសលើកទី២ គឺអង្គការជាអ្នកសម្រេច ហើយយើងដឹង -- យើងចង់ដឹងថាអ្នកណាជាអ្នកសម្រេចនោះ នៅក្នុងអង្គការយើងមិនអាចដឹងច្បាស់លាស់ទេ។

ការជម្លៀសប្រជាជនទី១ ក៏ដូចជាទី២ ដែរបង្ហាញអំពីចំណុចដែលថា វាខុសពីអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើង ហើយនិងខុសពីដីកាដំណោះស្រាយ។ គឺថាវាមិនមែនជាចេតនាមួយអាក្រក់ទេ គឺវាជាស្ថានភាព គឺជាវិធានការមួយដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ចនៅកម្ពុជា។ តើនេះជាជម្រើសផ្នែកមនោគមន៍វិជ្ជាមែនទេ? ពិតហើយ គឺដូចជាប្រទេសដទៃទៀតអ៊ីចឹង គឺថានៅពេលដែលមានបញ្ហា គឺតែងតែចាត់វិធានការដើម្បីដោះស្រាយបញ្ហា។ តើលើកឧទាហរណ៍ដូចនៅកម្ពុជា តើមានឧស្សាហកម្មទេនៅសម័យនោះ? ក្រៅពីកសិកម្ម តើមានប្រភពចំណូលអីផ្សេងទៀតទេនៅពេលនោះ? គ្មានទេ កម្ពុជានៅពេលនោះ គឺមានតែពីកសិកកម្មតែប៉ុណ្ណោះ។ ដូច្នេះហើយបានជាមានការជម្លៀសប្រជាជនដើម្បីទៅធ្វើកសិកម្ម។

[១៣:៥៧:២៥]

ដើម្បីបញ្ចប់ពាក់ព័ន្ធទៅនឹងមូលហេតុនៃការជម្លៀសប្រជាជន និងយោងទៅតាមអ្វីដែលបានលើកឡើងពាក់ព័ន្ធទៅនឹងបរិបទប្រវត្តិសាស្ត្រ យើងត្រូវតែនិយាយថា កាលៈទេសៈដែលកើតឡើងនៅពេលនោះនោះគឺថា មានតាំងពីមុនពេលដែលខ្មែរក្រហមចូលកាន់អំណាចទៅទៀត។ ហើយយើងមិនអាចគាំទ្រទៅលើគំនិតរបស់សហព្រះរាជអាជ្ញាដែលនិយាយថា គោលនយោបាយនេះធ្វើឡើងដើម្បីប្រឆាំងប្រជាជនទេ។ យើងមិនអាចនិយាយបានថា ប្រជាជនមិនទទួលរងនៅភាពអត់ឃ្លាននោះទេ។ ក៏ប៉ុន្តែការដែលនិយាយថា ជាការធ្វើបាបប្រជាជនថ្មី ដូចការលើកឡើងសហព្រះរាជអាជ្ញានោះ គឺថាវាមិនត្រូវទៅតាមអ្វីដែលបានចេញបញ្ហាពីអង្គការនោះទេ។ នេះមិនមែនជាអ្វីដែលខ្ញុំនិយាយទេ គឺឯកសារបានបញ្ជាក់ច្បាស់។

[១៣:៥៨:២៦]

ឥឡូវនេះខ្ញុំចូលទៅចំណុចមួយទៀត។ សំខាន់ណាស់ នៅក្នុងក្របខ័ណ្ឌនៃការការពារក្តីលោកខៀវ សំផន ហើយនិងក្របខ័ណ្ឌនៃការពិនិត្យមើលទៅលើអ្វីដែលបាននិយាយនៅក្នុងសវនាការនេះកាលពីប៉ុន្មានថ្ងៃមុននេះ។ ខ្ញុំចូលទៅចំណុចមួយ ប្រសិនបើយើងចង់សិក្សាអំពីសំណុំរឿងនោះ យើងត្រូវតែបោះបង់ចោលនូវបុរេវិនិច្ឆ័យ ហើយយើងត្រូវពិនិត្យមើលភស្តុតាងដែលមានទាំងអស់។ យើងត្រូវតែពិនិត្យមើលទៅលើឯកសារដែលសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញាមិនចង់លើកឡើង ក៏ប៉ុន្តែវាពិតជាមាន។ ខ្ញុំបានស្តាប់ឮខាងសហព្រះរាជអាជ្ញាគាត់សើចចំអកទៅលើពាក្យ “ស្តេចត្រាញ់” ខ្ញុំមិននិយាយលម្អិតពាក់ព័ន្ធទៅនឹងចំណុចនេះទេ។ ព្រោះថាខាងមេធាវីលោក នួន ជា បាននិយាយលម្អិត

រួចទៅហើយអំពីចំណុចទាំងអស់នេះ។ គាត់បានអត្ថាធិប្បាយយ៉ាងក្បោះក្បាយពាក់ព័ន្ធទៅនឹងអំណាចរបស់ភូមិភាគ ក៏ប៉ុន្តែយើងសូមរំឭកនូវអ្វីដែលអ្នកជំនាញបាននិយាយ គឺលោក ហ្វីលីព ស្បត បាននិយាយនៅក្នុងសវនាការនេះ។ ខ្ញុំសូមកដស្រង់ -- គឺនៅក្នុងឯកសារក្នុង -- សៀវភៅរបស់គាត់ ប៉ុល ពត "ប្រវត្តិនៃសុបិនអាក្រក់" គឺលេខ E3/79, គាត់បាននិយាយថា ខ្ញុំសូមដកស្រង់៖ "ផ្ទុយនឹងរដ្ឋកុម្មុយនីស្តអូតូដុកដែលបានធ្វើសេចក្តីសម្រេចប្រមូលផ្តុំតែមួយ កម្ពុជារបស់ពួកខ្មែរក្រហមនោះគឺថាមិនមានវិន័យទេ វាខុសពីរដ្ឋកុម្មុយនីស្តផ្សេងៗទៀត"។ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣ លោក ហ្វីលីព ស្បត បានពន្យល់ឃ្លាមួយនេះ គាត់បានលើកឡើងថា "មាគ៌ាបក្សបានបញ្ជូនទៅប្រធានភូមិភាគ ហើយគេបកស្រាយតាមតែគេនឹកឃើញ ហើយនេះចុងក្រោយខែមេសា ឆ្នាំ១៩៧៥ នៅតែបន្តរហូតដល់ចប់របប។ គឺថាមានការប្រែប្រួលគួរឲ្យកត់សម្គាល់ ហើយនិងមានការលំបាកខ្លាំងក្នុងការធ្វើឲ្យគោលនយោបាយនោះស៊ីគ្នា ដូចគ្នាទាំងអស់" សូមបញ្ចប់ការដកស្រង់។

[១៤:០១:០៣]

បើអ៊ីចឹងគឺថា ការដែលយល់ឃើញថា មជ្ឈិមហ្នឹងគ្រប់គ្រងអ្វីបានទាំងអស់នុ៎ងមិនត្រឹមត្រូវទេ។ ត្រង់ចំណុចនេះដដែល ជាការពិតណាស់ដែលថាចម្លើយរបស់អ្នកជំនាញ មិនថាត្រូវដាច់ខាតនោះទេ។ គឺថាត្រង់ចំណុចនេះគឺយើងត្រូវចាប់អារម្មណ៍លើភស្តុតាងដែលអស់លោក លោកស្រីចៅក្រមបានស្តាប់។ នួន ជា ក៏បានទទួលស្គាល់ផងដែរថា មានវិធីសាស្ត្រ ដើម្បីកាសស្ថានភាពពិតប្រាកដនៅពេលដែលគាត់ទៅធ្វើទស្សនកិច្ចនៅតាមមូលដ្ឋាន។ អស់លោក លោកស្រីចៅក្រមបានដឹងស្រាប់ហើយថា បានឃើញកិច្ចសម្ភាសន៍របស់សម្តេច សីហនុ កាលពីព្រឹកមិញនេះគាត់ថា នៅសហករណ៍ដែលគាត់បានទៅចុះទស្សនកិច្ចជាមួយលោក ខៀវ សំផន នោះ គឺថាសហករណ៍ទាំងអស់នេះ ចំពោះគាត់នោះគឺហាក់ដូចជាមិនមែនជាកន្លែងដែលថាលក្ខខណ្ឌការងារហ្នឹងគួរឲ្យស្អប់ខ្ពើម ឬក៏អាក្រក់ណាស់នោះទេ។ អ៊ីចឹងគឺថាជាការពិតណាស់ ជាក់ស្តែងណាស់ គឺថាការទស្សនកិច្ចទាំងអស់ដែលគាត់ -- លោក ខៀវ សំផន បានធ្វើនៅពេលដែលគាត់ផ្លាស់ទីដើម្បីមើល -- ទៅមើលហ្នឹង ដើម្បីឲ្យឃើញការរីកចម្រើននៃបដិវត្តន៍ហ្នឹង គឺថាសុទ្ធតែជាកន្លែងដែលគេជ្រើសរើសឲ្យគាត់មើលឲ្យឃើញថាវាប្រសើរ។ ហ្នឹងទស្សនៈហ្នឹង ខៀវ សំផន គាត់ឃើញថាប្រសើរដោយសារឃើញតែកន្លែងល្អ។ ហើយយើងមិនអាចជឿ ខៀវ សំផន ទាំងស្រុងនោះទេ គ្រប់ពាក្យនោះទេ។

ជាការពិតណាស់ យើងមិនអាចជឿគាត់ទាំងស្រុង យើងមិនអាចជឿថាភូមិភាគមានវិធីសាស្ត្រ

របស់គេផ្ទាល់ដែលគេមិនបានបញ្ជូនមកដល់ថ្នាក់លើទេ មានសក្ខីកម្មរបស់ ស៊ីវ ហេងឌ័រ ត្រង់ចំណុចនេះ ខ្ញុំត្រូវតែរំឭកថា ស៊ីវ ហេងឌ័រ ហ្នឹងគាត់មិនមែនជាសាក្សីរបស់អង្គជំនុំជម្រះទេ លោកបានធ្វើការជាមួយការិយាល័យសហព្រះរាជអាជ្ញាផង ជាមួយការិយាល័យចៅក្រមស៊ើបអង្កេតផង ហើយគាត់ហ្នឹងជាអ្នកតាក់តែងឯកសារ បទចោទប្រកាន់នេះហើយ។ រួចថា រូបគាត់ផ្ទាល់នេះហើយនេះគាត់ត្រូវតែនិយាយថា "គាត់បានឃើញគេនិយាយ ឮពាក្យគេនិយាយប្រាប់គាត់ថាព័ត៌មានមួយចំនួនមិនបានបញ្ជូនមកថ្នាក់លើទេ"។

[១៤:០៣:៣៥]

បើតាមសក្ខីកម្មដែលគាត់បានប្រមូលផ្តុំនោះគឺឯកសារ TCW-325 នៅពេលដែលគាត់ត្រូវបានគេសម្ភាសគាត់នោះ សួរសំណួរគាត់ គាត់លើកឡើងដូចតទៅនេះ សាក្សីនេះ "ប្រហែលជានៅពេលដែលថ្នាក់លើនៃបក្សនុំងចុះទៅតាមជនបទហ្នឹង ភាគច្រើនហ្នឹងគឺអ្នកដឹកនាំតាមមូលដ្ឋានហ្នឹងគេសម្អាតហើយគេដកអ្នកដែលសុខភាពមិនល្អចេញ គេរៀបចំយ៉ាងស្អាតដើម្បីទទួល"។ ហើយ ហេងឌ័រ ក៏បញ្ជាក់ផងដែរនៅក្នុងសវនាការថ្ងៃទី១៧ កក្កដា ឆ្នាំ២០១៣ ខ្ញុំសូមដកស្រង់៖ "មានរឿងរ៉ាវជាច្រើនដែលគេបានរៀបរាប់ឡើងទាក់ទងទៅនឹងការបង្កើតមុខមាត់ថ្មីនៅពេលដែលថា រូបភាពថ្មីនៅពេលដែលថ្នាក់លើចុះទៅមើលតាមមូលដ្ឋាន"។ អ៊ីចឹងនេះជាតថភាពដែលខាងព្រះរាជអាជ្ញាមិនព្រមទទួលស្គាល់នោះ។ ហើយលើកការសន្និដ្ឋានថាមានគោលនយោបាយមួយថា រើសអើងលើប្រជាជនថ្មី ឬក៏ធ្វើបាបប្រជាជនថ្មីនេះ យើងមិនអាចទទួលយកបាននោះទេ យើងត្រូវតែពិចារណាថា តើមានឬមិនមាន? ជន -- ដូចការលើកឡើងថា ខៀវ សំផន យើងឃើញហើយ ដូច្នេះយើងថាយើងត្រូវគិតពិចារណាឡើងវិញពីគោលនយោបាយសហឧក្រិដ្ឋកម្មរួម ដែលជាការបង្កើត -- ជាការយល់ឃើញរបស់សហព្រះរាជអាជ្ញានេះព្រោះថាវាខុសគ្នាខាងការពិតជាក់ស្តែងផ្សេង។ ការពិតនោះវាមានការរបាយការណ៍ក្លែងក្លាយមួយចំនួនការឆ្អែប្រឌិតមួយចំនួនដូច ហុង សុផង់ ក្នុងសវនាការយើងនេះ -- នង សុផង់ (សូមទោស) គាត់និយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "ខ្ញុំគិតថាអ្នកមួយចំនួនចង់យក*ប៊ុង* ហើយអ៊ីចឹងក៏ធ្វើរបាយការណ៍មួយចំនួននោះ ឬក៏លេខ ទូរលេខមួយចំនួននោះដែលបង្ហាញថា មានការរីកចម្រើនខ្លាំងនៅតាមកន្លែងរបស់គេ តែការពិតគឺមិនមានអ៊ីចឹងទេ គឺស្ថានភាពលំបាក"។ សូមបញ្ចប់ការដកស្រង់។

[១៤:០៦:១៦]

មានសក្ខីកម្មរបស់លោក មាស វឿន ផងដែរ ជាសក្ខីកម្មដ៏ល្អ ព្រោះគាត់ត្រូវមកទីនេះដើម្បីផ្តល់

សក្ខីកម្មថា លោក ខៀវ សំផន គ្រប់គ្រងតំបន់១០៥ ហើយគាត់បានផ្ញើទូរលេខតែមួយគត់ទៅលោក ខៀវ សំផន ហើយមិនដឹងច្បាស់ថា ខៀវ សំផន នោះបានទទួល ឬមិនបានទទួលផង។ ហើយគាត់គួរតែមកលោក មាស វឿន នេះ។

អ៊ីចឹងហើយបានខ្ញុំថា ចាំបាច់ណាស់ក្នុងការកោះហៅសាក្សីមួយចំនួនមកបំភ្លឺនៅទីនេះ ឲ្យឆ្លើយបំភ្លឺទៅលើចម្លើយដែលគាត់ឆ្លើយទៅចៅក្រមស៊ើបអង្កេត ព្រោះថាពេលខ្លះវាមានធាតុផ្សំដោះបន្ទុកខ្លះដែរ។ អ៊ីចឹងហើយបានជាយើងរៀបរាប់ថា យើងមានភស្តុតាងរាប់ម៉ឺនជាលាយលក្ខណ៍អក្សរ ហើយដែលយើងមិនមានលទ្ធភាពសួរដេញដោលទៅសាក្សីទាំងអស់នេះ។ អ៊ីចឹងមានបញ្ហារដ្ឋបាលខាងភស្តុតាងហើយ។ ដូច្នេះលោក មាស វឿន នេះបានរំឭកថា នៅក្នុងក្របខ័ណ្ឌនៃការងាររបស់គាត់ ហើយ ខៀវ សំផន ក៏មិនដែលបានបដិសេធពីការងាររបស់លោក មាស វឿន ដែរ។ អ៊ីចឹង ខៀវ សំផន គាត់បានទទួលបន្ទុកបញ្ជូនទំនិញមួយចំនួន សម្ភារៈមួយចំនួនទៅតាមមូលដ្ឋាន។ ហើយ មាស វឿន នោះបានឆ្លើយថានៅតំបន់១០៥ ដែលគាត់បានទៅនោះ គាត់បានសង្កេតឃើញថា សម្ភារៈដែលបញ្ជូនទៅនោះ គឺថាពុករលួយនៅក្នុងឃ្លាំង។ អ៊ីចឹងបានថា អ្នកដែលនៅធ្វើតាមមូលដ្ឋាននោះមិនបានបំពេញការងាររបស់ខ្លួនក្នុងការបែងចែកសម្ភារៈទាំងអស់នេះទៅប្រជាជន។ អ៊ីចឹងបានន័យថាយ៉ាងម៉េច? នេះតើអ៊ីចឹង ឬន័យដែលថាខាងថ្នាក់នេះគ្រប់គ្រងបានទាំងអស់នេះ។ នង សុផង់ ក៏បានបញ្ជាក់ផងដែរគាត់និយាយនៅក្នុងសវនាការនេះ។ ខ្ញុំសូមដកស្រង់៖ “ខ្ញុំសង្កេតឃើញថា អង្គការបានបែកចាយសម្លៀកបំពាក់ ហើយនិងអាហារ។ ហើយលោក ខៀវ សំផន បានឲ្យចេញបញ្ជាឲ្យចែកចាយសម្ភារៈ និងសម្លៀកបំពាក់ទាំងអស់នេះ ក៏ប៉ុន្តែគួរឲ្យសោកស្តាយដែរនៅតាមមូលដ្ឋាននោះ គឺប្រជាជនមិនបានទទួលទេ”។ អ៊ីចឹងនៅក្នុងសេចក្តីចម្លើយរបស់គាត់ គាត់បានលើកឡើងអំពីអសមត្ថភាពនៃអ្នកដឹកនាំតាមមូលដ្ឋាន។ នេះមិនមែនជាការប្រឌិតរបស់ជនជាប់ចោទទេ។

[១៤:០៩:០២]

ហើយនៅតំបន់១០៥នេះដដែល ១០៥ដែលយើងទាំងអស់គ្នាស្គាល់នេះ ដែលលោកសាក្សី មាស វឿន ត្រូវបានគេបញ្ជូនទៅបំពេញបេសកកម្មពិសេស ដែល ប៉ុល ពត បញ្ជា ដែលគាត់មិនដឹងថានៅទីនោះមានរឿងអីកើតឡើង គាត់បានលើកឡើងថា៖ “នៅក្នុងរយៈពេលដែលគាត់នៅតំបន់១០៥នោះ មិនមែន ខៀវ សំផន ទេដែលគាត់ទាក់ទងជាមួយអ្នកដែលគាត់មានទំនាក់ទំនងជាមួយនោះគឺមេផ្ទាល់គាត់ទេ”។ អ៊ីចឹងដូច្នេះ គេមិនចង់និយាយ មិនចង់ស្តាប់អំពីអំណាចរបស់តំបន់ របស់មូលដ្ឋានអីហ្នឹង ហើយ

ភាពឯករាជ្យភាពអ៊ីចឹង ក៏ប៉ុន្តែយើងឃើញហើយនៅសវនាការមានអ្នកមកនិយាយអំពីអំណាចទាំងអស់នេះ។ ដូច ឈូក រីន គាត់មកនិយាយនៅទីនេះឆ្នាំ២០១៣នោះ មានការបកប្រែជាភាសាបារាំងកាលណោះ គឺថាគាត់ ឈូក រីន និយាយពីពាក្យពេចន៍ដូចទៅនេះ៖ “នៅលើក្បាល តាម៉ុក មានម្លូក–លើ ម៉ុក មានម្លូក”។ អ៊ីចឹង អានេះគឺបញ្ជាក់ហើយថាភូមិភាគនោះមានអំណាចខ្លាំងណាស់។ ហើយទាក់ទងនឹងភូមិភាគហ្នឹងដែរ គឺថាយើងត្រូវចងចាំថា កងទ័ពដែលបានជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះសុទ្ធតែជាកងទ័ពភូមិភាគទេ។

[១៤:១០:៤៨]

អស់លោក លោកស្រីចៅក្រម ក៏បានស្តាប់សាក្សី លឹម សាត ផងដែរ ដែលជាប្រធានសហករណ៍ ដែលគាត់ពន្យល់ថា “ជាប្រចាំថ្ងៃ គាត់ជាអ្នកសម្រេចការងារ ត្រូវធ្វើអីៗ”។ អ៊ីចឹងកាលដែលយើងនិយាយថា មជ្ឈិមហ្នឹងគ្រប់គ្រងបានដឹងទាំងអស់នោះ មិនមែនជាការពិតទេ អស់លោក លោកស្រីចៅក្រម។ បាទ មានការជឿ ឬការសន្មតមួយទៀតដែលថាយើងត្រូវបំបាក់អាការយល់នេះ ការគិតអ៊ីចឹងចោល។ យើងត្រូវតែចោទសួរអំពីរបៀបទំនួលខុសត្រូវ ដូចជាការឧក្រិដ្ឋកម្មរួមដែលព្រះរាជអាជ្ញាបានលើកឡើងនោះ ដែលគាត់ថាមូលហេតុនៃការជម្លៀសសំខាន់នោះ គឺថាគឺដាក់ទណ្ឌកម្មលើប្រជាជនថ្មី ដែលបានសហការជាមួយរបបលន់នល់ ហើយដែលគេដឹងថា ដែលមេដឹកនាំខ្មែរក្រហមនោះថានឹងធ្វើឲ្យពួកគេក្លាយជាជនរងគ្រោះ ហើយដោយសារខ្លួនបានទទួលបញ្ជាពីថ្នាក់លើ។ នេះមិនត្រឹមត្រូវទេការអះអាងយ៉ាងដូច្នេះ។

[១៤:១២:១០]

នៅក្នុងដីកាដំណោះស្រាយនឹងសរសេរថា គោលបំណងចម្បងលើសពីតម្រូវការពលកម្មនោះ គឺថាត្រូវដកហូតពីអតីតរដ្ឋការរបស់សាធារណរដ្ឋខ្មែរទាំងអស់ហ្នឹង និងអតីតទាហាននេះ នៅសិទ្ធិសេដ្ឋកិច្ចហើយនិងនយោបាយ។ នេះគឺជាការច្រឡំហើយ ការដែលថាដកសិទ្ធិទាំងអស់នេះចេញហើយ ធ្វើឲ្យគេក្លាយជាកសិករ។ ដូចខ្ញុំលើកឡើងកាលពីព្រឹកមិញអ៊ីចឹង ភស្តុតាងរហូតមកដល់ពេលនេះ ត្រូវបានពិចារណាក្នុងទស្សនៈវិស័យនេះហើយ គឺថាទស្សនៈដែលថាជម្លៀសប្រជាជនថ្មីនេះ គឺជាការប្រឆាំងវាយប្រហារទៅលើប្រជាជនស៊ីវិល។ ការវិភាគក្នុងទស្សនវិស័យនេះមិនត្រូវទេ។ ខ្ញុំកំពុងតែនិយាយថានៅ -- គឺតាមពិតទៅ ជម្លៀសដោយសារមូលហេតុសេដ្ឋកិច្ចទេ ដែលមានបញ្ហាសេដ្ឋកិច្ចនៅពេលនោះ។ ហើយចំណុចមួយទៀត មូលហេតុមួយទៀតនោះ គឺថាភស្តុតាងដែលអស់លោក លោកស្រីចៅក្រមមាន

ទាក់ទងទៅនឹងការប្រព្រឹត្តទៅនឹងប្រជាជនថ្មីនេះ មិនដូចនឹងអ្វីដែលបានកើតឡើងនៅតាមមូលដ្ឋានទេ។ ពីព្រោះយើងនៅទីនេះ យើងមិនមែនកំពុងតែជម្រាបថា អ្នកដែលមកផ្តល់សក្ខីកម្មទាំងនេះ ដែលថាៗ គាត់ទៅដល់មូលដ្ឋានហើយ គេធ្វើបាបគាត់នោះ។ ខ្ញុំមិននិយាយថាហ្នឹងខុសទេ ក៏ប៉ុន្តែខ្ញុំចង់និយាយថា នេះមិនមែនជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទេ។

[១៤:១៤:០៣]

អ៊ីចឹង ប្រសិនជាយើងចង់រកមូលហេតុពិត ហើយនិងមូលហេតុពិតនៃអ្វីដែលបានកើតឡើងចន្លោះឆ្នាំ៧៥, ៧៩ នោះ លើអ្វីដែលកើតឡើងនៅក្នុងវិសាលភាពនៃសំណុំរឿងយើងនេះ យើងត្រូវតែឈប់ធ្វើការវិចារណាក្នុងទស្សនវិស័យដែលខុសនេះ ព្រោះវាងាយស្រួលពេក ហើយនិងការទាញ កុំមកបំព្រួញពេកហើយ បើយើងចង់និយាយអំពីបេះដូង ឬក៏អ្វីដែលសំខាន់បំផុតនៃការកាត់ក្តីយើងនេះ។ តើគោលនយោបាយនៃការជម្លៀសប្រជាជននៅសម័យនុ៎ងយ៉ាងម៉េចដែរ តាមឯកសារដែលសរសេរនៅសម័យនោះនោះ? យើងត្រូវសួរយ៉ាងដូច្នេះវិញ។ លោក ហ្វីលីព ស្ហត បានរំឭកថា គោលបំណងរបស់ខ្មែរក្រហមនោះមិនអវត្តមានទេ ក៏ប៉ុន្តែប្រព័ន្ធមិនដំណើរការ។ ខ្ញុំមិនបាននិយាយអ៊ីចឹងទេ តែនេះពាក្យសម្តីរបស់លោក ហ្វីលីព ស្ហត។ គាត់ក៏បានលើកឡើងផងដែរ នៅពេលគេសួរគាត់ ទាក់ទងទៅនឹងបញ្ហាស្បៀងអាហារ របបអាហាររវាងប្រជាជនចាស់និងប្រជាជនថ្មី។ គាត់បានលើកឡើងថា ខ្ញុំសូមដកស្រង់ "អាហារ គេប្រើប្រាស់អាហារហ្នឹងដើម្បីគ្រប់គ្រងប្រជាជនថ្មី។ នេះជាមធ្យោបាយរបស់កម្មាភិបាលមូលដ្ឋាន ក៏ប៉ុន្តែខាងថ្នាក់លើនេះ គេប្រាប់ថាធ្វើយ៉ាងម៉េចឲ្យអាហារឲ្យគ្រប់គ្រាន់ទៅដល់ប្រជាជន។ អ៊ីចឹងវាផ្ទុះបញ្ហាំងថាមានបញ្ហាប្រព័ន្ធនៅសម័យនោះ"។

[១៤:១៥:៣៨]

អ្នកជំនាញដដែលនេះក៏បានលើកឡើងផងដែរនៅឆ្នាំ២០១៣ ដដែលគឺថាការប្រព្រឹត្ត ការធ្វើបាបនោះមិនមែនជាគោលបំណងទេ។ គាត់បានលើកឡើងដូចតទៅនេះ។ ប៉ុល ពត បាននិយាយយ៉ាងដូច្នេះជាច្រើនដងនៅក្នុងសុន្ទរកថារបស់គាត់នោះ គាត់និយាយថា "ត្រូវតែផ្តល់ចំណីអាហារឲ្យគ្រប់គ្រាន់ដល់ប្រជាជន។ ខ្ញុំសូមបញ្ចប់ការដកស្រង់។ នេះខ្ញុំមិនមែនចង់និយាយ មិនមែនថាដោយសារតែលោក ហ្វីលីព ស្ហត និយាយថាអ៊ីចឹងត្រូវអ៊ីចឹងទេ។ ប៉ុន្តែតាមពិត នេះជាអ្វីដែលលោក ប៉ុល ពត គាត់និយាយគាត់ថាអ៊ីចឹង។ ហើយលោក ហ្វីលីព ស្ហត ហ្នឹង គាត់លើកឡើងថែមទៀតដែរថា -- ប៉ុន្តែតាមពិតទៅក្នុងការអនុវត្តប្រចាំថ្ងៃហ្នឹងវាមិនអ៊ីចឹងទេ មិនដូចដែលថ្នាក់លើនិយាយទេ ពីព្រោះថាគណៈអចិន្ត្រៃយ៍

នោះមិនបានធ្វើយ៉ាងណាឲ្យវាទៅរួច ហើយកម្មាភិបាលថ្នាក់ក្រោមហ្នឹងការងារច្រើនលើសលប់ពេកទៅក៏ប្រើ យកវិធីសាស្ត្របង្អត់អាហារដើម្បីគ្រប់គ្រងប្រជាជនបាន។ ធ្វើអ៊ីចឹងលទ្ធផល ប្រជាជនចុះខ្សោយ ផលិតផលក៏វាធ្លាក់ចុះ។

[១៥:១៦:៥៨]

នៅក្នុងសវនាការយើងនេះ គាត់បានបន្ថែមទៀតថា ការធ្វើយ៉ាងដូច្នេះមិនមែនជាបំណងរបស់ថ្នាក់ដឹកនាំទេ។ អ៊ីចឹងមានបញ្ហាដឹកនាំ បញ្ហាគ្រប់គ្រងនៅក្នុងប្រទេស ក្នុងរបបនេះ។ តើមានបញ្ហាអីរឿងអី រឿងថាដាក់ថាជាគំនិតហ្នឹង គោលគំនិតហ្នឹងគឺថាចង់ គោលបំណងគឺថាចង់បង្អត់អាហារប្រជាជន ចង់ធ្វើបាបប្រជាជននោះមិនអាចមានទៅរួចទេ។ យើងចង់និយាយដូច្នេះ គឺយើងចង់ដាក់សហឧក្រិដ្ឋកម្មរួមបានយើងនិយាយយ៉ាងដូច្នេះ។

នៅក្នុងឯកសារបក្សកុម្មុយនីស្តកម្ពុជាមួយ មាននិយាយពីគោលនយោបាយដែលមិនដូចនឹងអ្វីដែលសហព្រះរាជអាជ្ញាសរសេរទាល់តែសោះ។ គេនិយាយថាមានភាសាស្រពិចស្រពិល ក៏ប៉ុន្តែឯកសាររបស់កម្ពុជាប្រជាធិបតេយ្យទាក់ទងទៅនឹងប្រជាជនថ្មីនោះមានខ្លឹមសារច្បាស់លាស់ណាស់។ ចាប់ពីឆ្នាំ១៩៧៣ មក ទង់បដិវត្ត, ឯកសារ E3/785, បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការផ្គត់ផ្គង់តម្រូវការរបស់ជនជម្លៀស។ មានការលើកឡើងដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ទាក់ទងទៅនឹងទំនួលខុសត្រូវចំពោះប្រជាជន ចំពោះប្រជាជនដែលគេជម្លៀសទៅថ្មី បក្សមូលដ្ឋានត្រូវតែទទួលខុសត្រូវរបស់ខ្លួនផ្នែកស្មារតី និងផ្នែកសម្ភារៈ ទោះបីជាយើងសំបូរហូរហៀរក៏ដោយ យើងខ្វះស្បៀងអាហារក៏ដោយត្រូវតែទទួលខុសត្រូវ។

[១៥:១៨:៥៣]

ទង់បដិវត្តមួយដែលលើកឡើងដូច្នេះ ហើយ ភី ភួន ដែលជាសាក្សីសំខាន់ដែរ។ ភី ភួន បានលើកឡើងនៅទីនេះ នៅថ្ងៃទី៣០ កក្កដា ឆ្នាំ២០១២។ ខ្ញុំសូមដកស្រង់៖ “ទាក់ទងទៅនឹងស្បៀងអាហារ ពុំមានបញ្ហាអាហារទេ ប្រជាជនថ្មីទៅតំបន់រំដោះ ហើយវានៅជាមួយគ្នានឹងប្រជាជនចាស់។ ហើយពួកគេទៅដាំដំណាំជាមួយគ្នា ហើយគេធ្វើការជាមួយគ្នា ហើយអត់មានឃើញមានបញ្ហាអ្វីទេ។” ហើយ ឌុច ហ្នឹងក៏ដោយដែលជាសាក្សីសំខាន់ដែល សាក្សីរបស់ព្រះរាជអាជ្ញានេះ គាត់បានរៀបរាប់នៅសវនាការនៅថ្ងៃទី២១ មីនា ឆ្នាំ២០១២។ គាត់ ឌុច ក៏បានលើក -- ឌុច នេះធ្លាប់នៅតំបន់រំដោះដែរនៅមុនឆ្នាំ៧៥នេះ។ គាត់បានលើកឡើងដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ទិសដៅតែមួយនេះ គឺថាគឺដាក់យ៉ាងណាឲ្យ

ប្រជាជនថ្មីហ្នឹងនៅជាមួយប្រជាជនចាស់លាយឡំគ្នា"។ អៀង ផាន ដែលជាសាក្សីមួយទៀតនោះ ក៏បាននិយាយដូចគ្នាអ៊ីចឹងដែរ។ នៅសវនាការថ្ងៃទី២០ ឧសភា ឆ្នាំ២០១៣ គាត់និយាយពីបទពិសោធន៍គាត់ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ គាត់និយាយថា "រាល់ដងដែលខ្ញុំទៅភូមិខ្ញុំ ខ្ញុំសង្កេតឃើញថាប្រជាជនចាស់និងប្រជាជនថ្មីរស់នៅជាមួយគ្នា។ តាមមើលទៅពួកគេមានរបបអាហារដូចគ្នា ស្មើគ្នា"។ សូមបញ្ចប់ការដកស្រង់។

[១៤:២០:៥២]

នេះគឺជាចម្លើយ ជាសក្ខីកម្មមួយចំនួនដែលអស់លោក លោកស្រីចៅក្រមបានស្ដាប់កន្លងមក។ ឥឡូវនេះយើងត្រូវតែផ្ដល់សារៈសំខាន់ទៅលើភស្ដុតាងមួយចំនួនដែលមិនមែនទទួលបានពីមេធាវីការពារក្ដីរបស់លោក ខៀវ សំផន ទេ ក៏ប៉ុន្ដែដោយ ស្ទីវ ហេដឌ័រ គាត់បានលើកឡើងនៅក្នុងសវនាការនេះផងដែរ។ លោក ស្ទីវ ហេដឌ័រ មិនមានពាក្យណាដែលថា មានន័យអាថ៌កំបាំង ឬក៏ស្រពេចស្រពិលទេ។ លោក ហេដឌ័រ និយាយយ៉ាងដូច្នេះនៅក្នុងអត្ថបទមួយរបស់គាត់ដែលមានចំណងជើងថា "ការវាយតម្លៃឡើងវិញលើតួនាទីរបស់មេដឹកនាំជាន់ខ្ពស់ ហើយនិងមេដឹកនាំតាមមូលដ្ឋាននៃរបបកម្ពុជាប្រជាធិបតេយ្យ", ឯកសារ E3/4527។ គាត់វិភាគគោលនយោបាយចំពោះប្រជាជនថ្មី ដែលមានចែងដោយអ្នកដឹកនាំជាន់ខ្ពស់ខ្មែរក្រហម។

[១៤:២២:០៥]

នៅក្នុងការសួរចម្លើយ -- នៅផ្ដល់សក្ខីកម្មនេះ គាត់បាននិយាយថា គាត់បានប្រើឯកសារមួយចំនួនដើម្បីតាក់តែងអត្ថបទនេះ ហើយឯកសារយោងនេះដាក់ចូលទៅក្នុងសំណុំរឿង ឧទាហរណ៍ដូចជាឯកសារ E3/216 ដែលជាទង់បដិវត្ដយុវជន។ ឯកសារ E3/781, E3/729, E3/748, E3/570, E3/170, E3/760 ទាំងអស់នេះមិនមែនជាឯកសារដែលបាត់ទៅហើយទេ តែឯងទេ គឺឯកសារជាច្រើនជាប់គ្នា ហើយនៅក្នុងឯកសារទាំងអស់នេះមានពាក្យពេចន៍ដូចតទៅនេះ ដែលលោក ស្ទីវ ហេដឌ័រ បានដកស្រង់ទាក់ទងទៅនឹងប្រជាជនថ្មីនេះ ការប្រព្រឹត្ដទៅលើប្រជាជនថ្មី។ គេសូមឲ្យកម្មាភិបាលមូលដ្ឋានឲ្យមានស្មារតីបើកចំហជាមួយនឹងប្រជាជនថ្មី ដោយឲ្យចេះបត់បែន ហើយនិងទន់ភ្លន់ ឲ្យចេះអត់ឱន ហើយកុំឲ្យចាត់ទុកពួកគេថាជាឈ្លើយសឹក។ សូមឲ្យកម្មាភិបាលថ្នាក់ក្រោមតាមមូលដ្ឋាននេះ ឲ្យថាធ្វើយ៉ាងណាឲ្យប្រជាជនចាស់ ប្រជាជនថ្មីធ្វើការជាមួយគ្នា។ គេសុំឲ្យប្រជា -- កម្មាភិបាលមូលដ្ឋានផងដែរ សូមឲ្យធ្វើយ៉ាងណាឲ្យជីវភាពប្រជាជនថ្មីប្រសើរឡើង ដើម្បីបង្ហាញពួកគេឲ្យដឹង ឲ្យគេយល់

ឃើញថារបបនេះគឺជារបបពួកគេដែរ។ ហើយ ស៊ីវហ្វិន ហេងឌ័រ និយាយបន្តទៀតនៅក្នុងអត្ថបទគាត់នុំងថា ប្រជាជនចាស់មិនត្រូវយកប្រយោជន៍ពីការងារប្រជាជនថ្មីទេ តែត្រូវជួយពួកគេវិញនោះទេ។ អ៊ីចឹងថា គិតធ្វើម៉េចកុំឱ្យមានបុរេវិនិច្ឆ័យទៅលើពួកគាត់ ពួកប្រជាជនថ្មី។ អ៊ីចឹងប្រជាជនចាស់ ប្រជាជនថ្មីត្រូវធ្វើការសប្បាយជាមួយគ្នា ឈឺ វេទនាជាមួយគ្នានៅក្នុងសហករណ៍។

[១៤:២៤:២៣]

គាត់បានលើកឡើងផងដែរ នៅក្នុងអត្ថបទដដែលនេះ។ គឺថាអ្នកដែលគេជម្លៀសទៅហ្នឹងគឺជាប្រជាជនពេញសិទ្ធិ ប៉ុន្តែមិនមែនជាខ្មាំងទេ។ ហើយក៏មានបញ្ជាក់ផងដែរថាត្រូវគ្រោងស្បៀងអាហារទឹកទាំងអស់នោះ ដើម្បីទទួលអ្នកដែលគេជម្លៀសទៅ សម្លាប់សត្វជាដើម ដើម្បីផ្តល់ធ្វើជាម្ហូបអាហារជូនគាត់។ នេះគឺជាព័ត៌មានដែល ស៊ីវ ហេងឌ័រ បានផ្តល់ជូន ហើយព័ត៌មានទាំងអស់នេះមាននៅក្នុងទស្សនាវដ្តីរបស់បក្សកុម្មុយនីស្តកម្ពុជា។ ហើយមិនមែនថាត្រឹមតែជាឯកសារនោះទេ យើងក៏បានស្តាប់ពាក្យពេចន៍ដែល ស៊ីវ ហេងឌ័រ បញ្ជាក់ផងដែរ ជាពាក្យពេចន៍ដែលកម្មាភិបាលដែលគាត់បានសម្ភាស។ មានការលើកឡើងដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “នៅមេសា ឆ្នាំ១៩៧៥ បទបញ្ជាគឺថាត្រូវតែផ្តល់ចំណីអាហារដល់ប្រជាជនចាស់ ប្រជាជនថ្មីឱ្យដូចគ្នា ការលត់ដំពួកគេ មិនមែនបានន័យថា បង្អត់អាហារគេទេគឺថាធ្វើយ៉ាងណាធ្វើយ៉ាងណាឱ្យវាតឹងរ៉ឹងជាមួយពួកគាត់ជាងជាមួយពួកយើង”។

[១៤:២៥:៤៤]

ឯកសារមួយទៀតគឺ ឯកសារយុវជន យុវនារីកម្ពុជា គឺថាឯកសារ E169/4/1.1.1គឺចុះនៅខែកក្កដា ឆ្នាំ១៩៧៥ ខ្ញុំសូមដកស្រង់៖ “ឥឡូវនេះ យើងចូលនៅក្នុងសករាជថ្មីនៅក្នុងបដិវត្តន៍ប្រជាធិប-តេយ្យ សង្គមកម្ពុជាក្លាយជាសង្គមថ្មីមួយដែលមិនមានអ្នកណាជិះជាន់អ្នកណា ហើយមិនមានអ្នកមានអ្នកក្រ វណ្ណៈជិះជាន់ និងវណ្ណៈដែលត្រូវបានគេជិះជាន់នោះទេ។ ខ្មែរទាំងអស់រស់នៅក្នុងភាពស្មើគ្នា”។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងពាក្យពេចន៍របស់លទ្ធិម៉ាក្ស-លេនីនហ្នឹងមាននៅក្នុងហ្នឹងឃើញ -- ប៉ុន្តែទោះយ៉ាងណាក៏ក្តីមិនមានឃើញនិយាយអំពីការរើសអើងទៅលើប្រជាជនថ្មីនោះទេ ប៉ុន្តែផ្ទុយពីហ្នឹងទៅវិញទេ។

ឯកសារ E3/249 គឺជាឯកសារទង់បដិវត្ត សីហា ១៩៧៥ “ផ្នែកនយោបាយមិនត្រូវធ្វើអ្វីដែលប៉ះពាល់ដល់បដិវត្តន៍ទេ ហើយជាពិសេសហ្នឹង គឺត្រូវធ្វើអ្វីដែលប៉ះពាល់ទៅដល់ផលប្រយោជន៍ និងទឹកចិត្តប្រជាជនចាស់ និងប្រជាជនថ្មីនោះទេ”។ សូមបញ្ចប់ការដកស្រង់។ អ៊ីចឹងយើងកន្លែងនេះ យើងអាច

យោងទៅលើសក្ខីកម្មរបស់លោក ប៉ង់សូដ៍ គឺថាគំនិតទាំងអស់នេះប្រហែលជាការរវើរវាយមិនអាចធ្វើទៅបាន ដោយសារថាខ្មែរក្រហមនោះមិនបានគិតអំពីសារជាតិជាមនុស្ស។ អ៊ីចឹងថាពិបាកនឹងអនុវត្តបានណាស់ ក៏ប៉ុន្តែបើសិនជាយើងនិយាយថា គោលនយោបាយនោះគឺថា រើសអើងប្រជាជនថ្មីនោះ តែបើតាមអត្ថបទរបស់ខ្មែរក្រហមនេះមិនមានចែងយ៉ាងដូច្នេះទេ។

[១៤:២៧:៤៧]

ឯកសារមួយទៀតចុះខែតុលា ខែធ្នូ ឆ្នាំ១៩៧៥ ថាដើម្បីឲ្យក្លាយជាមនុស្សល្អ មានគោលជំហរត្រូវ ហើយរស់តាមលក្ខណៈអ្នកបដិវត្តន៍ហ្នឹង ត្រូវគិតគូរពីប្រជាជន។ នេះជាបទបញ្ជាដែលដាក់ពីថ្នាក់លើទៅមូលដ្ឋាន។ ឯកសារមួយទៀតគឺឯកសារ E3/166 ទង់បដិវត្ត។ ក្នុងឯកសារនេះមានរិះគន់ពីការប្រព្រឹត្តទៅលើប្រជាជនថ្មីពីសំណាក់កម្មាភិបាល។ ខ្ញុំសូមដកស្រង់៖ "នៅកន្លែងខ្លះ កម្មាភិបាលមួយចំនួនបានអនុវត្តមាគ៌ាបក្សដោយមិនគិតពីទំនួលខុសត្រូវរបស់ខ្លួនចំពោះប្រជាជន ដោយមិនគិតពីអាយុជីវិតរបស់គេ" ឧទាហរណ៍ដូចជាជម្លៀសគេប្រជាជនទៅក្រៅភូមិ ហើយដោយគ្មានហេតុផលអ្វីទាំងអស់ ពេលខ្លះមិនត្រូវជម្លៀសទេ ប៉ុន្តែជម្លៀសដែរ ឲ្យគេរស់នៅកណ្តាលវាល។ អ៊ីចឹងមានវិធានការមួយចំនួនដែលគេនេះដែរ គេៗចង់ចាត់វិធានដើម្បីទប់ទល់នឹងកម្មាភិបាលបែបនេះដែរ។ អ៊ីចឹងតើនៅក្នុងអ្វីដែលឮយើងទាំងអស់នេះខុសឬ? មិនមែនទេ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលមកផ្តល់សក្ខីកម្មនៅទីនេះ យើងមិនបាននិយាយថា យើងមិនទទួលស្គាល់ពីការប្រព្រឹត្តអាក្រក់ទៅលើពួកគាត់នោះទេ ក៏ប៉ុន្តែយើងចង់និយាយថា មិនមែនជាបទបញ្ជាចេញពីអ្នកដឹកនាំពីទីក្រុងភ្នំពេញនេះទេ។ អ៊ីចឹងហើយយើងខ្ញុំចង់និយាយថា ការផ្សាភ្ជាប់នឹងសហឧក្រិដ្ឋកម្មរួមនេះមិនត្រឹមត្រូវទេ។ នៅពេលដែលយើងនិយាយពីទំនួលខុសត្រូវរបស់កម្មាភិបាលមូលដ្ឋាននេះវាជាការសំខាន់ ហើយជាទស្សនវិស័យមួយទៀតនៃសំណុំរឿងយើងនេះ ក៏ប៉ុន្តែមិនមានអ្នកណាចង់និយាយអំពីបញ្ហានេះទេ ពីព្រោះអី? ពីព្រោះថា កាលណាយើងនិយាយពីកម្មាភិបាល ថ្នាក់ក្រោមនេះ វាធ្វើឲ្យសហឧក្រិដ្ឋកម្មរួមនេះចុះខ្សោយ ដែលសហព្រះរាជអាជ្ញាមិនចង់បានទេ ឲ្យពិចារណាក្នុងចក្ខុវិស័យនេះនោះ។

[១៤:៣០:២០]

មានចំណុចមួយចំនួនដែលមេដឹកនាំខ្មែរក្រហមមិនបានគិតនោះ គឺប្រហែលជាគាត់ ពួកគាត់មិនបានគិតដល់ភ្លេច ដែលមិនបានគិតពីអារម្មណ៍របស់ប្រជាជនដែលនៅទីក្រុង ហើយប្រជាជននៅស្រុកស្រែ ដែលគាត់នៅឆ្ងាយនោះ។ ហើយការដែលមានអារម្មណ៍មិនល្អ មានការស្អប់គ្នានេះ ប្រជាជនចាស់

ប្រជាជនថ្មីស្អប់គ្នានេះ មាននិយាយដែរ។ សៅ នី លើកឡើងដូចតទៅនេះ “គាត់ -- ប្រជាជនចាស់និយាយថា យើងទៅដល់នោះយើងលួចចំណីអាហារគេ ហើយគេប្រើពាក្យពេចន៍យ៉ាងដូច្នេះ”។ ឡាយ បូនី ក៏បានលើកឡើងផងដែរ ខ្ញុំសូមដកស្រង់៖ “យើងពិបាកធ្វើការបង្កបង្កើនផល គេនិយាយថាយើងជាមនុស្សគ្មានសមត្ថភាព ហើយខ្ជិល”។ សូមបញ្ចប់ការដកស្រង់។ ត្រង់ចំណុចនេះ ខ្ញុំមិនបាននិយាយថាបទពិសោធន៍អស់នេះមិនពិតទេ ក៏ប៉ុន្តែខ្ញុំចង់និយាយថា តើនេះវាចេញបញ្ជាពីលើ ឬក៏យ៉ាងម៉េច? ចេញតាមពីឯកសារផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏យ៉ាងម៉េច? តាមពិតទាំងអស់នេះមិនបានឆ្លុះបញ្ចាំងអំពីការណែនាំពីថ្នាក់លើទេ។ អ៊ីចឹងវាមិនមែនជាគោលបំណងហ្នឹងចង់ធ្វើសហឧក្រិដ្ឋកម្មរួមទេ។

មានសាក្សីមួយទៀត មុម សំអឿន -- មានដើមបណ្តឹងរដ្ឋប្បវេណីមួយទៀត គាត់បានពណ៌នាពីប្រតិកម្មដូចជាមនុស្សបុរេប្រវត្តិនោះ និយាយថា “វាសមមុខវាហើយអាប្រជាជនថ្មីហ្នឹង នៅពិបាកអ៊ីចឹងត្រូវហើយ”។ អ៊ីចឹងគាត់បន្ថែមទៀតផងដែរ៖“ប្រជាជនចាស់មួយចំនួនហ្នឹងមិនមានអីទាស់នឹងប្រជាជន១៧មេសាទេ គេចិត្តល្អ គេឲ្យអាហារយើងដែរហូបចុកដែរ ប៉ុន្តែអ្នកខ្លះហ្នឹងដែលពួកអនក្ខរជនមួយចំនួនគឺថាមានបុរេវិនិច្ឆ័យមួយចំនួន ដែលថាពួកគេទៅហ្នឹងដើម្បីលួចចំណីអាហាររបស់គេ។ អ៊ីចឹង ជាចុងបញ្ចប់ថាគេស្អប់ប្រជាជនថ្មីហ្នឹងឯង”។

[១៤:៣២:៣៦]

អ៊ីចឹងយើងឃើញថា មានរឿងហ្នឹងកើតឡើងមែន ការស្អប់ខ្ពើមគ្នារវាងប្រជាជនចាស់ ប្រជាជនថ្មី ក៏ប៉ុន្តែមិនមែនជាសេចក្តីណែនាំពីថ្នាក់លើទេ។ អ៊ីចឹងយើង -- ដូចលោក ប៉ូ ឌីណា ដើមបណ្តឹងរដ្ឋប្បវេណីនោះក៏បានលើកឡើងដែរ នៅភូមិហ្នឹងខ្វះចំណីអាហារ ហើយពេលហ្នឹងយើងត្រូវតែបន្តដំណើរទៅមុខទៀតដែរ។

ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតក៏ផ្តល់សក្ខីកម្មដូចគ្នាអ៊ីចឹងដែរ ពីព្រោះថាការពិតគឺថាអ្វីដែលសេចក្តីណែនាំពីថ្នាក់លើឲ្យចេះស្រឡាញ់គ្នាទៅមូលដ្ឋានមិនអាចធ្វើបានទេ ពីព្រោះពេលខ្លះយើងយល់ពីអារម្មណ៍របស់មនុស្ស។ ហើយ ភី ភួន ក៏បានលើកឡើងដែរ ដែលយើង -- ដែលគាត់លើកឡើងថា អ្វីដែលគាត់បានឃើញនៅក្នុងសហករណ៍មួយចំនួនចំពោះប្រជាជនថ្មីនោះ វាមិនដូចនឹងអ្វីដែលបញ្ជាដែល ឬក៏បញ្ជា ឬក៏វគ្គសិក្សានយោបាយដែលគាត់បានឆ្លងកាត់នោះទេ គេមិនបានប្រាប់យ៉ាងដូច្នេះទេ។ ដកស្រង់៖ “ខ្ញុំសង្កេតឃើញថា ការប្រព្រឹត្តមួយចំនួនផ្ទុយពីមាគ៌ាបក្ស ឬក៏បទបញ្ជាចេញពីបក្សកុម្មុយនីស្តកម្ពុជា។ ឧទាហរណ៍ ដូចជាមានការប្រព្រឹត្តមិនល្អជាដើម”។ ដូច្នេះ អង្គជំនុំជម្រះពេលដែលចេញ

សាលក្រមគួរតែគិតអំពីចំណុចទាំងអស់នេះ។ វាទាំងអស់នេះប្រហែលជាខុសពីបុរេវិនិច្ឆ័យរបស់លោកទាំងអស់គ្នា ក៏ប៉ុន្តែត្រូវគិតអំពីការពិតជាច្រើនផ្សេងៗ។ សូមថាគិតយ៉ាងណា អស់លោក លោកស្រីចៅក្រមសូមមេត្តាកុំឲ្យគិតថាល្អៗដាច់ អាក្រក់ៗដាច់ សឬខ្មៅដាច់ពីគ្នានោះមិនកើតទេ ព្រោះមានចំណុចខ្លះដែលយើងត្រូវថ្លឹងថ្លែងដែរ។

[១៤:៣៤:៤៣]

នៅក្នុងការស្ដាប់ចម្លើយរបស់លោក ស៊ីវ ហេងឌ័រ ហើយបន្ទាប់មកខ្ញុំនឹងផ្ដល់វេទិកាទៅសហភាតារបស់ខ្ញុំគាត់និយាយអំពីការរំលោភអំណាចរបស់ខ្លួន -- រំលោភអំណាចរបស់កម្មាភិបាលថ្នាក់ទាបនៅមូលដ្ឋាន។ តើនេះជា -- យើងនៅទីនេះ យើងត្រូវមកចោទសំណួរ ឬក៏ថាយើងមកគ្រាន់តែបញ្ជាក់ទទួលយកបុរេវិនិច្ឆ័យ គិតអំពីពិរុទ្ធភាពដែលយើងគិតថាត្រូវតែមាន។ រឿងនេះយើងត្រូវតែសួរ។ អ៊ីចឹងអង្គជំនុំជម្រះមិនបានអនុញ្ញាតឲ្យយើងពិចារណាលើចំណុចទាំងអស់នេះ ជាមួយលោក ហ្វីលីព ស្សូតទេ។ ព្រោះថានៅថ្ងៃនេះ យើងចង់ការទទួលខុសត្រូវរបស់កូនក្ដីរបស់ខ្ញុំ ជាឧបកិច្ចនោះ ហើយយើងមិនព្រមនិយាយអំពីទំនួលខុសត្រូវផ្សេងៗទៀត ពីព្រោះថាបើសិនជាគោលនយោបាយនោះ មិនបានបង្គាប់បញ្ជាឲ្យគេធ្វើបាបប្រជាជនទេនោះ។ វាគោលនយោបាយនេះ មិនបានសំដៅឲ្យមានការរើសអើងទេ។ ហើយអ្វីដែលកើតនៅតាមមូលដ្ឋាននោះ កើតមកអ៊ីចឹង យើងគួរតែចាប់អារម្មណ៍ ហេតុអីបានកើតអ៊ីចឹង? ម៉េចក៏មិនចាប់អារម្មណ៍សួរថា ម៉េចក៏នៅមូលដ្ឋានមានការធ្វើបាបមនុស្ស?

[១៤:៣៦:០៣]

បើអ៊ីចឹង កាលដែលយើងធ្វើយ៉ាងដូច្នេះ គឺថាឲ្យអ្នកដែលនៅទីនេះហ្នឹងទទួលខុសត្រូវជំនួសគេទាំងអស់ហើយ។ ហើយខ្ញុំសូមរំឭកផងដែរ ថាសេចក្ដី -- ចម្លើយរបស់លោក ស៊ីវ ហេងឌ័រ ដែលបញ្ជាក់ថាបានស្ដាប់ការចោទប្រកាន់ ដែលគាត់បានសម្ភាស ដូចថាការសរសេររាយការណ៍ខុស ហើយរក្សាអង្ករ ស្រូវ នោះសម្រាប់ខ្លួនឯង មិនផ្ដល់អាហារដល់ប្រជាជនហូបចុកនោះជាដើមនោះ។ គាត់រាយការណ៍ស្ថានការណ៍តាមមូលដ្ឋានរៀបរាប់ រាយការណ៍ថា ភាគច្រើនហ្នឹង រាយការណ៍ថា បញ្ហានោះ គឺដោយសារតែកម្មាភិបាលមូលដ្ឋានលាក់ស្រូវ លាក់អីទាំងអស់នោះដើម្បីប្រយោជន៍ខ្លួនឯង។ ហើយគាត់ក៏បាននិយាយពីភូមិភាគពាយ័ព្យផងដែរថា ចង់និយាយថា តំបន់ខាងនុ៎ង ហើយភូមិភាគខាងនុ៎ង គេធ្វើអ្វីដែលគេគិតថាត្រឹមត្រូវសម្រាប់ពួកគេ។ ហ្នឹងជាព័ត៌មាន ឬក៏សក្ខីកម្មដែលលោក ស៊ីវ ហេងឌ័រ បានប្រមូលបាន។ ហើយលោកឪពុក ប៉ុងសួដ៏ ក៏បាននិយាយផងដែរ ថាគាត់បាន ពេលក្រោយ

មកគាត់ដឹងថាការងាររបស់លោក ម៉ៃខល វីកឃើរី អាចបំពេញបន្ថែមទៅលើ និងការងារស្រាវជ្រាវរបស់គាត់ផ្ទាល់ផងដែរ។

[១៤:៣៧:២៧]

លោក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ បាននិយាយថា "កំហុសរបស់របបខ្មែរក្រហមនេះ គឺថាដោយសារផ្ដល់ទំនួលខុសត្រូវទៅកម្មាភិបាលថ្នាក់ក្រោមហ្នឹងលឿនពេក ដែលមិនទាន់បណ្ដុះបណ្ដាលពួកគេគ្រប់គ្រាន់ផង"។ គោលនយោបាយដែលថា មានភាពរវើរវាយហួសហេតុពេក ឬគោលនយោបាយដែលមិនអាចដំណើរការបាន។ ក៏ប៉ុន្តែយើងត្រូវសួរថា តើគោលនយោបាយនេះគឺមានបំណងធ្វើការរើសអើងលើប្រជាជនថ្មី ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងទេ ដូចថាធ្វើឲ្យប្រជាជនហ្នឹងក្លាយទៅជាទាសករជាដើមនេះ។ អ៊ីចឹងយើងមិនមែននៅចំពោះមុខអ្នកដឹកនាំ ដែលថាខ្លួនគាត់ គាត់មិនបាន មិនមានសមត្ថភាពក្នុងការគ្រប់គ្រង។ ព្រោះថាការងារនោះលំបាកណាស់ ប្រហែលជាអ្នកផ្សេងទៀត ក៏មិនអាចដោះស្រាយបញ្ហានៅសម័យនោះបានដែរ។

អ៊ីចឹងឥឡូវនេះ លោក លោកស្រីចៅក្រម កំពុងតែកាត់ក្ដីលើមនុស្ស មិនមែនកាត់ក្ដីលើប្រព័ន្ធនយោបាយមួយទេ។ អ៊ីចឹងដោយសារអស់លោក លោកស្រីចៅក្រម កាត់ទោស កាត់សេចក្ដីលើមនុស្សនោះ សហភាតា គង់ សំអុន ខ្ញុំ នឹងនិយាយអំពីប្រវត្តិរបស់លោក ខៀវ សំផន។ នៅក្នុងការស៊ើបអង្កេតនោះ គេមិនដែលបានខំនិយាយលម្អិតអំពីព័ត៌មានលម្អិតទាំងអស់នេះទេ ទាក់ទងនឹងជនជាប់ចោទនេះ។ ព្រោះថាព័ត៌មានទាំងអស់នេះ ជាផ្នែកមួយនៃសំណុំរឿង។ ហើយអស់លោក លោកស្រីចៅក្រម មិនអាចមិនពិចារណាលើភស្ដុតាងទាំងអស់នេះបានទេ នៅពេលដែលអស់លោក លោកស្រីចៅក្រមចេញសាលក្រម។

[១៤:៣៩:១៥]

ឥឡូវនេះ ខ្ញុំសូមរំឭកថា ទាក់ទងទៅនឹងប្រវត្តិលោក ខៀវ សំផន ថាសូមកុំឲ្យច្រឡំដូចអ្វីដែលព្រះរាជអាជ្ញាបានលើកឡើងនោះ គឺថាដាក់លោក ខៀវ សំផន ដាក់នៅក្នុងប្រភេទដូចគ្នា។ អ៊ីចឹងដោយសារអស់លោក លោកស្រីចៅក្រម នឹងធ្វើការកំណត់ទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់នោះ សូមវែកញែកឲ្យដាច់ កុំឲ្យចាត់ទុកគាត់ដូចជាអ្នកដទៃទៀត។

ឥឡូវ ខ្ញុំសូមផ្ដល់វេទិកាដល់លោក គង់ សំអុន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤០ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣១]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដីលោក ខៀវ សំផន ដើម្បីមានឱកាសឡើងធ្វើសេចក្ដីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួនជាបន្ត។ សូមអញ្ជើញបាទ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ ភាគីសាធារណជន។ ខ្ញុំមេធាវី គង់ សំអុន ក្រោកឈរនៅពេលនេះ ដើម្បីការពារសុភាពបុរសម្នាក់ដែលត្រូវគេលាបពណ៌ថា "ជាបិសាច"។ ខ្ញុំនឹងរៀបរាប់នៅពេលនេះ អំពីអត្តចរិត និងប្រវត្តិតួនាទីរបស់លោក ខៀវ សំផន នៅមុនឆ្នាំ១៩៧៥។ លោក លោកស្រីចៅក្រម តាមការពិនិត្យតួនាទីពិតរបស់លោក ខៀវ សំផន ក្នុងអំឡុងពេលដែលអង្គហេតុកើតឡើង ដែលជាកម្មវត្ថុនៃការជំនុំជម្រះដំបូង លោកគ្មានតួនាទីដូចការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានោះទេ។ តួនាទីរបស់លោក ខៀវ សំផន នៅពេលនោះ មានសារៈសំខាន់សម្រាប់កំណត់មូលដ្ឋានគតិយុត្តិ ដែលជាការចេញសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះនាពេលខាងមុខ។

សញ្ញាណនៃតួនាទីពិតប្រាកដនេះ ពិតជាសំខាន់ណាស់នៅក្នុងសំណុំរឿងមួយដែលសហព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួន ដោយសំអាងលើការឧបមា ការបកស្រាយ ដែលគេអាចសង្ខេបមកត្រឹមពាក្យមួយឃ្លាថា "លោកមិនអាចមិនដឹងនោះទេ"។ ក៏ប៉ុន្តែ ដូចក្រុមមេធាវីការពារបានពន្យល់នៅក្នុងក្របខ័ណ្ឌនៃសារណារបស់ខ្លួន ដូចមានក្នុងឯកសារ E163/5/9 កថាខណ្ឌទី៦៨ ស្ដីពីច្បាប់អនុវត្តរួចមកហើយ គឺថា-- សូមដកស្រង់៖ "ការកំណត់បទល្មើសសហឧក្រិដ្ឋកម្មរួម ក្នុងទម្រង់មូលដ្ឋានទាមទារឲ្យមានការបង្ហាញពីសំណាក់សហព្រះរាជអាជ្ញា នៅអត្ថិភាពនៃផែនការឧក្រិដ្ឋកម្មច្បាស់លាស់ ដែលជនជាប់ចោទបានដឹងអំពីផែនការនោះ ហើយដែលជនជាប់ចោទបានចូលរួមយ៉ាងជាក់ច្បាស់តែម្ដង។

[១៥:០៤:០២]

ដូចគ្នានឹងការកំណត់លើបទសមគំនិតតាមរយៈការជួយ ឬការលើកទឹកចិត្តត្រូវតែបានបកស្រាយដោយផ្អែកលើមូលដ្ឋាននៃប្រព័ន្ធច្បាប់បែបបារាំង ដែលប្រព័ន្ធច្បាប់នេះតម្រូវឲ្យមានការបង្ហាញពីសំណាក់សហព្រះរាជអាជ្ញានូវសកម្មភាពជាវិជ្ជមានរបស់ជនជាប់ចោទ ដែលសកម្មភាពនោះបានជះឥទ្ធិពលយ៉ាងជាក់ច្បាស់ចំពោះការប្រព្រឹត្តបទល្មើសមួយឬច្រើន ហើយដែលបទល្មើសនោះស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក យើងនេះ។ គេគួរតែពិនិត្យឲ្យបានត្រឹមត្រូវនូវភស្តុតាងស្ដីពីអំណាច និងតួនាទីរបស់លោក ខៀវ សំផន យ៉ាងជាក់លាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីកំណត់ថា តើធាតុផ្សំដែលកំណត់លក្ខណៈគតិយុត្តិត្រូវបានបង្ហាញលើសពីវិមតិសង្ស័យដែរឬទេ។ ពីព្រោះថា យើងស្ថិតនៅក្នុងវិស័យព្រហ្មទណ្ឌ។ ដូច្នេះ គប្បីពិនិត្យមើលថា តើជនជាប់ចោទមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងក្របខ័ណ្ឌនៃការចូលរួមរបស់ខ្លួននៅក្នុងបដិវត្តន៍សង្គមនិយមនៃរបបកម្ពុជាប្រជាធិបតេយ្យឬទេ? លោក ខៀវ សំផន មិនអាចទទួលខុសត្រូវរាល់អំពើទាំងអស់ដែលកើតមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ ហេតុនេះការពិនិត្យឲ្យបានត្រឹមត្រូវលើអង្គហេតុ នឹងនាំឲ្យគេឆ្លើយដោយអវិជ្ជមានជាមិនខាន។

[១៥:០៦:៥៧]

បុគ្គលិកលក្ខណៈរបស់លោក ខៀវ សំផន និងកាតព្វកិច្ចរបស់លោកពិតជាសំខាន់ណាស់ដើម្បីយល់ពីហេតុផលនៃជម្រើសរបស់លោក។ សហព្រះរាជអាជ្ញាបានចំអកឡកឡាយជាច្រើនដងនៅពេលសាក្សីអត្តចរិតផ្ដល់សក្ខីកម្ម ដោយចោទប្រកាន់ថាសាក្សីនិយាយកុហក តែថាក្នុងអំឡុងពេលនៃសវនាការរយៈពេល២០ខែនេះ សាក្សីគ្រប់រូបរួមទាំងដើមបណ្ដឹងរដ្ឋប្បវេណីផង ដែលបានស្គាល់លោក ខៀវ

សំផន តិចឬច្រើនក្តី តែងតែលើកឡើងពីភាពស្អាតស្អំ សុភាពរាបសារ ពីចិត្តមនុស្សធម៌ និងពីទឹកចិត្តស្មោះត្រង់របស់លោកនៅក្នុងកាតព្វកិច្ចដើម្បីប្រទេសកម្ពុជា។ គុណស័ព្ទដែលគេតែងប្រើដើម្បីរៀបរាប់ពីរូបលោកមានដូចជា បញ្ញវន្ត យុត្តិធម៌ និងស្អាតស្អំ ជាដើម។

អ្នកស្រី សូ សុជាតិ ដែលជាសាក្សីម្នាក់បានមកបង្ហាញអត្តចរិតរបស់លោក ខៀវ សំផន នៅចំពោះមុខអង្គជំនុំជម្រះបានបញ្ជាក់ថា នៅមុនស្គាល់លោក ខៀវ សំផន អ្នកស្រីបានដឹងអំពីអត្តចរិតរបស់លោក ខៀវ សំផន ពីឈ្មោះ អ៊ំយឹម ថាជាបញ្ញាជនចាស់ និងជាមនុស្សស្លូតបូត។ អ្នកស្រីបានបន្ថែមថាក្រោយពីរៀបការហើយ "ខ្ញុំឃើញជាគុណសម្បត្តិថា គាត់ជាមនុស្សអត់ធ្មត់ គឺជាមនុស្សសុភាពរាបសារមិនដែលមានទំនាស់នៅក្នុងកន្លែង ស្លូតបូត ហើយធ្វើអ្វីធ្វើតែខ្លួនឯង។ ខ្ញុំឃើញអត្តចរិតខ្ញុំឃើញឫកពារមិនមែនជាអ្នកធំនោះទេ គឺអ្វីទាំងអស់តាំងពីគក់កន្ទប ទាំងអីគឺជួយខ្ញុំសព្វគ្រប់"។ ការឆ្លើយបញ្ជាក់ទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ អ្នកស្រី សូ សុជាតិ បានអះអាងយ៉ាងម៉ឺងម៉ាត់ ដើម្បីបញ្ជាក់អំពីអត្តចរិតរបស់លោក ខៀវ សំផន ថាជាមនុស្សស្លូតបូត សុភាពរាបសារ ទន់ភ្លន់ និងមិនរើសអើង។

[១៥:០៩:៣១]

ម៉្យាងទៀត អ្នកស្រី សូ សុជាតិ បានបញ្ជាក់ថាលោក ខៀវ សំផន ជាប្តីល្អរបស់អ្នកស្រី ហើយដែលអ្នកស្រីមានជំនឿយ៉ាងមុតមាំទៅលើភាពត្រឹមត្រូវ មិនមែនជាមនុស្សកាចសាហាវឃោរឃៅក្នុងអំឡុងពេលដែលគាត់រស់នៅជាមួយគ្នាជាប្តីប្រពន្ធជាង៣០ឆ្នាំមកហើយនោះ។ អ្នកស្រី សូ សុជាតិ ក៏បានឆ្លើយបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៣ ផងដែរថា សូមដកស្រង់ "ខ្ញុំសូមរំឭកថា ទោះបីលោកតុលាការមានការចោទមកលើប្តីខ្ញុំត្រូវចាប់ ត្រូវកាត់ទោសយ៉ាងក៏ណាដោយតែខ្ញុំជាប្រពន្ធគឺនៅតែជឿចិត្តលើប្តីខ្ញុំ ជាមនុស្សល្អត្រឹមត្រូវ។ ពីព្រោះរស់នៅក្នុងរយៈពេលជាង៣០ឆ្នាំមកនេះ ខ្ញុំស្គាល់ប្តីខ្ញុំ ខ្ញុំស្គាល់អត្តចរិត ស្គាល់ឫកពារ គឺមិនមែនជាមនុស្សស្វែងរកលាភសក្ការៈ ស្វែងរកមុខមាត់បុណ្យស័ក្តិ ស្វែងអំណាចអាជ្ញានោះទេ។ ក៏មិនមែនជាមនុស្សកាចសាហាវឃោរឃៅ ដើរចាប់ចងកាប់សម្លាប់នោះដែរ។ ដូច្នេះទោះបីជាមានការចោទប្រកាន់យ៉ាងណាក៏ដោយ ក៏នៅតែជឿទុកចិត្ត"។ សូមចប់ការដកស្រង់។

[១៥:១០:៥៩]

លើសពីនេះលោក ចៅ សុគន្ធ ជាសាក្សីម្នាក់របស់អង្គជំនុំជម្រះបានឆ្លើយបញ្ជាក់អំពីអត្តចរិត

របស់លោក ខៀវ សំផន ដោយបានទទួលស្គាល់គុណសម្បត្តិរបស់លោក ខៀវ សំផន ថាជាមនុស្ស ស្អាតស្អំ ស្រឡាញ់យុត្តិធម៌ និងជាមនុស្សដែលមានប្រជាប្រិយភាព។ នៅក្នុងសវនាការនាថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ លោក ចៅ សុគន្ធ បានឆ្លើយបញ្ជាក់ពីកេរ្តិ៍ឈ្មោះល្បីល្បាញរបស់លោក ខៀវ សំផន ថា សូមដកស្រង់៖ "ជំនាន់នោះគឺថាកេរ្តិ៍គាត់ហ្នឹង យើងខ្ញុំជានិស្សិត ថាខ្ញុំមិនមែនម្នាក់ឯងទេ គឺច្រើនណាស់ទទួលស្គាល់នូវគុណសម្បត្តិរបស់គាត់ ថាគាត់ជាមនុស្សស្អាតស្អំ ជាមនុស្សស្រឡាញ់យុត្តិធម៌។ ហេតុដូច្នេះខ្ញុំបានដំណឹងពីលោក ខៀវ សំផន តាំងពីខ្ញុំអាយុ១២, ១៣, ១៤ឆ្នាំមកហ្នឹង។ គឺថាឮដូច្នេះទៅហើយ"។ សូមចប់ការដកស្រង់។ លោក ចៅ សុគន្ធ ក៏បានឆ្លើយបញ្ជាក់ចំពោះមុខអង្គជំនុំជម្រះផងដែរថា ប្រជាប្រិយភាពរបស់លោក ខៀវ សំផន នៅមានរហូតគ្មានប្រែប្រួល។ ដោយលោកបានអះអាងថា សូមដកស្រង់៖ "ប្រជាប្រិយភាពរបស់គាត់ តាមខ្ញុំយល់គឺថាគ្មានថយចុះអីទេ ផ្ទុយទៅវិញសភាពការណ៍ឥឡូវនេះទៀតមានតុលាការមានអីទៀត ធ្វើឲ្យបងប្អូនយើងចាប់អារម្មណ៍ពីការរងគ្រោះរបស់គាត់ ដែលត្រូវដោះស្រាយឲ្យបានយុត្តិធម៌"។ សូមចប់ការដកស្រង់។

[១៥:១២:៤៦]

ដូច្នេះគ្នានេះដែរ លោកស្រី សូ សុជាតិ ក៏បានបញ្ជាក់បន្ថែមជូនអង្គជំនុំជម្រះផងដែរអំពីទឹកចិត្តស្មោះត្រង់ មិនលោភលន់របស់លោក ខៀវ សំផន ចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃទី១០ ខែមិថុនា បានឆ្លើយថា៖ "គាត់គោរពទៅអ្វីដែលគាត់ឃើញថាល្អ គាត់គោរព។ អានេះចង់និយាយថាស្មោះត្រង់ មិនមានថាលោភលន់អំណាចឬមួយអីទេ ចង់បញ្ជាក់ថាជាទ្រព្យសម្បត្តិអីក៏គាត់មិនមែនជាអ្នកលោភលន់ គាត់ឈ្មោះត្រង់ តែគេឲ្យអីគាត់យកហ្នឹងប៉ុណ្ណឹង។ ចង់និយាយអ៊ីចឹង គឺសន្តានចិត្តស្មោះត្រង់នឹងជាតិ គាត់មិនមានមហិច្ឆតាចង់ធ្វើអ្វីក្រៅពីបម្រើជាតិនោះទេ"។ សូមចប់ការដកស្រង់។

នៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ លោក សុខ រឿ ដែលជាសាក្សីម្នាក់បានស្គាល់លោក ខៀវ សំផន យ៉ាងជិតស្និទ្ធក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងក្រោយឆ្នាំ១៩៧៩ បានឆ្លើយបញ្ជាក់ចំពោះមុខអង្គជំនុំជម្រះផងដែរថា សូមដកស្រង់ "អាកប្បកិរិយាដែលខ្ញុំធ្លាប់រស់នៅជាមួយ គាត់មិនមែនជាមនុស្សឆេវឆាវ ហើយគាត់ងាយចេះថាផ្ដេសផ្ដាស ហើយគាត់ជាមនុស្សមួយហ្នត់ចត់ចេះពិចារណា។ គាត់មិនចេះតែខាងអត់ដឹងក្បាលកន្ទុយនោះទេ។ នេះចរិតរបស់គាត់"។ សូមចប់ការដកស្រង់។

[១៥:១៤:៤៥]

ក្រុមប្រឹក្សាជំនុំជម្រះ លោក ខៀវ សំផន ជាមនុស្សដែលរស់ក្នុងជីវភាពសាមញ្ញក្នុងសង្គម ទោះ

បីលោកមានឋានៈខ្ពង់ខ្ពស់ និងមានចំណេះដឹងជ្រៅជ្រះយ៉ាងណាក៏ដោយ។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ នៅចំពោះមុខអង្គជំនុំជម្រះ លោក ហ្វីលីព ហ្ស៊ីល្យាន-ហ្គោប្រៃស បានឆ្លើយអះអាងថា សូមដកស្រង់៖ "នៅឆ្នាំ២០០៥ ខ្ញុំនៅប៉ៃលិន ខ្ញុំស្នាក់នៅផ្ទះគាត់ ហើយខ្ញុំឃើញផ្ទះចាស់របស់គាត់នៅទីនោះ គឺថាផ្ទះក្បឿង ដែលខ្ញុំបានពិពណ៌នាអម្បាញ់មិញអីចឹង។ ហើយក្រោយមក គាត់នៅផ្ទះថ្ម ប្រពន្ធគាត់ធ្វើការ ធ្វើម្ហូបអាហារនៅក្រៅផ្ទះ។ អីចឹងផ្ទះនោះមិនមានផាសុខភាពអីទេ។ អត់ទាំងមានទឹកម៉ាស៊ីនផង"។ សូមបិទការដកស្រង់។ ចំណុចនេះ បញ្ជាក់ពីការរស់នៅក្នុងលក្ខណៈសាមញ្ញរបស់លោក ខៀវ សំផន ជាមួយនឹងក្រុមគ្រួសាររបស់គាត់។ លើសពីនេះទៀត លោក ហ្គោប្រៃស ក៏បានបញ្ជាក់អំពីទឹកចិត្តរបស់ប្រជាជននៅតាមផ្លូវ ខណៈដែលលោកកំពុងធ្វើដំណើរជាមួយលោក ខៀវ សំផន ដោយបានកត់សម្គាល់ឃើញថា មានប្រជាជនគោរពស្រឡាញ់ លោក ខៀវ សំផន យ៉ាងច្រើន។ លោកបានឆ្លើយបញ្ជាក់ថា សូមដកស្រង់៖ "នៅតាមភូមិផ្សេងៗនោះ ខ្ញុំសង្កេតឃើញថា ប្រជាជននៅតាមភូមិនោះ នៅគោរពលោក ខៀវ សំផន ច្រើនណាស់ គឺគោរពស្រឡាញ់គាត់"។ សូមបិទការដកស្រង់។

[១៥:១៦:៤៨]

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ លោក ប៉ុងសូដ៍ ដែលជាអ្នកបានស្គាល់លោក ខៀវ សំផន នៅសម័យសង្គមរាស្ត្រនិយម បានឆ្លើយបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះផងដែរថា សូមដកស្រង់៖ "ខ្ញុំសរសើរលោក ខៀវ សំផន ជាមនុស្សស្អាតស្អំ មិនពុករលួយ ហ៊ានតវ៉ារកយុត្តិធម៌ ប្រឆាំងអយុត្តិធម៌ នៅសម័យរាជានិយមសម្តេច សីហនុ។ លោកត្រូវនគរបាលធ្វើបាបផ្តេសផ្តាសនៅមុខរដ្ឋសភា។ ហេតុនេះហើយ ខ្ញុំសូមសរសើរលោក ខៀវ សំផន"។ សូមចប់ការដកស្រង់នេះ។

នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ លោក ហ្វីលីព ហ្ស៊ីល្យាន-ហ្គោប្រៃស បានឆ្លើយចំពោះមុខអង្គជំនុំជម្រះថែមទៀតថា "លោក ខៀវ សំផន ជាមនុស្សស្អាតស្អំ ជាមនុស្សស្មោះត្រង់ ហើយភាពស្មោះត្រង់របស់គាត់នេះ គឺថាគេទទួលស្គាល់គាត់ ទោះបីគេកាន់និន្នាការនយោបាយខុសពីគាត់ក៏ដោយ។ ដូច្នេះភាពស្មោះត្រង់របស់គាត់នេះហើយ និងចំណាប់អារម្មណ៍របស់គាត់ទៅលើបញ្ហាសង្គម មានទំហំធំធេងណាស់"។ ដោយលោកបានបញ្ជាក់បន្ថែមថា សូមដកស្រង់៖ "រូបភាពនេះ គឺជារូបភាពមួយ ដែលចលនាខ្មែរក្រហមអាចប្រើដើម្បីឲ្យទុកចិត្តលោក ខៀវ សំផន"។ សូមចប់ការដកស្រង់។ ជម្រើសទាំងអស់របស់លោក ខៀវ សំផន ទោះអាក្រក់ក្តី ល្អក្តី សុទ្ធតែមានហេតុផល ដើម្បីចង់លើកស្ទួយប្រជាជាតិកម្ពុជា។

[១៥:១៩:00]

ខ្ញុំសូមបន្តលើកពីការសិក្សារបស់លោក នៅក្នុងប្រទេសបារាំងដែលជាផ្នែកមួយ។ តំណាងសហព្រះរាជអាជ្ញាបានលើកថា ជាការចាប់ផ្តើមនៃនិន្នាការនយោបាយរបស់លោក ខៀវ សំផន។

ខ្ញុំសូមលើកឡើងខ្លីៗអំពីអំឡុងពេលលោក ខៀវ សំផន សិក្សានៅប្រទេសបារាំង ដោយគូសបញ្ជាក់តែពីចរិតលក្ខណៈ។ ខ្សោយហួសហេតុរបស់តំណាងសហព្រះរាជអាជ្ញាដែលចាត់ទុកថា ការដែលមានលក្ខណៈសម្បត្តិជាជនកុម្មុយនីស្ត ឬបានរាប់អានមជ្ឈដ្ឋានកុម្មុយនីស្តនៅក្នុងទសវត្សរ៍៥០ ទៅ ៦០ គឺជាអំពើឧក្រិដ្ឋស្រេចទៅហើយ។ លោក ខៀវ សំផន ក៏បានឆ្លើយតបទៅនឹងចំណុចនេះ នៅពេលបើកសវនាការដេញដោលរួចហើយដែរ។ លោក ខៀវ សំផន បានជម្រាបជូនអង្គជំនុំជម្រះ កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១១ថា សូមដកស្រង់៖ “ជាការពិតណាស់ខ្ញុំក៏បានចាប់អារម្មណ៍ពីលទ្ធិកុម្មុយនីស្ត ហើយខ្ញុំក៏បានសិក្សាអំពីទ្រឹស្តីកុម្មុយនីស្តដែរ។ ចុះយ៉ាងម៉េច! នៅថ្ងៃនេះលោកអស់សំណើចពេបជ្រាយ ប៉ុន្តែខ្ញុំត្រូវរំឭកលោកថា នាពេលនោះកុម្មុយនីស្តគឺជាចលនាមួយដែលផ្តល់សេចក្តីសង្ឃឹមដល់យុវជនរាប់លាននាក់នៅលើសាកលលោកទាំងមូល”។ សូមចប់ការដកស្រង់។

[១៥:២០:៥២]

ការបញ្ជាក់របស់លោក ខៀវ សំផន ត្រង់ចំណុចនេះ គឺចង់បង្ហាញថាការសម្រេចចិត្តរបស់លោកនៅក្នុងការចូលរួមបក្សកុម្មុយនីស្តបារាំង ជាការសម្រេចខុសឬ? ក៏ប៉ុន្តែ កាលពីសម័យនោះគេប្រាកដជាយល់ថា ការសម្រេចចិត្តរបស់លោកពិតជាត្រឹមត្រូវ គឺដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរណាមួយដែលអាចផ្តល់បទពិសោធន៍ល្អដល់ប្រទេសកម្ពុជា។ ការចូលរួមរបស់លោក ខៀវ សំផន គឺដើម្បីស្វែងរកការអភិវឌ្ឍជីវភាពរបស់ប្រជាពលរដ្ឋ សេដ្ឋកិច្ចជាតិ និងសមភាពនៅក្នុងសង្គម។ លោក ខៀវ សំផន បានឆ្លើយតបទៅនឹងកថាខណ្ឌ១១២៦ និង១១៥៩ នៃដីកាដំណោះស្រាយថា លោកបានជាប់សញ្ញាបត្រទុតិយភូមិនៅឆ្នាំ១៩៥១ ហើយលោកត្រូវធ្វើការដើម្បីសន្សំទុនទុកឲ្យម្តាយ និងប្អូនៗរបស់លោកចិញ្ចឹមជីវិត។

[១៥:២២:១១]

លោកបានធ្វើជាសាស្ត្រាចារ្យ នៅអនុវិទ្យាល័យបច្ចេកទេស ហើយទន្ទឹមនឹងនោះ លោកក៏បានរៀនចប់ -- រៀនច្បាប់នៅភ្នំពេញផង រហូតដល់ឆ្នាំ១៩៥៣ ទើបលោកបានចេញទៅរៀនប៉ារីស។ លោក ខៀវ សំផន ក៏បានបញ្ជាក់ផងដែរ លោកមិនបានជួប សាឡុត ស ដែលហៅថា ប៉ុល ពត នោះទេ។

ពីព្រោះគាត់ត្រឡប់មកប្រទេសកម្ពុជាវិញហើយ។ លោក ខៀវ សំផន មានគោលបំណងសំខាន់នៅពេលនោះ គឺដើម្បីចូលរួមទាមទារឯករាជ្យឲ្យប្រទេសកម្ពុជាពីអាណានិគមនិយមបារាំង។ លោកបានបញ្ជាក់ថា នៅពេលដែលលោកបានទៅដល់ទីក្រុងប៉ារីសបានពីរបីខែ ក៏មានមិត្តភក្តិរបស់លោកម្នាក់ដែលស្គាល់គ្នានៅវិទ្យាល័យស៊ីសុវត្ថិឈ្មោះ ឌិក សុគន្ធ បាននិយាយស្នើលោកឲ្យចូលរួមក្នុងរង្វង់ម៉ាក្ស-ស៊ីស តែលោកបានឆ្លើយតបវិញថា សូមដកស្រង់៖ “ខ្ញុំចង់បានឯករាជ្យជាតិ តែខ្ញុំមិនយល់អ្វីពីកុម្មុយនីស្តពីម៉ាក្សស៊ីសអីទេ”។ សូមចប់ការដកស្រង់។ លោក ឌិក សុគន្ធ បានឆ្លើយតបវិញដោយពន្យល់គាត់ថា សូមដកស្រង់ “រង្វង់ម៉ាក្សស៊ីស មានទិសដៅឲ្យយើងបានយល់ដឹងទូលំទូលាយដើម្បីយើងអាចរកផ្លូវឈានទៅដល់ឯករាជ្យ”។ សូមចប់ការដកស្រង់។

[១៥:២៣:៤៣]

ពេលនោះហើយដែលលោក ខៀវ សំផន បានសម្រេចចិត្តយល់ព្រមចូលរួមក្នុងរង្វង់ម៉ាក្សស៊ីស ប៉ុន្តែលោកមិនបានចំណាយពេលច្រើននៅលើនយោបាយនោះទេ ហើយលោកបានចេញពីក្រុងប៉ារីសទៅរៀននៅទីក្រុងម៉ុងប៉ូលីយេ នៅភាគខាងត្បូងប្រទេសបារាំងឯណោះវិញ។ នៅទីនោះលោកបានរៀនច្បាប់ ហើយក៏បានរៀនពាណិជ្ជកម្ម ដូច្នេះឃើញថា ទំនាក់ទំនងរបស់លោក ខៀវ សំផន ជាមួយនិងរង្វង់ម៉ាក្សស៊ីសនៅឆ្ងាយពីគ្នា។ លោកមានឱកាសចូលរួមក្នុងរង្វង់ម៉ាក្សស៊ីសបានម្តងក្នុងពេលវិស្សមកាលរដូវក្តៅប៉ុណ្ណោះ។ បីឆ្នាំក្រោយមកទើបលោក ខៀវ សំផន មកទីក្រុងប៉ារីសដើម្បីរៀបចំនិក្ខេបបទរបស់ខ្លួនខាងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទើបលោកមានឱកាសចូលរួមក្នុងរង្វង់ម៉ាក្សស៊ីសទៀត។ ប៉ុន្តែបរិបទនយោ-បាយនៅកម្ពុជាប្រែប្រួលទៅហើយ ដោយហេតុថា កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ បានទទួលស្គាល់ឯករាជ្យរបស់កម្ពុជា។ ដូច្នេះទិសដៅនៃការទាមទារឯករាជ្យមិនចោទជាបញ្ហាទៀតទេ ព្រោះថាការនាំគ្នាត្រៀមខ្លួនចូលរួមតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំង ដើម្បីបំពាក់ស្មារតីស្នេហាជាតិនោះមិនមានតែភាពខ្លាំងក្លាដូចមុនទេ។ គ្រាន់តែគេជំរុញឲ្យសមាជិកចូលបក្សកុម្មុយនីស្តបារាំង។ លោក ខៀវ សំផន ត្រូវបានរើស -- ត្រូវបានជ្រើសរើសឲ្យទទួលដំណែងបន្តពីលោក អៀង សារី ដែលលោក ខៀវ សំផន យល់ព្រមទទួលក្នុងគោលបំណងជួយបំផុសស្មារតីស្នេហាជាតិដ៏សមាជិកជានិស្សិត។ លោក ខៀវ សំផន បានបញ្ជាក់ផងដែរថា មានភាពផ្ទុយគ្នារវាងសមាគមដែលដឹកនាំដោយ ប៉ុល ពត, វ័ត្ន សាមឿន, អៀង សារី ដែលជាសាខាកម្មករ ខុសពីសាខារបស់លោកដែលជាសាខានិស្សិត។

[១៥:២៦:០៧]

ប៉ុន្តែមួយឆ្នាំក្រោយមកលោកក៏បានឈប់ទទួលបណ្ណសមាជិក ឈប់ចូលរួមសកម្មភាពរបស់បក្សកុម្មុយនីស្តបារាំង ដោយហេតុថា គេប្រជុំពិភាក្សាតែបញ្ហារបស់បារាំងមិនសូវមានប្រយោជន៍អ្វីដល់រូបលោកជាខ្មែរនោះទេ។ ហើយនៅពេលត្រឡប់មកកម្ពុជាវិញ លោកក៏គ្មានទំនាក់ទំនងអ្វីជាមួយបក្សកុម្មុយនីស្តកម្ពុជាដែរ។ ការដែលលោកចូលជាសមាជិកបក្សកុម្មុយនីស្តបារាំងពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៥៦ ក៏ព្រោះតែបក្សនោះបានលើកទឹកចិត្តរាល់អ្នកទាំងឡាយណាដែលរស់នៅក្រោមនឹមអាណានិគមនិយមនៅគ្រប់ទីកន្លែងនៅលើពិភពលោកឲ្យចូលរួមជាកម្លាំងជាមួយពួកគេ និងគាំទ្រកិច្ចខំប្រឹងប្រែងប្រឆាំងសង្គ្រាមនៅវៀតណាម។ លោកគិតថា ការតស៊ូរួមគ្នានេះនឹងចូលរួមចំណែកជំរុញឲ្យប្រទេសកម្ពុជាឆាប់ទទួលបានឯករាជ្យ។ លោក ខៀវ សំផន ក៏បានបញ្ជាក់ផងដែរនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ថា សូមដកស្រង់៖ "ខ្ញុំបានចូលរួមបក្សកុម្មុយនីស្តបារាំងនៅឆ្នាំ១៩៥៥ មូលហេតុគឺមកពីបក្សនេះប្រឆាំងនឹងអាណានិគម គាំទ្រការតស៊ូរបស់ប្រជាជនដែលនៅក្រោមការជិះជាន់ដើម្បីឯករាជ្យ និងអធិបតេយ្យជាតិរបស់គេ ហើយបំផុសឲ្យប្រជាជននៅក្នុងសាកលលោករួបរួមសាមគ្គីគ្នា" ចប់ការដកស្រង់។

[១៥:២៨:០៤]

លើសពីនេះទៀត លោកបានបញ្ជាក់ថា សូមសកស្រង់៖ "បក្សនេះបានប្រមូលកម្លាំងរៀបចំបាតុកម្ម ប្រឆាំងសង្គ្រាមវៀតណាម" ចប់ការដកស្រង់។ ដោយសារតែមូលហេតុនេះហើយទើបលោក ខៀវ សំផន សម្រេចចិត្តចូលរួមបក្សកុម្មុយនីស្តបារាំង។ វាពិតជាងាយណាស់សម្រាប់អ្នកស្ថិតនៅក្នុងឆ្នាំ២០១៣ ក្នុងការបំភ្លេចសម័យកាលសង្គ្រាមត្រជាក់និងចលនាឯករាជ្យ។ ប៉ុន្តែវាជាការពិតដែលបានបង្កើតឲ្យមានមនសិការនយោបាយដល់និស្សិតជាច្រើននៅអាស៊ី ឬអាហ្វ្រិកក្នុងខណៈពេលដែលអ្នកទាំងនោះរស់នៅប្រទេសបារាំង។

អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ភាពដាច់ខាតដែលគេចោទលើរូបលោក ខៀវ សំផន មិនមែននៅក្នុងការងារនិក្ខេបបទរបស់លោកដែលចង់ឲ្យមានការអភិវឌ្ឍប្រទេសកម្ពុជាឲ្យទៅជារបបមូលធននិយមជាតិស្វយ័តនោះទេ។ គោលបំណងចម្បងរបស់លោក ខៀវ សំផន គឺការផ្តើមគំនិតកែទម្រង់សេដ្ឋកិច្ច និងសង្គម ដើម្បីបោះមូលដ្ឋានមួយសម្រាប់សេដ្ឋកិច្ចឯករាជ្យរបស់ប្រទេស ដូចគេបានអនុវត្តនៅប្រទេសជប៉ុន។ ហេតុនេះ លោកសម្រេចចិត្តជ្រើសរើសយកប្រធានបទនៃនិក្ខេបបទរបស់ខ្លួនលើបញ្ហានៃឧស្សាហូបនីយកម្មកម្ពុជា ដោយលោកមានជំនឿថា ឲ្យតែមានវិធានការសមស្របនាយទុន

ជាតិមួយនឹងអាចរីកលូតលាស់បាន។ លោកបានចោទសំណួរសំខាន់នៅក្នុងនិក្ខេបបទនោះថា តើហេតុអ្វីបានជារចនាសម្ព័ន្ធសេដ្ឋកិច្ចនាពេលនោះមិនអាចឲ្យមានការអភិវឌ្ឍប្រទេសកម្ពុជាបាន? ចម្លើយគឺថា ទំនិញឧស្សាហ៍កម្មរបស់បារាំងបានមកប្រកួតប្រជែងមួយនឹងសិប្បកម្មខ្មែរ។ ដូច្នេះ ធ្វើឲ្យសិប្បកម្មខ្មែរត្រូវរួញក្តោបងើបមិនរួច ដែលលោកបានកត់សម្គាល់ថា បានធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចកសិកម្មអន់ថយទៅវិញ។ លោក ខៀវ សំផន បានគិតថារដ្ឋត្រូវតែកាន់កាប់ពាណិជ្ជកម្មក្រៅប្រទេសជាឧប-ករណ៍សម្រាប់ការរីកលូតលាស់នៃសិប្បកម្ម ហើយតម្រង់ការងារទៅខាងផលិតកម្ម និងតម្រង់កម្លាំងការងារទៅខាងពាណិជ្ជកម្ម ដោយលោកបានផ្អែកលើទ្រឹស្តីអ្នកសេដ្ឋសាស្ត្រឈ្មោះ អាដាំ ស្មីត ជាជនជាតិស្កុតឡែន។

[១៥:៣១:០២]

ម្យ៉ាងទៀត និក្ខេបបទរបស់លោក ខៀវ សំផន មិនបានតម្រូវឲ្យលុបបំបាត់ការប្រើប្រាស់លុយនោះទេ ហើយក៏មិនបានស្នើឲ្យលុបបំបាត់កម្មសិទ្ធិឯកជន និងទីក្រុងដែរ។ ដូច្នេះ មិនមានន័យថារបបកម្ពុជាប្រជាធិបតេយ្យបានប្រើប្រាស់និក្ខេបរបស់លោក ខៀវ សំផន ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចជាតិនាសម័យនោះនោះទេ។ គឺថាដូចការអះអាងរបស់លោក ស្បូត និងលោក ហ្ស៊ីល្យាន-ហ្គោហ្វ្រៃស ដែលមានប្រសាសន៍ថា គេមិនយកនិក្ខេបបទនេះទៅប្រើប្រាស់ ដើម្បីកសាងគម្រោងសេដ្ឋកិច្ចក្នុងសម័យខ្មែរក្រហមនោះឡើយ។

លោក ហ្វីលីព ស្បូត បានឆ្លើយបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ អំពីនិក្ខេបបទរបស់លោក ខៀវ សំផន ពាក់ព័ន្ធនឹងវិស័យវិនិយោគ ដែលលោកសង្ខេបថា សូមដកស្រង់៖ “ជាប្រធានបទសំខាន់នោះគឺ ការផ្លាស់ប្តូរពីសេដ្ឋកិច្ចអាណានិគម ដែលមានន័យថា សេដ្ឋកិច្ចមួយដែលបរទេសនាំចូលមកនូវវត្ថុធាតុដើម ហើយបន្ទាប់មកទៀតលក់ផលិតផលសម្រេច។ ដូច្នេះ វាពាក់ព័ន្ធទៅនឹងឧស្សាហូបនីយកម្ម ដើម្បីលើកតម្លៃធនធានរបស់ប្រទេសកម្ពុជា ដូចជាកសិកម្ម ឈើកៅស៊ូ។

[១៥:៣២:៥៣]

ដូច្នេះតាមលោក ខៀវ សំផន នោះគឺថាត្រូវអភិវឌ្ឍឧស្សាហកម្មដើម្បីលើកតម្លៃផលិតកម្មក្នុងស្រុក គឺដើម្បីលើកស្ទួយដល់សេដ្ឋកិច្ចក្នុងស្រុក។ គាត់ព្រមទុកនូវបទអន្តរាគមន៍របស់រដ្ឋមួយចំនួន ប៉ុន្តែមិនមែនជាអន្តរាគមន៍ដាច់ខាតនិងទាំងស្រុងនោះទេ “ពីព្រោះថាយើងមិនត្រូវធ្វើឲ្យវិនិយោគទុកបរទេស

ភ័យខ្លាចនោះទេ ពីព្រោះថាធនធានរបស់ប្រទេសនោះមិនគ្រប់គ្រាន់សម្រាប់ធ្វើឧស្សាហូបនីយកម្មប្រទេសនេះទេ ហើយនិងមិនអាចឧបត្ថម្ភទៅដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់នោះដែរ"។ សូមចប់ការដកស្រង់។

លោក ហ្វីលីព ស្សូត ក៏បានបញ្ជាក់ពីការចងចាំរបស់លោក ដែលលោកបានធ្វើកំណត់ត្រាចំពោះការបញ្ចប់សំណេរនិក្ខេបបទរបស់លោក ខៀវ សំផន ដែលលោកបាននិយាយថា សូមដកស្រង់៖ "ចង់ឲ្យសេដ្ឋកិច្ចកម្ពុជានោះមានស្វ័យភាព គឺថាមិនមែនឲ្យខ្លួនឧបត្ថម្ភខ្លួនទាំងស្រុងនោះទេ"។ ចប់ការដកស្រង់។ លើសពីនេះលោក ហ្វីលីព ស្សូត បានបញ្ជាក់ទៅលើស្នាវតីអន្តរាគមន៍របស់លោក ខៀវ សំផន នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៥៩ នៅពេលដែលលោកនិយាយជាសាធារណៈ ដោយប្រៀបធៀបជាមួយនឹងការពិភាក្សាឯកជនជាមួយនឹងលោក ដែលលោក ខៀវ សំផន ថាត្រូវគ្នានឹងពាក្យពេចន៍ដែលលោកបានជជែកសំណេះសំណាលជាឯកជននោះ។ លោក ខៀវ សំផន បានសង្កត់ធ្ងន់ទៅលើសង្គមកិច្ច ដែលមានន័យថាត្រូវតែអភិវឌ្ឍសេដ្ឋកិច្ចប្រទេស ដើម្បីបង្កើនជីវភាពប្រជាជន។ ដូចលោក ហ្វីលីព ស្សូត បានកត់សម្គាល់ថា កាលដែលលោក ខៀវ សំផន ប្រឆាំងនឹងការលុបបំបាត់អំពីរូបិយប័ណ្ណនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺជាឧទាហរណ៍ជាក់ស្តែង។

[១៥:៣៥:១៨]

នៅពេលត្រឡប់មកកម្ពុជាវិញ លោក ខៀវ សំផន បានបង្កើតកាសែតឯករាជ្យមួយ ដែលជាមួយនឹងកាសែតនោះ លោកបានទិតៀនយ៉ាងសុភាពរាបសា ដោយភាពក្លាហាន ចំពោះអំពើអយុត្តិធម៌នៅក្នុងសង្គមនៃរបបសម្តេច នរោត្តម សីហនុ។ លោកត្រូវបាននគរបាលរបស់សម្តេចធ្វើឲ្យអាម៉ាស់ជាសាធារណៈ ហើយចាប់ដាក់គុក ដោយគ្មានការជំនុំជម្រះ។ កាសែត ឡូបស៊ែរវ៉ាទ័រ ក៏ត្រូវហាមឃាត់មិនឲ្យចេញផ្សាយ។ តែទោះជាយ៉ាងណា លោកបន្តរស់នៅភ្នំពេញដែលជាទីនោះ លោកត្រូវនគរបាលឃ្លាំមើលជាប់ជានិច្ច។ ហើយលោកនៅតែព្យាយាមបន្តឆន្ទៈក្នុងការកែប្រែប្រទេសកម្ពុជាប្រកបដោយសន្តិវិធី។

ក្រោយពីការចូលប្រឡូកក្នុងនយោបាយចំនួនពីរលើក ហើយកាន់កាប់មុខងារជារដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្មនៅក្នុងរាជរដ្ឋាភិបាលរបស់សម្តេច សីហនុ លោកបានចូលរួមក្នុងរាជរដ្ឋាភិបាលគឺដើម្បីជំទាស់រាល់អំពើពុករលួយនៅពេលនោះ។

[១៥:៣៦:៤៣]

នៅក្នុងសវនាការថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ លោក នូ ហ៊ាន់ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី បានឆ្លើយបញ្ជាក់អំពីភាពស្អាតស្អំរបស់លោក ខៀវ សំផន ថា សូមដកស្រង់៖ "គាត់មិនចូលចិត្តរឿងបញ្ហាពុករលួយអីផ្សេងៗហ្នឹងទេ" សូមបញ្ចប់ការដកស្រង់។ ហើយលោកបានលើកឧទាហរណ៍នូវអង្គហេតុមួយពាក់ព័ន្ធនឹងឈ្មួញម្នាក់ បានយករថយន្តមែរស៊ីដេសថ្មីមួយគ្រឿងមកទុកឲ្យលោក ខៀវ សំផន តែលោកបានបញ្ជាឲ្យគេយកទៅប្រគល់ឲ្យម្ចាស់វិញ។ ទោះបីសាក្សីរូបនេះមិនបានឃើញផ្ទាល់ភ្នែកពីភាពស្អាតស្អំរបស់លោក ខៀវ សំផន ប៉ុន្តែភាពល្បីល្បាញរបស់លោក ខៀវ សំផន មានពាសពេញប្រទេស។

ស្រដៀងគ្នានេះដែរ នៅថ្ងៃទី០៩ ខែមករា អ៎! សូមទោស នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៣ លោក ប៉ុងសូដ៍ បានឆ្លើយបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះផងដែរថា សូមដកស្រង់៖ "លោកឯកឧត្តម ខៀវ សំផន ជាមីស្ទើឃ្លីន។ ហើយសម្តេច សីហនុ បានតែងតាំងលោកឲ្យកាន់ក្រសួងពាណិជ្ជកម្ម"។ ចប់ការដកស្រង់។ លោក ប៉ុងសូដ៍ ក៏បានដឹងរឿងថា លោក ខៀវ សំផន មិនព្រមទទួលសំណូករថយន្តមែរស៊ីដេសនេះដែរ។ ដោយលោកបានបញ្ជាក់បន្ថែមថា ដើម្បីជាថ្នូរឲ្យគាត់ចុះហត្ថលេខពីរឿងទិញសាច់ តែគាត់មិនព្រម។ លោក ប៉ុងសូដ៍ បានឆ្លើយបញ្ជាក់ពីការកោតសរសើររបស់យុវជន បញ្ញវន្ត គ្រូបង្រៀន និងរូបលោកផ្ទាល់ ចំពោះលោក ខៀវ សំផន ដែលជា "*អាយឌុល*" របស់ពួកគេ។

[១៥:៣៨:៣៩]

នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៣ នៅចំពោះមុខអង្គជំនុំជម្រះ លោក ឈូក រីន ក៏បានរៀបរាប់អំពីការជឿជាក់របស់លោកចំពោះលោក ខៀវ សំផន ផងដែរថា សូមដកស្រង់៖ "ជាមនុស្សមានសច្ចភាពណាស់ ហើយបើខ្ញុំនិយាយអំពីប្រវត្តិកងទ័ពលំបាកវេទនាហ្នឹង គាត់ប្រហែលជាបានត្រឹមតែសោកស្តាយទឹកភ្នែកពីអតីកាលតែប៉ុណ្ណឹង"។ សូមចប់ការដកស្រង់។ ម្យ៉ាងទៀតលោក ឈូក រីន បានបន្ថែមថា សូមដកស្រង់៖ "លោក ខៀវ សំផន មិនអាចលាក់ប្រវត្តិរូបរបស់ខ្លួនឯងបានទេ ដោយសារតែភាពល្បីល្បាញរបស់លោក ដោយបញ្ជាក់ថា "ព្រោះកាលនោះខ្ញុំនៅជាកូនសិស្ស តែគេតែងតែនិយាយកាលសម័យគាត់ធ្វើរដ្ឋមន្ត្រី ធ្វើតំណាងរាស្ត្រ លោកទៅប្រជុំ តែងតែគេយកវីរភាពថា លោកគ្មានឡានជិះហ្នឹងគេទេ។ លោកជិះតែកង់ទៅធ្វើការ ព្រោះលោកស្រលាញ់រាស្ត្រណាស់ ហើយគាត់ល្បីឈ្មោះសំខាន់ហ្នឹង គឺគាត់និយាយពេលសមាជជាតិម្តងៗ ហើយអ៊ីចឹងបានធ្វើឲ្យគាត់មិនអានលាក់កំបាំងនូវរឿងរ៉ាវហ្នឹងទេ។ រឿងរ៉ាវដែលកើតជំនាន់គាត់រត់ចេញនោះ មកចូលច្រកព្រៃនេះ គឺគេស្គាល់ច្បាស់

ហើយគាត់លាក់មិនបានទេ។ ព្រោះខ្ញុំនៅក្មេង ក៏ខ្ញុំដឹងថាគាត់ជាបញ្ញវន្តរបស់ខ្មែរយើងមួយរូបដែរ”។ សូមចប់ការដកស្រង់។ លោក ឈូក រីន ក៏បានបញ្ជាក់ពីភាពស្អាតស្អំរបស់លោក ខៀវ សំផន ផងដែរ ដោយបញ្ជាក់ថា “លោក ខៀវ សំផន ធ្វើតំណាងរាស្ត្រក្តីហ្នឹង ធ្វើរដ្ឋមន្ត្រីក្តីហ្នឹង គាត់ជាបុគ្គលមួយ ស្អាតស្អំ មិនពុករលួយមិនស្អី សម្រាប់គំរូមួយដល់ជនជាតិកម្ពុជាគួរឲ្យគោរព”។ សូមចប់ការដកស្រង់។

[១៥:៤០:៤៥]

ចំណែកឯលោក ហ៊ុន ឈុនលី ក៏បានបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១២ អំពីភាពស្អាតស្អំរបស់លោក ខៀវ សំផន ផងដែរ។ សូមដកស្រង់៖ “ខ្ញុំស្គាល់លោក ខៀវ សំផន ក្នុងឋានៈគាត់ជាបញ្ញវន្តមួយរូប ជាប្រធានកាសែតឡុបសែរវ៉ាទ័រ ហើយនិងជារដ្ឋមន្ត្រីមួយដែល គេទទួលស្គាល់ថា ជាមន្ត្រីស្អាតស្អំ”។ សូមចប់ការដកស្រង់។ លោក ហ៊ុន ឈុនលី បានបញ្ជាក់ពីការ កោតសរសើរ និងការគោរពចំពោះលោក ខៀវ សំផន ពីព្រោះលោក ខៀវ សំផន ជាមនុស្សសាមញ្ញ ស្អាតស្អំ មិនពុករលួយ។

ចំណែកអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ក៏បានញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ផងដែរថា លោកបានស្គាល់លោក ខៀវ សំផន និងបានដឹងពីភាពល្បីល្បាញរបស់ គាត់នៅពេលដែលលោកមកធ្វើការនៅកម្ពុជា ក្នុងឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦២ នៅពេលដែលលោកធ្វើការ នៅស្ថានទូតសហរដ្ឋអាមេរិក។ ដោយគាត់បានបញ្ជាក់អំពីលោក ខៀវ សំផន ថា សូមដកស្រង់៖ “ជាមនុស្សមានការសរសើរ អំពីភាពសុចរិតរបស់គាត់ ខ្ញុំគិតថាសម្តេច សីហនុ មានការភ័យខ្លាចគាត់ ដោយសារថាគាត់មនុស្សមួយដែលស្អាតស្អំ គឺថាមានកិត្តិយស អាចនឹងជាមនុស្សសំខាន់ក្នុងសង្គម ទាក់ទងនឹងក្រុមមនុស្សសំខាន់ធ្វើឲ្យព្រះអង្គមានការព្រួយបារម្ភពីគាត់”។ សូមចប់ការដកស្រង់។

[១៥:៤២:៤៣]

លើសពីនេះ លោក ហ្វីលីព ស្សូត ក៏បានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៣ អំពីកិត្តិយស និងប្រជាប្រិយភាពរបស់លោក ខៀវ សំផន ផងដែរថា សូមដកស្រង់៖ “កាសែតរបស់គាត់គឺធ្វើឲ្យគាត់ជាមនុស្សពិសេស គឺថាជាមនុស្សដែលមានកិត្តិយស មានលទ្ធភាព គឺថា មិនអាចងាយឲ្យគាត់ភ័យបានទេ។ ហើយគាត់ជឿជាក់នៅក្នុងយុត្តិធម៌ ប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេស”។ សូមចប់ការដកស្រង់។ ហើយលោក ស្សូត ក៏បានអះអាងបន្ថែមផងដែរថា សូមដកស្រង់៖ “ប្រសិនបើ របបសីហនុ ទុកឱកាសឲ្យ ខៀវ សំផន ធ្វើការហ្នឹង គឺថានឹងមានអ្វីកើតឡើងល្អ ប៉ុន្តែគាត់មិនមាន

ឱកាសទេ។ នេះហើយដែលថាគាត់ទទួលបានកិត្តិយស ហើយនិងកិត្តិស័ព្ទ ដែលធ្វើឲ្យគេស្គាល់គាត់រហូតដល់ឆ្នាំ១៩៧៥។ នេះហើយជាអ្វីដែលគេទទួលថា ជាវីរជនសម្រាប់គាត់នោះ"។ សូមចប់ការដកស្រង់។ ការអះអាងបញ្ជាក់បន្ថែមទៅលើឆន្ទៈរបស់លោកនៅក្នុងការកែទម្រង់ គឺធ្វើពីថ្នាក់លើចុះមកក្រោម ត្រង់ចំណុចនេះលោក ប៉ុងសូដ៏ បានឆ្លើយបញ្ជាក់ចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ ផងដែរថា សូមដកស្រង់៖ "បើយើងយកករណីលោក ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម, ចៅ សេង គាត់ទាំងអស់នេះជាអ្នកធ្វើនយោបាយពីថ្នាក់កំពូលមក គឺពីកំពូលមកក្រោម ហើយយកអំណាចតាមក្រសួង ហើយបន្ទាប់មកទៀតបង្កើតជារបបមួយដែលត្រឹមត្រូវជាងរបបមុន"។ សូមចប់ការដកស្រង់។

[១៥:៤៥:០៥]

ចំណែកលោក ហ្វ្រ៊ីល្យាន-ហ្គោហ្វ្រែស ក៏បានជម្រាបជូនអង្គជំនុំជម្រះនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៣ អំពីគោលជំហរល្អរបស់លោក ខៀវ សំផន ផងដែរថា តាមរយៈសុន្ទរកថារបស់លោកនៅពេលលោកអញ្ជើញលោក ខៀវ សំផន ឲ្យទៅធ្វើទស្សនកិច្ចនៅរោងចក្ររបស់ខ្លួន នៅពេលដែលលោកក្លាយជាតំណាងរាស្ត្រនោះ លោក ហ្វ្រ៊ីល្យាន-ហ្គោហ្វ្រែស បានអះអាងថា សូមដកស្រង់៖ "តាមរយៈការសន្ទនាពីមុនមកជាមួយគាត់ ហើយនិងក្រោយមកទៀត ខ្ញុំដឹងថាគាត់ចាប់អារម្មណ៍នឹងបញ្ហាសង្គម ហើយនិងកម្រិតជីវភាព គឺថាគាត់ចង់ឲ្យកសិករអាចលក់ផលិតផលរបស់ពួកគេនៅក្នុងតម្លៃមួយដែលអាចទទួលយកបានសមរម្យ ហើយនិងអាចទទួលប្រាក់កម្ចីដោយមានការប្រាក់តិច។ "កាលណោះការប្រាក់ខ្ពស់ណាស់ ហើយអង្កាល់ណោះគាត់ក៏ចង់នៅក្រៅ គិតពីជីវភាពគាត់គិតពីបញ្ហាសុខភាព ហើយនិងការបណ្តុះបណ្តាលរបស់មនុស្សផងដែរ" សូមចប់ការដកស្រង់។ បន្ថែមពីនេះ លោកបានបន្ថែមបញ្ជាក់ថា និន្នាការនយោបាយរបស់លោក ខៀវ សំផន ក្នុងសម័យនោះជាអ្នកចម្រើនមួយរូបស្រឡាញ់ការស្អាតស្អំ ចង់ឲ្យសង្គមខ្មែរយើងមានយុត្តិធម៌ ដោយចាត់ទុកថាជាអ្នកប្រជាធិបតេយ្យមួយរូបព្រោះថាសម័យនោះគ្មានកុម្មុយនីស្តទេ។ ផ្ទុយស្រះពីការអះអាងរបស់តំណាងសហព្រះរាជអាជ្ញា លោក ខៀវ សំផន មិនមែនជាអាយ៉ងរបស់កម្ពុជាប្រជាធិបតេយ្យនោះទេ លោកមិនបានរស់នៅលាក់ខ្លួន តែលោកបានប្រយុទ្ធយ៉ាងចំហ និងស្របច្បាប់ដើម្បីផ្លាស់ប្តូរសង្គមកម្ពុជា។

[១៥:៤៧:០៩]

ចាប់ពីឆ្នាំ១៩៦៦ មកសម្តេច នរោត្តម សីហនុ បានបាត់បង់នូវការគ្រប់គ្រងលើស្ថានភាព

នយោបាយចំពោះមុខអ្នកស្តាំនិយម តឹងត្អឹងដែលដឹកនាំដោយនាយករដ្ឋមន្ត្រីថ្មីរបស់លោក គឺលោក លន់ នល់។ បន្ទាប់ពីការប៉ះបោររបស់កសិករនៅសំឡូតឆ្នាំ១៩៦៧មក សម្តេចបានចោទប្រកាន់លោក ខៀវ សំផន ថាជាអ្នករួមចំណែកក្នុងចលនានោះហើយប្រកាសចាប់ខ្លួនរូបលោក និងជូនរង្វាន់អ្នកណាដែលចាប់រូបលោកបានទៀតផង។ លោក ខៀវ សំផន បានឆ្វេងយល់ឃើញថា ការគំរាមនេះពិតជាមានស្ថានភាពធ្ងន់ធ្ងរដល់អាយុជីវិត ហេតុនេះលោកក៏បានសម្រេចចិត្តរត់គេចខ្លួនពីរាជធានីភ្នំពេញ។

ដូចការសង្ខេបរបស់លោក ហ្វីលីព ស្បត ដូច្នេះដែរ នៅកម្ពុជាលោក ខៀវ សំផន សូមដកស្រង់៖ “មានកេរ្តិ៍ល្បីតែមួយគត់គឺជាមនុស្សដែលមានកិត្តិយស ដែលមិនងាយនឹងគេគំរាមបាន ហើយដែលជឿជាក់ទៅលើប្រព័ន្ធនយោបាយមួយប្រសើរជាងមុន និងមានយុត្តិធម៌ជាងមុនសម្រាប់ប្រទេសកម្ពុជា។ ប្រសិនបើរបបសម្តេច សីហនុ ទុកតួនាទីនយោបាយមួយជូនដល់មនុស្សដូចលោក ខៀវ សំផន នេះ អនាគតប្រទេសប្រាកដជាខុសពីនោះ។ ដោយសារតែការខ្លាចគេសម្លាប់ និងគ្មានជម្រើសផ្សេងទើបលោក ខៀវ សំផន បានយល់ស្របតាមសំណើរបស់ខ្មែរក្រហមក្នុងការចូលព្រៃ។ ការភ័យខ្លាចរបស់លោក ខៀវ សំផន ពេលនោះគឺមានហេតុផលសមស្របដែលថាអាយុជីវិតរបស់លោកកំពុងស្ថិតនៅគ្រោះថ្នាក់។

[១៥:៤៩:០២]

នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ លោក ប៉ង់សូដ៍ បានឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះថា សូមដកស្រង់៖ “សម្តេច សីហនុ បានធ្វើបាប ខៀវ សំផន ចង់សម្លាប់ ខៀវ សំផន ជារដ្ឋមន្ត្រីខ្មោចនៅឆ្នាំ១៩៦៧។ សម្តេច សីហនុ ចង់ចាប់លោក ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ហើយលោកលួចរត់ទៅកំពតទៅកាន់ តាម៉ុក”។ សូមចប់ការដកស្រង់។ ហើយលើសពីនេះលោក ប៉ង់សូដ៍ បានឆ្លើយបញ្ជាក់យ៉ាងច្បាស់នៅចំពោះមុខអង្គជំនុំជម្រះផងដែរថា សូមដកស្រង់៖ “សម្តេច សីហនុ ជេរលោក ខៀវ សំផន នេះ ខ្ញុំឮផ្ទាល់នឹងត្រចៀក ជេរលោក ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម ជាអ្នកក្បត់ជាតិ” សូមចប់ការដកស្រង់។ ដោយសម្តេច សីហនុ បានចោទលោក ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម ថាជាជនកុម្មុយនីស្តដែលនាំឲ្យអ្នកទាំងបីខាងលើរត់ប្រាសអាយុដើម្បីឲ្យរួចផុតពីការកាប់សម្លាប់។

នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១២ លោក មាស វឿន បានឆ្លើយបញ្ជាក់នៅចំពោះមុខអង្គជំនុំជម្រះអំពីមូលហេតុនៃការរត់ចូលព្រៃរបស់លោក ខៀវ សំផន ថា សូមដកស្រង់៖ “ខ្ញុំពេលនោះខ្ញុំមិនបានសួរលោក -- សាកសួរគាត់ទេ ក៏ប៉ុន្តែខ្ញុំស្តាប់វិទ្យុ វិទ្យុដែលសម្តេច សីហនុ បានជេរគាត់ ហើយនិងរកគាត់

រហូតដល់ចង់កាត់ក្បាលគាត់។ អង្កាល់នោះខ្ញុំមិនចាំទេ គ្រាន់តែថានរណារកឃើញ ខៀវ សំផន ឬ ហ៊ូ យន់ អីគាត់សម្តេចឲ្យប្រាក់លើកទឹកចិត្ត ប៉ុន្មានទេប្រហែលជា៧លាន ខ្ញុំមិនចាំច្បាស់ទេ និងគាត់មានទំនាស់អីខ្ញុំមិនដឹង តែខ្ញុំស្តាប់តាមវិទ្យុ”។ ចប់ការដកស្រង់។

[១៥:៥១:៥៥]

លោក ឆេនដ៍ល័រ ជាប្រវត្តិវិទូម្នាក់ដែលបានមកឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១២ ក៏បានយល់ស្របថា លោក ខៀវ សំផន មានការភ័យខ្លាចពីការគំរាមកំហែង ហើយក៏បានចាកចេញពីភ្នំពេញទៅព្រៃ។ ការផ្សព្វផ្សាយដឹងឮជាសាធារណៈបែបនេះ បានធ្វើឲ្យលោក ខៀវ សំផន មានការភ័យខ្លាចប៉ះពាល់ដល់អាយុជីវិតរបស់ខ្លួន ដែលប្រព្រឹត្តឡើងដោយរដ្ឋាភិបាលនាសម័យនោះ។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ លោក ខៀវ សំផន បានឆ្លើយស្របគ្នាទៅនឹងសម្តីសាក្សី និងអ្នកជំនាញផងដែរថា សូមដកស្រង់៖ “ខ្ញុំមិនបានចូលរួមដោយតស៊ូដោយជំនឿជឿជាក់របស់ខ្ញុំទេ គឺដោយខ្ញុំទាល់ច្រកត្រូវបង្ខំចិត្តការពារសន្តិសុខផ្ទាល់ខ្លួន រត់មកជ្រកក្រោមម្លប់បក្សកុម្មុយនីស្តកម្ពុជាឲ្យជួយការពារខ្ញុំទៅវិញទេ។ ខ្ញុំមិនបានបោះបង់ចោលតំណែងខ្ញុំជាតំណាងរាស្ត្រដោយខ្លួនឯងទេ គឺដោយបង្ខំចិត្ត។ នេះមិនហៅថាជាការចូលរួមតស៊ូបដិវត្តន៍ទេ។ ចំណុចនេះហើយដែលជិតដាមជាប់ប្រវត្តិរបស់ខ្ញុំ”។ សូមចប់ការដកស្រង់។ នេះបញ្ជាក់ឲ្យឃើញថា លោក ខៀវ សំផន គ្មានលក្ខណៈសម្បត្តិសមស្របសម្រាប់បក្សកុម្មុយនីស្តកម្ពុជានោះទេ។ ដោយហេតុថា វត្តមានរបស់លោក ខៀវ សំផន នៅក្នុងក្រុមកុម្មុយនីស្តកម្ពុជា គឺដើម្បីឲ្យគេជួយយកអាសាតែប៉ុណ្ណោះ។ កត្តានេះវាមានការលំបាកណាស់សម្រាប់លោក ខៀវ សំផន ក្នុងការទទួលបានការទុកចិត្តពីថ្នាក់ដឹកនាំរបស់កុម្មុយនីស្តកម្ពុជា។

[១៥:៥២:៥៦]

គ្មានលក្ខខណ្ឌសមស្របដូចការកំណត់នៅក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ដែលមានចែងពីលក្ខណៈសម្បត្តិ១០យ៉ាង ដែលយើងអាចមើលឃើញនៅក្នុងមាត្រាទី៥ នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា។ ខ្ញុំសូមសង្ខេបនូវមាត្រានោះ “ចំណុចនេះទាំង១០នេះ៖ ១) និយាយអំពីគោលជំហរបដិវត្តន៍រឹងប៉ឹងខាងមាគ៌ានយោបាយរបស់បក្ស។ ទី២) ជំហរបដិវត្តន៍រឹងប៉ឹងខាងសតិអារម្មណ៍អធនរបស់បក្ស ៣) ជំហរបដិវត្តន៍រឹងប៉ឹងសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់បក្ស ៤) ជំហរបដិវត្តន៍រឹងប៉ឹងខាងមាគ៌ាដឹកនាំធ្វើការងាររបស់បក្ស ៥) ជំហរបដិវត្តន៍រឹងប៉ឹងខាងការប្រុងប្រយ័ត្នរបស់បក្ស រក្សាការសម្ងាត់ និងការពារកម្លាំងបដិវត្តន៍ ៦) ជំហរបដិវត្តន៍រឹងប៉ឹងខាងឯករាជ្យរបស់ម្ចាស់ការ ខ្លួនទីពឹងខ្លួន និង

ខ្លួនធ្វើម្ចាស់លើខ្លួនរបស់បក្ស ៧) ជំហរបដិវត្តន៍រឹងប៉ឹងខាងការធ្វើ និងត្រួតពិនិត្យប្រវត្តិរូប និងជីវទស្សន៍បដិវត្តន៍ ៨) ជំហរបដិវត្តន៍រឹងប៉ឹងខាងវណ្ណភាព ៩) ជំហរបដិវត្តន៍រឹងប៉ឹងខាងសីលធម៌រស់នៅ ស្អាតស្អំ និងស្អាតស្អំខាងនយោបាយ ១០) លទ្ធភាពកសាងខ្លួន និងតួនាទីដឹកនាំទៅអនាគត"។

[១៥:៥៤:៣៥]

នៅក្នុងចំណុចទាំង១០នេះ មានចំណុចទី១, ទី២, ទី៣ និងទី៤ ជាចំណុចពិសេសដែលអាចជ្រើសរើសឲ្យចូលក្នុងអង្គភាពដឹកនាំផ្សេងៗរបស់បក្សបាន។ តាមការពិនិត្យទៅលើលក្ខណៈសម្បត្តិទាំង ១០ យើងឃើញថា លោក ខៀវ សំផន គ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ឡើយ។ ជាពិសេសលក្ខណៈសម្បត្តិទី១, ទី២ និងទី៨ ដែលលោក ខៀវ សំផន គ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ឲ្យថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទុកចិត្ត ឲ្យកាន់តំណែងសំខាន់ណាមួយដែលមានអំណាចពិតប្រាកដនៅក្នុងជួរបក្សនោះទេ។ ម្យ៉ាងទៀត លោកបានរស់នៅបានពីរឆ្នាំនៅក្នុងព្រៃម៉ាគីទៅហើយ គឺនៅឆ្នាំ១៩៦៩ ទើបលោកបានចូលជាសមាជិកបក្ស។ លោកបានរស់នៅដាច់ពីគេដ៏យូរនៅក្នុងព្រៃអស់រយៈពេលប្រាំពីរឆ្នាំជាមួយនឹងកសិករដែលបានខឹតខំតស៊ូដើម្បីរំដោះប្រទេសជាតិ។ ចំណែកឯលោកវិញ លោកបែរជាស្ថិតនៅក្នុងស្ថានភាពនៅទំនេរ។ ខណៈពេលនេះ សំខាន់ណាស់សម្រាប់កត់សម្គាល់។ ជាក់ស្តែងនៅក្នុងសៀវភៅរបស់លោក E3/18 បានរៀបរាប់ពីការសម្ងំលាក់ខ្លួននៅក្នុងព្រៃដែលជាជីវភាពមួយក្នុងសភាពស្ងប់ស្ងាត់នៅតាមជនបទ។ ព្រោះតែការសម្ងំលាក់ខ្លួនគ្មានការងារអ្វីធ្វើ ហើយដែលត្រូវចល័តខ្លួនពីភូមិមួយទៅភូមិមួយ វាជាខណៈពេលបង្កឲ្យលោកមានការព្រួយបារម្ភ គិតច្រើន ព្រោះខ្លួនលោកជាបញ្ញាជនមិនអាចក្លាយទៅជាជនបដិវត្តន៍បានល្អនោះឡើយ។

[១៥:៥៦:៣០]

អំឡុងពេលនោះ សូមបញ្ជាក់ផងដែរថា ហេតុអ្វីបានជាក្រោយមកទៀត លោក ខៀវ សំផន សុខចិត្តក្លាយទៅជាបុគ្គលសាធារណៈនៃចលនាខ្មែរក្រហម ដោយមិនទទួលបាននូវអំណាចពិតប្រាកដ។ ទាក់ទងទៅនឹងចំណុចនេះ លោក សួង ស៊ីគឿន ដែលជាសាក្សីម្នាក់បានមកឆ្លើយអះអាងនៅចំពោះមុខអង្គជំនុំជម្រះ កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ ស្រដៀងគ្នានឹងលោក ខៀវ សំផន ផងដែរ ថា សូមដកស្រង់៖ "នៅពេលនោះ យើងខ្ញុំទាំងអស់គ្នា ក្នុងឋានៈជាបក្ខជនដែលបានទទួលការអប់រំនៅក្រៅប្រទេស ហើយជាពិសេសដែលធ្លាប់ជាប្រទេសអាណានិគមរបស់យើង យើងយល់ច្បាស់ថា ទស្សនៈគោលជំហររបស់យើង របៀបរស់នៅរបស់យើង ជាឧបសគ្គដ៏ឋានៈយើងជាបក្ខជន។ ដូច្នេះ យើងមាន

ទំនាស់ ឬមិនមានតូចចិត្តអ្វីទេនៅពេលនោះ ដែលបក្សកុម្មុយនីស្តកម្ពុជាទុកយើងជាកម្លាំងយុទ្ធសាស្ត្រ។ យើងសូមតែបម្រើទេ -- សូមតែបម្រើជាតិទេ ព្រោះពេលដែលយើងចូលមកក្នុងធ្វើបដិវត្តន៍ ចូលក្នុងបក្ស យើងបានប្ដេជ្ញាចិត្តច្បាស់លាស់ណាស់ ថានឹងជូនជីវិតរបស់យើងលះបង់អ្វីៗទាំងអស់ដើម្បីបក្ស ដើម្បីបដិវត្តន៍ និងដើម្បីប្រជាជន"។ សូមចប់ការដកស្រង់។ ការព្រួយបារម្ភរបស់លោក ខៀវ សំផន កាន់តែខ្លាំងជាងមុន។ ដោយសារតែចលនាបក្សបដិវត្តមិនទុកចិត្តចំពោះបញ្ញាជន គហបតីថ្នាក់ទាបនោះឡើយ។

លោក សួង ស៊ីគឿន ក៏បានបញ្ជាក់បន្ថែមផងដែរ សូមដកស្រង់៖ "ពេលនោះ ដើម្បីទៅធ្វើការងារទូត គឺខាងផ្នែកយើងខ្ញុំជាបញ្ញាជនមិនមានសង្ឃឹមថាបានទៅធ្វើការងារទូតទេ។ ព្រោះថា យើងមានវណ្ណៈដើមហ្នឹងមិនល្អ ហើយជាពិសេស គឺថាគោលជំហរ ទស្សនៈអីក៏មិនទាន់បានរឹងមាំ និងត្រឹមត្រូវដែរ។ ដូច្នេះ មិនមាននរណាអាចទៅធ្វើការងារតំណាងទូតទេ"។ សូបចប់ការដកស្រង់។

[១៥:៥៩:00]

លោក សួង ស៊ីគឿន ក៏បានពន្យល់បន្ថែមផងដែរ ចំពោះករណីដែលរូបលោក និងក្រុមបញ្ញាជនដទៃទៀត ត្រូវបានខ្មែរក្រហមចាត់ទុកថាជាកម្លាំងយុទ្ធសាស្ត្រដែលមានភាពខុសគ្នាពីកម្លាំងយុទ្ធវិធីបានពន្យល់ថា សូមដកស្រង់៖ "កម្លាំងជាយុទ្ធវិធី គឺវាទាក់ទងនឹងបញ្ញាជនជារួមទាំងអស់។ ជាពិសេសបញ្ញាជនដែលបានទៅរៀនសូត្រនៅប្រទេសបារាំង ហើយជាពិសេសទៀត គឺបញ្ញាជនដែលបានចូលរួមក្នុងបក្ស ក្នុងវង់ម៉ាក្សស៊ីស-លេនីន។ គឺបក្សកុម្មុយនីស្តកម្ពុជាពេលនោះ គឺត្រូវការបញ្ញាជនទាំងអស់ដើម្បីជាមុខមាត់ ហើយជាកម្លាំងប្រមូលមហាជនធំទូលាយ ជាពិសេសគឺថា បញ្ញាជន និស្សិត សិស្សសាលាទូទៅ ព្រោះពេលនោះជាការជាក់ស្ដែងមួយ គឺបញ្ញាជន ដែលគេហៅថា "បញ្ញាជនក្រហម" និងច្រើនជាអ្នកដែលពូកែខាងរៀនសូត្រ ហើយមានចរិតស្លូតបូត ដឹងចាស់ដឹងទុំ ហើយមានចិត្តទូលាយជួយរក្សាអ្នកផងទាំងពួង សិស្ស និស្សិតផងទាំងពួង។ ដូច្នេះកម្លាំងនេះ គេហៅថា "កម្លាំងបញ្ចោះជាកម្លាំងជំនួយ" ក៏ប៉ុន្តែមិនមែនជាកម្លាំងយុទ្ធសាស្ត្រទេ ព្រោះកម្លាំងយុទ្ធសាស្ត្រលុះត្រាតែពួកនេះចូលមកលត់ដំប្រឡូកនៅក្នុងសភាពការណ៍បដិវត្តន៍ជាក់ស្ដែងនៅក្នុងប្រទេស ប្រែក្លាយជាតិជាអនុធន មកជាធាតុអធន។ នេះគឺមានធាតុជាកម្មករបានអាចប្រែប្រួលទៅជាកម្លាំងយុទ្ធសាស្ត្រយូរអង្វែង"។ សូមបញ្ចប់ការដកស្រង់។

[១៦:00:៥២]

លោក សួង ស៊ីគឿន ក៏បានបញ្ជាក់ផងដែរ អំពីតួនាទីរបស់លោកក្នុងរណសិរ្សដែលជាកម្មាភិបាលក្រៅបក្ស ដូចលោក ឈូក រីន បានបញ្ជាក់ជូនអង្គជំនុំជម្រះនៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ អំពីតួនាទីរបស់លោក ខៀវ សំផន ដែលជាបញ្ញវន្តមិនចូលក្នុងបក្សដែលគេហៅថា "ជាមេដឹកនាំមានតែឈ្មោះ" ដែលលោក ឈូក រីន បានឮពីតាម៉ុក ថា លោក ខៀវ សំផន ជាបញ្ញាជនដែលមិនស៊ីជម្រៅក្នុងបក្សកុម្មុយនីស្តកម្ពុជាទេ។ លោក ឈូក រីន បានស្តាប់ការបកស្រែរបស់ តាម៉ុក ថា លោក ខៀវ សំផន ជាបញ្ញាជន គាត់មិនចូលក្នុងក្របខ័ណ្ឌកម្លាំង ឬស្នូលរបស់បក្សកុម្មុយនីស្តកម្ពុជាហ្នឹងទេ។ លោក ឈូក រីន បានបន្តផងដែរថា ភូមិភាគនិរតីដឹកនាំកម្លាំងស្នូល និងមូលដ្ឋានទាំងយោធា ដោយលោកបញ្ជាក់ថា លោក ខៀវ សំផន សូមដកស្រង់៖ "គាត់អត់យល់ទេ ព្រោះពេលហ្នឹងគាត់ក្រោមការការពាររបស់យោធាដែរ។

[១៦:០២:០១]

និយាយពីសច្ចៈ ដូចមេៗនិយាយអ៊ីចឹង ខៀវ សំផន ប្រហែលជាគាត់មិនដឹងថា ពេលហ្នឹងគេកំពុងកសាងជនចម្រើន កសាងសម្ព័ន្ធយុវកក ឬកសាងបក្ខជនទេ"។ លោក ឈូក រីន បានស្តាប់តាម៉ុកនិយាយថា សូមដកស្រង់៖ "បញ្ញវន្តអីហ្នឹង គឺគ្មានភាពឈ្លាសវៃ គ្មានភាពតស៊ូដាច់ខាតទេ"។ សូមបិទការដកស្រង់។

លោកប្រធាន ខ្ញុំឃើញម៉ោងនេះចប់ហើយ អាចបន្តទៀត ឬសូមសម្រាកពេលនេះ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអាចជម្រាបដល់អង្គសវនាការបានទេថាតើក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ហ្នឹងទំនងជាត្រូវការពេលវេលាប្រហែលជាប៉ុន្មានទៀតក្នុងការឡើងធ្វើសេចក្តីផ្តានបញ្ចប់កិច្ចពិភាក្សាដេញដោលនេះ?

**លោក គង់ សំអុន៖**

លោកប្រធានសម្រាប់ថ្ងៃនេះ ខ្ញុំគិតថាត្រូវការប្រហែលជាពេល១៥នាទីទៅ២០នាទី ទៀតបាទ។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងតែប៉ុណ្ណឹងទៀតចប់ ប្រហែលចំណាយទំនងតែ២០នាទីទៀតចប់ ឬក៏យ៉ាងម៉េច? ឬក៏មានត្រូវបន្តអីផ្សេងទៀតទេ?

**លោក គង់ សំអុន៖**

មិនមែនមានន័យថាចប់ទេ ខ្ញុំនិយាយថាចប់សម្រាប់ថ្ងៃនេះ ហើយនៅថ្ងៃចន្ទ យើងនឹងប្រើពេលមួយថ្ងៃថែមទៀត បើសិនជាត្រូវបន្តថ្ងៃចន្ទបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បើដូច្នោះទេ គឺទុកពេលវេលាបន្តទៅថ្ងៃចន្ទចុះ!

បាទ ឥឡូវនេះដល់ពេលត្រូវសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៨ ខែតុលា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយអង្គជំនុំជម្រះ សូមជម្រាបជូនភាគី និងសាធារណជនជ្រាបផងដែរថា នៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយនេះអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន ហើយក៏សូមជម្រាបជូនទៅភាគីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាផងដែរ ថា នៅថ្ងៃចន្ទ ប្រសិនបើពេលវេលានៅសេសសល់ពីការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់របស់សហមេធាវីការពារក្តីលោក ខៀវ សំផន នៅសមស្របដែលអាចបន្តបាននោះអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីធ្វើសេចក្តីសន្និដ្ឋានតបចុងក្រោយ។ នេះសូមជ្រាប។

បាទ សូមភាគី និងសាធារណជនជ្រាប ហើយនិងសូមអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅចន្ទសប្តាហ៍ក្រោយហ្នឹងឲ្យបានមុនពេលកំណត់។ អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនពួកគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃចន្ទដើមសប្តាហ៍ក្រោយ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក ដោយលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោមដែលរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៦ នាទី)*